# សហព័ន្ធស្រូវអង្ករកម្ពុជា

# Cambodia Rice Federation

## សមិទ្ធផលសហព័ន្ធស្រូវអង្ករកម្ពុជា

## អាណត្តិទី ២




**«ផ្តល់នូវអង្ករដែលមានតម្លៃ ប្រកួតប្រជែងនិងគុណភាព ខ្ពស់បំផុតដល់ពិភពលោក»**

ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩

August 9, 2019

CAMBODIA RICE FEDERATION

# សហព័ន្ធស្រូវអង្ករកម្ពុជា


និពន្ធ និងចងក្រងដោយ

ក្រុមការងារលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា



**ទំនាក់ទំនង**

សារអេឡិចត្រូនិក៖ info@crf.org.kh

ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៥៥៩ ៨៩៩៩

+៨៥៥ (0) ៨៧ ៥៥៩ ៨៩៩

**អាសយដ្ឋាន៖**

អគារពាណិជ្ជកម្ម សោម៉ា ជាន់ទី ៧

អាគារលេខ ២c ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មី II

ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា


## មាតិកា


Page

**1.** សេចក្តីផ្តើម 4

1.1. ប្រវត្តិសង្ខេប

1.2. ទស្សនវិស័យ

1.3. បេសកកម្ម

1.4. គុណតម្លៃ

1.5. អារម្ភកថារបស់ឯកឧត្តមប្រធាន

1.6. រចនាសម្ព័ន្ធសហព័ន្ធស្រូវអង្ករកម្ពុជា

1.6.1. ក្រុមប្រឹក្សាភិបាល

1.6.2. លេខាធិការដ្ឋាន

1.6.3. គណៈកម្មាធិការទាំង៦

**2.** សកម្មភាពការងារនិងសមិទ្ធផលសំខាន់ៗ 22

2.1. គណៈកម្មាធិការប្រតិបត្តិផ្សព្វផ្សាយទីផ្សារនិងការនាំចេញ

2.1.1. កម្ពុជាឈ្នះពានរង្វាន់អង្ករល្អបំផុតពិភពលោកចំនួន៤លើក

2.1.2. ការបង្កើតនិងដាក់សម្ពោធម៉ាកអង្ករជាតិ «ម្លិះអង្ករ (MALYS ANGKOR)»អង្ករក្រអូបប្រណិត

2.1.3. រៀបចំវេទិកាស្រូវអង្ករថ្នាក់ជាតិនិងអន្តរជាតិ និងពិធីបុណ្យស្រូវអង្ករកម្ពុជាជាប្រចាំ

2.1.4. ការដឹកនាំសមាជិកចូលរួមផ្សព្វផ្សាយអង្ករនិងចាប់ដៃគូពាណិជ្ជកម្ម

2.1.5. ចូលរួមពង្រឹងនិងពង្រីកការអនុវត្តកូតានាំចេញទៅកាន់ទីផ្សារចិននិងប្រទេសនានា

2.1.6. ការប្តឹងតវ៉ាករណីសហភាពអឺរ៉ុបដាក់ពន្ធលើការនាំចូលអង្ករកម្ពុជា និងពង្រឹងទីផ្សារអង្ករអឺរ៉ុប

2.2. គណៈកម្មាធិការរោងម៉ាស៊ីន-ការកិនកែច្នៃ និងឡសម្ងួត

2.2.1. គម្រោងឃ្លាំង-ឡសម្ងួត

2.2.2. កាត់បន្ថយចំណាយលើការវាយតម្លៃផលប៉ះពាល់បរិស្ថាន

2.2.3. សម្របសម្រួលជាមួយអគ្គនាយកដ្ឋានកសិកម្ម និងAQSIQ

2.2.4. សម្របសម្រួលជាមួយអគ្គនាយកដ្ឋានពន្ធដាររៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីស្តង់ដារប្រព័ន្ធគណនេយ្យ កាតព្វកិច្ចជាប់ពន្ធ

2.2.5. សហការជាមួយ SGS, Bureau Veritas បណ្តុះបណ្តាលពង្រឹងគុណភាព និងស្តង់ដាររោងម៉ាស៊ីន

2.2.6. ប្រមូល និងផលិតទិន្នន័យ

2.3. គណៈកម្មាធិការផលិតកម្ម ពូជ និងការងារសហគមន៍

2.3.1. កម្មវិធីផលិតស្រូវតម្រូវទីផ្សារ៖

2.3.1.1. សម្រេចបាននូវការបន្សុទ្ធពូជសែនក្រអូប

2.3.1.2. កំពុងបង្កាត់ពូជផ្ការំដួលមិនប្រកាន់រដូវ

2.3.2. រៀបចំការប្រកួតជ្រើសរើសជ័យលាភីសហគមន៍ដាំដុះស្រូវល្អជាងគេបំផុតប្រចាំកម្ពុជា

2.3.3. ជំរុញការអនុវត្តកិច្ចសន្យាកសិកម្មរវាងរោងម៉ាស៊ីនឬក្រុមហ៊ុននាំចេញជាមួយសហគមន៍កសិកម្ម

2.3.4. កម្មវិធីពង្រឹងសហគមន៍៖ គម្រោងវេទិកាគ្រាប់ពូជជាមួយគម្រោងJiCa និង សិក្ខាសាលាជាមួយGIZ កសាងសមត្ថភាព

2.3.5. ផ្សព្វផ្សាយការហាមឃាត់ការប្រើប្រាស់ថ្នាំកសិកម្មដែលមានផ្ទុកសារធាតុគីមី Tricy-clazole

2.4. គណៈកម្មាធិការផ្នែកឥណទាននិងធនាគារ

2.4.1. ការប្រែក្លាយធនាគារអភិវឌ្ឍន៍ជនបទទៅជាធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម

2.4.2. ឱកាសទទួលបានទុនបង្វិល និងពង្រីកការវិនិយោគ

2.4.3. បង្កើន Credit Line ជាមួយនឹងអត្រាការប្រាក់សមរម្យ

2.4.4. ការបណ្តុះបណ្តាល

2.4.5. ការស្រាវជ្រាវ

2.4.6. គម្រោងឃ្លាំង និងគំរូនៃការទទួលឥណទានតាមរយៈបញ្ចាំស្តុក

2.5. គណៈកម្មាធិការកាត់បន្ថយថ្លៃដើម

Executive Committee of Cost of Competiveness

2.5.1. កាត់បន្ថយចំណាយលើអគ្គិសនីទទួលបានជាបន្តបន្ទាប់

2.5.2. កាត់បន្ថយថ្លៃលើកដាក់(LoLo Fee) ថ្លៃត្រួតពិនិត្យ ថ្លៃស្តេនកុងទីន័រអង្ករ ដោយបានសហការជាមួយកំពង់ផែក្រុងព្រះសីហនុ និងកំពង់ផែភ្នំពេញ

2.5.3. លើកលែងពន្ធអាករបន្ថែមVAT លើកលែងពន្ធដែលមិនបានបង់មុនឆ្នាំអនុគ្រោះ និងលើកលែងពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំសម្រាប់ការនាំចេញអង្ករ

2.5.4. ការសម្រួលកម្រៃស្តេនរបស់ស្ថាប័នគយ

2.5.5. លុបចោលរបាំងពាណិជ្ជកម្មនានា និងកាំសាប ជាដើម

2.6. គណៈកម្មាធិការក្រមសីលធម៌និងវិន័យ

2.6.1. ទប់ស្កាត់និងប្រឆាំងអង្ករក្លែងក្លាយ

2.6.2. សហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការស្រាវជ្រាវ និងបង្ក្រាបបទល្មើសអង្ករ

2.7. លេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា

2.8. ក្រុមការងារសម្របសម្រួលនៅថ្នាក់តំបន់ និងខេត្ត៖

2.8.1. ក្រុមការងារតំបន់ទី១&២

2.8.2. ក្រុមការងារតំបន់ទី៤&៥

**3.** កិច្ចសហការជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា 44

3.1. កិច្ចសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការដោះស្រាយបញ្ហា

3.1.1 តាមរយៈវេទិការាជរដ្ឋាភិបាល-វិស័យឯកជន ផ្នែកស្រូវអង្ករ (ក្រុមការងារទី៩)

3.1.2. កិច្ចសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម

3.2. កិច្ចសហការជាមួយក្រសួងពាណិជ្ជកម្ម

3.3. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

3.4. កិច្ចសហការជាមួយអគ្គនាយកដ្ឋានពន្ធដារ

3.5. អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

3.6. ក្រសួងសាធារណៈការ និងដឹកជញ្ជូន

3.7. កិច្ចសហការជាមួយក្រសួងបរិស្ថាន

3.8. កិច្ចសហការជាមួយសភាពាណិជ្ជកម្មកម្ពុជា

3.9. កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា

**4.** ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពដែលនៅសេសសល់ត្រូវបន្តអនុវត្ត 62

**5.** ទិន្នន័យសំខាន់ៗ 70

5.1. ទិន្នន័យ-ស្ថិតិ (តម្លៃអង្ករFOB និងការនាំចេញអង្ករ២០១០-២០១៩ និងតម្លៃស្រូវ

5.2. ផែនទីតំបន់ រោងម៉ាស៊ីន និងសហគមន៍

5.3. កម្រងរូបភាពផ្សេងៗ


CAMBODIAN PREMIUM AROMATIC RICE

MALYS ANGKOR

## ម៉ាកវិញ្ញាតកម្មអង្ករជាតិ "ម្លិះអង្គរ"

(MALYS ANGKOR)

សូមអបអរសាទរ និងកោតសរសើរយ៉ាងជ្រាលជ្រៅ ចំពោះ



កសិករខ្មែរ និងរោងម៉ាស៊ីនស្រូវ ដែលបានខិតខំប្រឹងប្រែង ឥតឈប់ឈរក្នុងការផលិត និង កែច្នៃស្រូវ មានគុណភាពល្អ ពូជផ្កាម្លិះ និង បានធ្វើឲ្យ ប្រទេសយើងឈ្នះពានរង្វាន់អង្ករល្អបំផុតរបស់ ពិភពលោក ៤ លើក ២០១២-២០១៣-២០១៤-២០១៨ ជាតិទាំងមូល មានមោទនភាពចំពោះគ្នា!

# សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

## 1. ប្រវត្តិសង្ខេប

**នៅឆ្នាំ២០១០** រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយស្រូវអង្ករជាលើកដំបូង សំដៅជំរុញផលិតកម្មស្រូវ និងបង្កើនការនាំចេញអង្ករដោយមានភាពប្រកួតប្រជែងលើទីផ្សារអន្តរជាតិ។ ការពង្រឹងទំនុកចិត្តនៅក្នុងវិស័យស្រូវអង្ករក្លាយជាតម្រូវការចាំបាច់។

**នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤** ដោយមានការគាំទ្រពីតួអង្គសំខាន់ៗនៅក្នុងវិស័យស្រូវអង្ករបានសម្រេចបង្កើតសហព័ន្ធស្រូវអង្ករឡើងតាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលចំនួន ១៧រូបពីសំណាក់សមាជិកស្ថាបនិក២១៣នាក់ មកពីតំណាងសហគមន៍កសិកម្ម សមាគមរោងម៉ាស៊ីនកិនស្រូវ សមាគមអ្នកនាំចេញអង្ករ ក្រុមហ៊ុនដឹកជញ្ជូន និងភាគីពាក់ព័ន្ធ ដោយមានការគាំទ្រពីក្រសួងពាណិជ្ជកម្ម។

បន្ទាប់មករាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់សហព័ន្ធស្រូវអង្ករកម្ពុជាជាដៃគូ តែមួយគត់សម្រាប់ការពិភាក្សាគោលនយោបាយ និងជាអ្នកតំណាងវិស័យស្រូវអង្ករបស់កម្ពុជានៅលើឆាកអន្តរជាតិ ហើយក៏ជាស្ថាប័នមួយដែលត្រូវអភិវឌ្ឍរៀបចំវេទិកាថ្នាក់ជាតិនិងអន្តរជាតិដើម្បីលើកកម្ពស់វិស័យស្រូវអង្ករកម្ពុជាទាំងក្នុងស្រុក និងឆាកអន្តរជាតិ តាមរយៈអនុក្រឹត្យលេខ២២៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ។

គោលបំណងចម្បងនៃសហព័ន្ធស្រូវអង្ករកម្ពុជា គឺការពង្រឹងសាមគ្គីផ្ទៃក្នុង បង្កើតទំនុកចិត្តលើខ្សែចង្វាក់ស្រូវអង្ករទាំងមូល ជំរុញការផលិតស្រូវតាមរយៈការប្រើប្រាស់បច្ចេកទេសទំនើបនិងបង្កើនការនាំចេញ ព្រមទាំងពង្រឹងការប្រកួតប្រជែងអង្ករកម្ពុជានៅលើទីផ្សារអន្តរជាតិ។

**ឯកឧត្តម សុខ ពុទ្ធិវុធ** ត្រូវជាប់ការបោះឆ្នោតជាប្រធានក្រុមប្រឹក្សាភិបាលក្នុងអាណត្តិទី១ ដែលមានរយៈពេល២ឆ្នាំ ដោយផ្អែកលើសមត្ថភាពនិងការយល់ឃើញស៊ីជម្រៅអំពីយុទ្ធសាស្ត្រ នៃការអភិវឌ្ឍវិស័យស្រូវអង្ករកម្ពុជា  និងមានស្នាដៃល្អ មានទំនុកចិត្តខ្ពស់ពីសមាជិកនិងស្ថាប័នដៃគូ ឯកឧត្តម សុខ ពុទ្ធិវុធ ត្រូវបានជាប់ការបោះឆ្នោតដឹកនាំបន្តសម្រាប់អាណត្តិទី២ មានរយៈពេល៣ឆ្នាំ។

ក្នុងរយៈពេលពីរអាណត្តិស្មើនឹង៥ឆ្នាំកន្លងមកនេះ សហព័ន្ធស្រូវអង្ករកម្ពុជាបានសម្រេចនូវសមិទ្ធផលជាច្រើន តាមរយៈការដឹកនាំក្រុមប្រឹក្សាភិបាលប្រកបដោយតម្លាភាព សាមគ្គីភាព និងមានគណៈកម្មាធិការប្រតិបត្តិទាំង៦ និងលេខាធិការដ្ឋានមួយដែលរឹងមាំដែលអាចអនុវត្តលើផែនការដែលក្រុមប្រឹក្សាភិបាលដាក់ចេញ។

## បេសកកម្ម

ដើម្បីសម្រេចទស្សនវិស័យនេះ សហព័ន្ធស្រូវអង្ករកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់ផលិតភាពដើម្បីធ្វើឲ្យប្រសើរឡើងនូវបច្ចេកទេសកសិកម្មនិងការកិនកែច្នៃអង្ករកម្ពុជា ការកាត់បន្ថយចំណាយថ្លៃដើមក្នុងដំណើរការនាំចេញ ការលើកកម្ពស់ក្រមប្រតិបត្តិមួយក្នុងក្របខណ្ឌនៃវិស័យស្រូវអង្ករទាំងមូលដែលមានតម្លៃសម្រាប់ការវិនិយោគ និងការអនុវត្តនូវស្តង់ដារក្រមសីលធម៌ខ្ពស់បំផុត ក្នុងប្រតិបត្តិការរបស់យើងទាំងអស់គ្នាជាមួយនឹងភាគីពាក់ព័ន្ធ ដើម្បីការពារគុណភាពអង្កររយៈវែង កេរ្តិ៍ឈ្មោះ និងនិរន្តរ៍ភាពនៃការផ្គត់ផ្គង់អង្ករកម្ពុជា។

## គុណតម្លៃ

គុណតម្លៃទាំង៨របស់សហព័ន្ធស្រូវអង្ករកម្ពុជាតំណាងឲ្យតម្លៃនៃក្រមសីលធម៌ និងគោលការណ៍នៃការងារដែល   ជំរុញនូវរាល់សកម្មភាពរបស់សមាជិកសមាជិកាបុគ្គលិក និងថ្នាក់ដឹកនាំនៃសហព័ន្ធស្រូវអង្ករកម្ពុជា។ តម្លៃនៃក្រមសីលធម៌និងគោលការណ៍នៃការងារទាំងនោះរួមមាន៖

- សាមគ្គីភាព
- សុចរិតភាព
- តម្លាភាព
- ការអនុវត្តជាក់ស្តែង
- ការផ្តោតលើលទ្ធផល
- ភាពលឿន
- ផលប៉ះពាល់ពីការវិនិយោគ
- អត្ថប្រយោជន៍ទៅសមាជិក សហគមន៍ និងវិស័យស្រូវអង្ករកម្ពុជាទាំងមូល។



ឯកឧត្តម **សុខ ពុទ្ធិវុធ**

# អារម្ភកថារបស់ឯកឧត្តម សុខ ពុទ្ធិវុធ
# ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា សមាជិកសមាជិកា លេខាធិការដ្ឋាន និងភាគីពាក់ព័ន្ធទាំងអស់ដែលបានជួយគាំទ្រ ដល់សហព័ន្ធស្រូវអង្ករកម្ពុជាបន្ទាប់ពីបដិសន្ធិមក ក្នុងអំឡុងពេល៥ឆ្នាំនេះ។ កិច្ចសហការគ្នា ការជឿទុកចិត្ត តម្លាភាព ប្រសិទ្ធភាព និងរួមគ្នាក្នុងសម្លេងតែមួយ ដែលយើងសម្រេចបានក្នុងរយៈពេល២អាណត្តិនេះបានធ្វើអោយសហព័ន្ធស្រូវអង្ករកម្ពុជារបស់យើងកាន់តែរឹងមាំ និងត្រូវបានគេទទួលស្គាល់ ទាំងថ្នាក់ជាតិ និងអន្តរជាតិ។ ជាមួយនឹងការជឿទុកចិត្តនេះ បានធ្វើអោយសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជាមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ពោលគឺកើនឡើងពីចំនួនសមាជិកពី២១៣រូបនៅឆ្នាំ២០១៤ រហូតដល់៣១៣សមាជិកនៅឆ្នាំ២០១៩ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងចង្វាក់ផលិតកម្ម ដោយរាប់ទាំងសហគមន៍កសិករ រោងម៉ាស៊ីនកិនស្រូវ អ្នកនាំចេញ ធនាគារ ក្រុមហ៊ុនត្រួតពិនិត្យគុណភាព ក្រុមហ៊ុនដឹកជញ្ជូន ឡូជីស្ទិក ក្រុមហ៊ុនផលិតធាតុចូលកសិកម្ម។ល។ ជាមួយគ្នានេះ ការជឿទុកចិត្តនេះក៏បានធ្វើអោយដៃគូអភិវឌ្ឍន៍មួយចំនួនបានសហការអនុវត្តគម្រោងនានាជាមួយសហព័ន្ធនាពេលកន្លងមក ហើយយើងអាចស្នើសុំនូវមូលនិធិគាំទ្រដោយផ្ទាល់ពីដៃគូអភិវឌ្ឍន៍ផងដែរ។ ការទុកចិត្តនេះគឺជាសក្តានុពលមួយ ដែលយើងអាចពង្រីកវិសាលភាពនៃកិច្ចសហប្រតិបត្តិការគ្នាដើម្បីកៀរគរធនធានបន្ថែមទៀតក្នុងការប្រែក្លាយវិស័យស្រូវអង្ករកម្ពុជាឆ្ពោះទៅរកវឌ្ឍនភាពការធ្វើទំនើបកម្ម និងឈានមុខគេនៅពេលអនាគត។

ក្នុងរយៈពេល៥ឆ្នាំនេះ សមិទ្ធិផលជាច្រើនរបស់សហព័ន្ធស្រូវអង្ករកម្ពុជាត្រូវបានគេទទួលស្គាល់តាមរយៈការចូលរួមដោយផ្ទាល់ក្នុងការដោះស្រាយពីឫសគល់នៃបញ្ហា និងការពង្រឹងសង្វាក់ផលិតកម្មអោយកាន់តែរឹងមាំ និងបង្កើននូវភាពប្រកួតប្រជែងជាមួយប្រទេសនានាដែលផលិតស្រូវអង្ករ។ ការចាប់ផ្តើមដំបូង គឺការកសាងស្ថាប័ន ដោយយើងបានប្រែក្លាយសហព័ន្ធស្រូវអង្ករកម្ពុជាទៅជាស្ថាប័នមួយដែលរួបរួមពីគ្រប់សមាគមន៍ សហព័ន្ធនានា ដែលពីមុនធ្វើការនៅផ្សេងៗគ្នាមកធ្វើការលើតុតែមួយ ហើយរួមគ្នាដើម្បីវិស័យនេះដោយមានការកំណត់នូវចក្ខុវិស័យ និងផែនការសកម្មភាពច្បាស់លាស់ ក្នុងការដោះស្រាយបញ្ហាប្រឈមគន្លឹះនានា ដោយរួមទាំងការការចរចារបញ្ចុះថ្លៃដើមអោយកាន់តែទាប ការបង្កើនគុណភាពស្តង់ដារ ការបង្កើតម៉ាកសញ្ញា និងការផ្សព្វផ្សាយអង្ករកម្ពុជាលើឆាកអន្តរជាតិផងដែរ។ កិច្ចការនេះបានរួមចំណែកយ៉ាងសំខាន់ដល់ការបង្កើនល្បឿននៃការរីកចម្រើនរបស់វិស័យនេះ។ ជាក់ស្តែងនៅក្នុងរយៈពេល៥ឆ្នាំនេះ យើងពិនិត្យឃើញការរីកចម្រើននៃផលិតកម្មស្រូវ ពូជស្រូវ សមត្ថភាពកិនកែច្នៃនៃរោងម៉ាស៊ីន ការកើនឡើងនៃការនាំចេញអង្ករ ដែលនៅពេលចាប់ផ្តើមរបស់សហព័ន្ធ ការនាំចេញមានប្រមាណ១០ម៉ឺនតោននៅឆ្នាំ២០១០ ហើយបានកើនឡើងរហូតដល់ជាង ៦៣ ម៉ឺនតោន ក្នុងឆ្នាំ២០១៨ ដោយបាននាំចេញអង្ករទៅកាន់ជាង៦០ប្រទេស ហើយកេរ្តិ៍ឈ្មោះអង្ករកម្ពុជាត្រូវគេទទួលស្គាល់ថាជាអង្ករឆ្ងាញ់ជាងគេនៅលើពិភពលោក ដោយយើងទទួលបានពានរង្វាន់អង្ករល្អជាងគេពិភពលោកចំនួន៤លើករួចមកហើយ ពិសេសឆ្នាំ២០១៨ថ្មីៗនេះ។

សៀវភៅនេះ នឹងរៀបរាប់លម្អិតអំពីសមិទ្ធផលដែលក្រុមការងារសហព័ន្ធស្រូវអង្ករកម្ពុជា និងភាគីពាក់ព័ន្ធនានាបានសហការគ្នាក្នុងការធ្វើការដើម្បីសម្រេចបាននូវលទ្ធផលជាផ្លែផ្កា។ ខ្ញុំសូមឧទ្ទិសសមិទ្ធិផលដែលយើងសម្រេចបានក្នុងរយៈពេល៥ឆ្នាំនេះ ជូនដល់ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការប្រតិបត្តិ សមាជិកសមាជិកា ក្រុមការងារលេខាធិការដ្ឋាន ភាគីពាក់ព័ន្ធ និងបងប្អូនប្រជាកសិករទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងស្មារតីរួបរួមសាមគ្គីគ្នា ក្នុងការលើកស្ទួយវិស័យស្រូវអង្ករកម្ពុជាអោយរីកចម្រើនឈានមុខគេនៅលើឆាកអន្តរជាតិ។ ខ្ញុំសូមគោរពជូនពរ សូមមាននូវជោគជ័យក្នុងភារកិច្ចការងារ និងសុភមង្គលក្នុងក្រុមគ្រួសារ។

**ថ្ងៃសុក្រ ៩កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣**
**រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែសីហា ឆ្នាំ២០១៩**
**ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា**

**សុខ ពុទ្ធិវុធ**

**សហព័ន្ធស្រូវអង្ករកម្ពុជា**
Cambodia Rice Federation

# រចនាសម្ព័ន្ធសហព័ន្ធស្រូវអង្ករកម្ពុជា អាណត្តិទី២



# ក្រុមប្រឹក្សាភិបាល

## រចនាសម្ព័ន្ធថ្នាក់ដឹកនាំសហព័ន្ធអាណត្តិទី២



ឯ.ឧ សុខ ពុទ្ធិវុធ
ប្រធាន



ឧកញ៉ា ហ៊ុន ឡាក់
អនុប្រធាន



ឧកញ៉ា វង្ស ប៊ុនហេង
អនុប្រធាន



លោក នង វាសនា
អនុប្រធាន



លោក ហេង ផេង
អនុប្រធាន



លោក ស៊ី រ៉ានី
អនុប្រធាន



លោក ចាន់ សុខទី
សមាជិក



លោក ឈិត ប៊ុនថន
សមាជិក



ឧកញ៉ា គុត ចាន់វាសនា
សមាជិក



លោកស្រី អន សារុណា
សមាជិក



លោក សំអាត វាសនា
សមាជិក



លោក ហ៊ី ហ៊ីត
សមាជិក



លោក ឈុន ធំ
សមាជិក



លោក ឡាយ ឈុនហួ
សមាជិក



ឧកញ៉ា ច្រាយ សុន
សមាជិក



លោក តួ វាសនា
សមាជិក



លោក គឹម ប៊ុនសាន
សមាជិក

# លេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា

## SECRETARIAT



**Secretary General**
H.E Moul Sarith



**Assistant to President & Deputy Secretary General**
Mr. Horn Theara, PhD



**HR Officer & Assistant to Secretary General**
Mr.Phun Khemra

### Processing & Milling



**Mapping & Researching Officer**
Mr.San Tit

### Seeds & Farmers



**Seed & Farming Senior Officer**
Mr.Kong Virak

### Human Resource , Finance & Administration



**Accountant**
Ms.Thoeurn Sovatana

### Communication officer



Mr. Nop Soknea

### Admin Officer



Ms. Thun Sreymom

## ZONE DIRECTOR



**Zone Manager (Zone 4 & 5)**
Mr.Tithsothy Dianorin



**Zone Manager (Zone 1 & 2)**
Mr.Khe Iongmeng

«ផ្តល់នូវអង្ករដែលមានតម្លៃ ប្រកួតប្រជែងនិងគុណភាពខ្ពស់បំផុតដល់ពិភពលោក»

# គណៈកម្មាធិការទាំង៦

ដោយមើលឃើញពីភាពចាំបាច់ក្នុងការអនុវត្តនូវផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពឱ្យសម្រេចបានជោគជ័យខ្ពស់ ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជាបានសម្រេចបង្កើតគណៈកម្មាធិការប្រតិបត្តិទាំងអស់ចំនួន៦ ហើយគណៈកម្មាធិការនីមួយៗមានតួនាទីនិងភារកិច្ច ដូចមានចែងក្នុងសេចក្តីប្រកាស និងត្រូវធ្វើរបាយការណ៍ជាទៀងទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណីការងារណាដែលមិនមានចែងក្នុងក្របខណ្ឌផែនការសកម្មភាព គណៈកម្មធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលអនុញ្ញាតសម្រេចជាមុន។ ក្នុងករណីចាំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និងទីប្រឹក្សាសម្រាប់គណៈកម្មាធិការបាន។

គណៈកម្មាធិការមានភារកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្តលើកិច្ចការនៅក្នុងក្របខណ្ឌ ដែលមានចែងនៅក្នុងផែនការសកម្មភាព ដែលបានអនុវត្តដោយក្រុមប្រឹក្សាភិបាលសហព័ន្ធ និងមានបុគ្គលិកលេខាធិការដ្ឋានមួយរូបជាអ្នកសម្របសម្រួល គណៈកម្មាធិការទាំងនោះរួមមាន៖

**គណៈកម្មាធិការប្រតិបត្តិផ្នែកទីផ្សារនិងជំរុញការនាំចេញ**

Market Promotion and Export Executive Committee

**គណៈកម្មាធិការប្រតិបត្តិផ្នែករោងម៉ាស៊ីន និងឃ្លាំង**

Milling and Storage Executive Commitee

**គណៈកម្មាធិការប្រតិបត្តិផលិតកម្ម ពូជ និងកសិករ**

Seed and Farming Executive Committee

**គណៈកម្មាធិការប្រតិបត្តិផ្នែកឥណទាន**

Finance and Banking Solution Executive Committee

**គណៈកម្មាធិការប្រតិបត្តិកាត់បន្ថយថ្លៃដើម**

Cost Competitivenest Executive Committee

**គណៈកម្មាធិការប្រតិបត្តិក្រមសីលធម៌និងវិន័យ**

Code Conduct and Ethics Executive Committee

សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខៈ ១៥៤ /១៦ ស.អ.ក

**ប្រកាស**

**ស្តីពី**

**ការកែសម្រួលសមាសភាពគណៈកម្មាធិការផ្សព្វផ្សាយទីផ្សារសំរាប់នាំចេញអង្ករកម្ពុជា**

(Global Market Promotion Executive Committee)

**យោងៈ** - អនុក្រឹត្យស្តីពីការទទួលស្គាល់ការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា លេខ២២៨ អនក្រ.បក ចុះថ្ងៃទី៨ សីហា ឆ្នាំ២០១៤
- បានឃើញលក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាតកាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥
- យោងតាមការចាំបាច់របស់សហព័ន្ធស្រូវអង្ករកម្ពុជា

**សម្រេច**

**ប្រការ១.**

ការកែសម្រួលសមាសភាពគណៈកម្មាធិការទទួលបន្ទុកផ្សព្វផ្សាយទីផ្សារសំរាប់នាំចេញអង្ករកម្ពុជា (Global Market Promotion Executive Committee) ដែលមានសមាសភាពចំនួន ១១រូប និងលេខាធិការ ០១រូបដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តម សុខ ពុទ្ធីវុធ | ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា | ប្រធាន |
| ២. ឧកញ៉ា គុត ចាន់វាសនា | ក្រុមហ៊ុន Crystal Rice (Kampuchea) Co., Ltd | អនុប្រធាន |
| ៣. លោក ឡាយ ឈុនហ៊ួ | ក្រុមហ៊ុន City Rice Import Export Co.,Ltd | អនុប្រធាន |
| ៤. លោក ចាន់ សុខទី | អគ្គនាយកក្រុមហ៊ុន ហ្គ្រីនត្រេដ | អនុប្រធាន |
| ៥. លោក តឹម ប៊ុនសាន | ក្រុមហ៊ុន Khmer Foods Group Co., Ltd | សមាជិក |
| ៦. លោក ភូ វាសនា | រោងម៉ាស៊ីនកិនស្រូវ អ៊ឹង វណ្ណម៉ៅ | សមាជិក |
| ៧. លោក វង្ស ឈីវ | ក្រុមហ៊ុន Hung Hiep (Cambodia) Co.,Ltd | សមាជិក |
| ៨. លោក ចាន់ ពេជ្រ | ក្រុមហ៊ុន Signatures of Asia Co.,Ltd | សមាជិក |
| ៩. លោក សុខ ដេវីដ | ក្រុមហ៊ុន Golden Rice (Cambodia) | សមាជិក |
| ១០. លោក អ៊ុំ តារាសិទ្ធី | ក្រុមហ៊ុន FEDRICE BATTAMBANG LTD | សមាជិក |
| ១១. លោក Boonkiat Wongcharoensangsiri | ក្រុមហ៊ុនApsara Rice (Cambodia) Co.,Ltd | សមាជិក |
| លោក ពៅ បុណ្ណរិទ្ធ | ប្រធានផ្នែកទីផ្សារនៃសហព័ន្ធស្រូវអង្ករកម្ពុជា | លេខាធិការ |

**ប្រការ២.**

គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្តលើកិច្ចការនៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងផែនការសកម្មភាពដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល តាមការងារដូចខាងក្រោមៈ


#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia • Tel: +855 23 722 250 • Mail: info@crf.org.kh

1. ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ធ្វើការរៀបចំយុទ្ធសាស្រ្ត និងអនុវត្តលើការងារការបង្កើតម៉ាកយីហោអង្ករកម្ពុជា (CAMBODIAN RICE BRAND)សំរាប់ធ្វើការផ្សព្វផ្សាយ និងជំរុញការលក់អង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។
2. កំណត់នូវយុទ្ធសាស្រ្តទីផ្សារ ការពង្រីក និងពង្រឹងភាពប្រកួតប្រជែងអង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។
3. ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ក្នុងការចរចារជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិទីភ្នាក់ងារអភិវឌ្ឍន៍នានា ក្នុងការស្វែងរកនូវកិច្ចសហប្រតិបត្តិការ ការកៀងគររកនូវជំនួយសំរាប់ជួយដល់ការធ្វើសកម្មភាពការជំរុញផ្សព្វផ្សាយ អង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។
4. គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ ជាទៀងទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណី ការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលអនុញ្ញាតសំរេចជាមុន។
5. ក្នុងករណីចំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និង ទីប្រឹក្សាសំរាប់គណៈកម្មាធិការនេះ។

**ប្រការ៣.**

កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន ដោយត្រូវមានការចូលរួមពីសមាជិកយ៉ាងតិច ៥០%+១ នៃសមាសភាពសរុប និងអាចអនុម័តសម្រេចបាន ក៏ត្រូវមានសំលេង ២ភាគ៣ នៃសមាសភាពចូលរួមប្រជុំ។

**ប្រការ៤.**

ក្រុមប្រឹក្សាភិបាល លេខាធិការដ្ឋាន ការិយាល័យសាខាតាមខេត្ត និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦

**ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា**

**ប្រធាន**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

ចម្លងជូន៖
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្រ្តី ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្រ្តី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ធនាគារអភិវឌ្ឍន៍ជនបទ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានកសិកម្ម
- លេខាធិការដ្ឋានច្រកចេញចូលតែមួយ
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខ: ១៥៥ /១៦ ស.អ.ក

**ប្រកាស**
**ស្តីពី**
**ការបង្កើតគណៈកម្មាធិការទទួលបន្ទុកការងាររោងម៉ាស៊ីន និងឃ្លាំង**
**(Milling and Storage Executive Committee)**

**យោង៖** - អនុក្រឹត្យស្តីពីការទទួលស្គាល់ការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា លេខ២២៨ អនក្រ.បក ចុះថ្ងៃទី៨ សីហា ឆ្នាំ២០១៤
- បានឃើញលក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាតកាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥
- យោងតាមការចាំបាច់របស់សហព័ន្ធស្រូវអង្ករកម្ពុជា

**សម្រេច**

**ប្រការ១.**

បង្កើតគណៈកម្មាធិការទទួលបន្ទុកដោះស្រាយការងារជាមួយរោងម៉ាស៊ីននិងឃ្លាំង(Milling & Storage Executive Committee) ដែលមានសមាសភាពចំនួន ១១រូប និងលេខាធិការ ០១រូប ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក នង វាសនា | ប្រធានផ្នែកទីផ្សារនៃក្រុមហ៊ុន NKL | ប្រធាន |
| ២. លោក ឈុន ធំ | រោងម៉ាស៊ីន ឈុនធំ | អនុប្រធាន |
| ៣. លោក យន់ ហុង | ឥណ្ឌូឆាយណា រ៉ាយស៍មីល លីមីតធីត | អនុប្រធាន |
| ៤. លោក ឈិត ប៊ុនថន | រោងម៉ាស៊ីន ឈិតប៊ុនថន | សមាជិក |
| ៥. លោក រិទ្ធ សីហា | នាយកប្រតិបត្តិ Mekong Agro | សមាជិក |
| ៦. លោក វិញ ផាង | ម៉ាស៊ីនស្រូវ អ៊ឹងហ៊ុយមាង | សមាជិក |
| ៧. លោក សែ ឡាឡៃន | រោងម៉ាស៊ីន ហាក់ សែ | សមាជិក |
| ៨. លោក រស់ សុផារិទ្ធ | រោងម៉ាស៊ីន ១៦៨៨ | សមាជិក |
| ៩. លោក ហុង តុង | ដាប់បែលឃូ ឌេ អ ត្រេឌីង | សមាជិក |
| ១០. លោក ហួរ លុច | រោងម៉ាស៊ីន ភូ កុកគី | សមាជិក |
| ១១. លោក ហ៊ី ហ៊ត | រោងម៉ាស៊ីន ណមស្រ៊ីម | សមាជិក |
| មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា | | លេខាធិការ |

**ប្រការ២.**

គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្តលើកិច្ចការនៅក្នុងក្របខ័ណ្ឌ ដែលមានចែងនៅក្នុងផែនការសកម្មភាពដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលសហព័ន្ធ តាមការងារដូចខាងក្រោម៖

១. ជូនសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ធ្វើការរៀបចំផែនការសកម្មភាព និងការអនុវត្តជាក់ស្តែង ដោយផ្អែកលើផែនការមេរបស់សហព័ន្ធ ដោយសហការជាមួយរោងម៉ាស៊ីនកំណត់ទីតាំងក្នុងការពង្រីកឃ្លាំង ម៉ាស៊ីន


#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia • Tel: +855 23 722 250 • Mail: info@crf.org.kh

សម្ងួត ដើម្បីប្រមូលស្រូវទុកនៅរដូវប្រមូលផល និងការបញ្ចាំស្តុកដើម្បីឲ្យសហគមកសិករនិងប្រជាជន អាចយកស្រូវមកបញ្ចាំស្តុកដើម្បីយកថវិកាទៅបង្វិលបាន។

២. កំណត់នូវយុទ្ធសាស្ត្រ ទិសដៅជម្រុញការរីកចម្រើនរបស់រោងម៉ាស៊ីន ឃ្លាំង និងម៉ាស៊ីនសម្ងួត ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការរីកចម្រើននៃបច្ចេកវិទ្យា ក្នុងការរក្សាបាននូវស្តង់ដារជាតិនិងអន្តរជាតិ។

៣. ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ក្នុងការចរចារជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍នានា ក្នុងការស្វែងរកនូវកិច្ចសហប្រតិបត្តិការ ការកៀងគររកនូវជំនួយសំរាប់ជួយដល់ការធ្វើសកម្មភាពការវិនិយោគឃ្លាំង ម៉ាស៊ីនសម្ងួត និងការវត្តរបស់រោងម៉ាស៊ីន ដើម្បីជួយសម្រួលដល់រោងម៉ាស៊ីន សហគមន៍កសិករ និងប្រជាជន ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ និងសន្តិសុខស្បៀងក្នុងប្រទេស។

៤. ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ធ្វើការតាមដានផលលំបាកនានា និងទិន្នន័យរបស់រោងម៉ាស៊ីនរបស់សមាជិកពាក់ព័ន្ធទៅនឹងការកិនកែច្នៃ និងការស្តុកទុក ហើយធ្វើរបាយណ៍ទៅក្រុមប្រឹក្សាភិបាសហព័ន្ធដើម្បីផ្តល់អនុសាសន៍ដោះស្រាយ។

៥. គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ ជាទៀងទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណី ការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលអនុញ្ញាត្តិសំរេចជាមុន ។

៦. ក្នុងករណីចំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និង ទីប្រឹក្សាសំរាប់គណៈកម្មាធិការទៅក្រុមប្រឹក្សាភិបាលសហព័ន្ធ ។

**ប្រការ៣.**

កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន ដោយត្រូវមានការចូលរួមពីសមាជិក ៥០%+១ នៃសមាសភាពសរុប និងអាចអនុម័តសម្រេចបាន ត្រូវមានសំលេង ២ភាគ៣ នៃសមាសភាពចូលរួម។

**ប្រការ៤.**

ក្រុមប្រឹក្សាភិបាល លេខាធិការដ្ឋាន ការិយាល័យសាខាតាមខេត្ត និង សាម៉ីខ្លួន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៕

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦

**ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

**ចម្លងជូន៖**

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ធនាគារអភិវឌ្ឍន៍ជនបទ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានកសិកម្ម
- លេខាធិការដ្ឋានច្រកចេញចូលតែមួយ
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

- 2-

សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខៈ ១៥៦ /១៦ ស.អ.ក

**ប្រកាស**

**ស្តីពី**

**ការកែសម្រួលសមាសភាពគណៈកម្មាធិការទទួលបន្ទុកការងារសហគមន៍កសិករ**
**និងជំរុញផលិតកម្មស្រូវពូជ**

( Executive Committee for Farming and Seed Production )

**យោង៖** - អនុក្រឹត្យស្តីពីការទទួលស្គាល់ការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា លេខ២២៨ អនក្រ.បក ចុះថ្ងៃទី៨ សីហា ឆ្នាំ២០១៤
- បានឃើញលក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាទកាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥
- យោងតាមការចាំបាច់របស់សហព័ន្ធស្រូវអង្ករកម្ពុជា

**សម្រេច**

**ប្រការ១.**

ការកែសម្រួលសមាសភាពគណៈកម្មាធិការទទួលបន្ទុកដោះស្រាយការងារសហគមន៍កសិករ និងជំរុញផលិតកម្មស្រូវពូជ (Farming &Seed Production Executive Committee) ដែលមានសមាសភាពចំនួន១១រូប និង លេខាធិការ ០១រូប ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក ស៊ី វ៉ាន់នី | អនុប្រធានសហព័ន្ធ និងជាប្រធានសហគមន៍ FNN | ប្រធាន |
| ២. លោក តាំង ផុងធី | នាយកក្រុមហ៊ុនសម្បត្តិវឌ្ឍនៈ | អនុប្រធាន |
| ៣. លោក សាក់ ជឿន | ប្រធានក្រុមហ៊ុន AQUIP Seed | អនុប្រធាន |
| ៤. លោកស្រី អន សារុណា | តំណាងសហគមន៍កសិករ CFAP | អនុប្រធាន |
| ៥. លោក សំអាត វាសនា | តំណាងសហគមន៍កសិករ FCFD | អនុប្រធាន |
| ៦. លោក ឈីន ឆារ៉ុម | ក្រុមហ៊ុន HCLP | សមាជិក |
| ៧. អ្នកស្រី រ៉ុម សាវឿន | ប្រធានសមាគមន៍ស្ទឹងជីនិត | សមាជិក |
| ៨. លោក គង់ មឿន | ប្រធាន ACUS | សមាជិក |
| ៩. លោក គង់ សាវឿន | ប្រធាន CRAP | សមាជិក |
| ១០. តំណាង | ក្រុមហ៊ុន CDAC | សមាជិក |
| ១១. លោក ហេង រតនា | តំណាងក្រុមហ៊ុនហេង រតនា | សមាជិក |
| លោក ផង់ ផល្លា | ប្រធានផ្នែកការងារកសិករនិងផលិតកម្មពូជ នៃ ស.អ.ក | លេខាធិការ |

**ប្រការ២.**

គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្តលើកិច្ចការនៅក្នុងក្របខ័ណ្ឌ ដែលមានចែងនៅក្នុងផែនការសកម្មភាពដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលសហព័ន្ធ តាមការងារដូចខាងក្រោម៖


#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia • Tel: +855 23 722 250 • Mail: info@crf.org.kh

1. ផ្តល់មុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ជម្រុញការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់សហព័ន្ធ ដោយកំណត់លើប្រភេទពូជស្រូវដែលឆ្លើយតបតាមតម្រូវការទីផ្សារនិងម៉ាកយីហោអង្ករកម្ពុជា កំណត់ដី ថ្នាំសំលាប់សត្វល្អិត និងការងារក្បៀតសាស្ត្រ ជាដើម។
2. ផ្តល់មុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ក្នុងការជួយសម្របសម្រួលរៀបចំ និងសហការជាមួយក្រុមការងារតំបន់ទាំង៥ របស់សហព័ន្ធស្រូវអង្ករកម្ពុជា។
3. ផ្តល់មុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ក្នុងការចរចារជាមួយក្រសួង-ស្ថាប័នជាតិ អន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍនានា ក្នុងការស្វែងរកនូវកិច្ចសហប្រតិបត្តិការ ការកៀងគររកនូវជំនួយសំរាប់ជួយដល់ការធ្វើសកម្មភាពការជំរុញ ការផ្សព្វផ្សាយ ការងារកិច្ចសន្យាកសិកម្ម (Contract Farming) ប្រព័ន្ធទិញលក់បែបទំនើប(Trading Platform) ការងារអប់រំ ការចងក្រងសហគមន៍កសិករ និងកម្មវិធីនានាដែលជួយដល់និរន្តរភាពលើការអនុវត្តការដាំដុះ បច្ចេកទេសដាំដុះរបស់ប្រជាជន ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ និងសន្តិសុខស្បៀងក្នុងប្រទេស។
4. សម្របសម្រួលការអនុវត្តជាក់ស្តែងជាមួយសហគមន៍កសិករ ដូចជា ជំរុញផ្សព្វផ្សាយពូជ ជី ថ្នាំ បច្ចេកទេសការដាំដុះ និងការទុកដាក់ពេលប្រមូលផល។
5. គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ ជាទៀងទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណី ការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលអនុញ្ញាតសំរេចជាមុន។
6. ក្នុងករណីចំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និងទីប្រឹក្សាសំរាប់គណៈកម្មាធិការ ទៅក្រុមប្រឹក្សាភិបាលសហព័ន្ធ។

**ប្រការ៣.**

កិច្ចប្រជុំអាចប្រព្រឹត្តទៅបានដោយត្រូវមានការចូលរួមពីសមាជិក ៥០%+១ នៃសមាសភាពសរុប និងអាចអនុម័តសម្រេចបាន ត្រូវមានសំលេង ២ភាគ៣ នៃសមាសភាពចូលរួម។

**ប្រការ៤.**

ក្រុមប្រឹក្សាភិបាល លេខាធិការដ្ឋាន ការិយាល័យសាខាតាមខេត្ត និងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦

**ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា**

**ប្រធាន**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

**ចម្លងជូន៖**

- ឧទ្ទកាលេីយ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឧទ្ទកាលេីយ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ឧទ្ទកាលេីយ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ឧទ្ទកាលេីយ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានកសិកម្ម
- លេខាធិការដ្ឋានច្រកចេញចូលតែមួយ
- ធនាគារអភិវឌ្ឍន៍ជនបទ
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

សហព័ន្ធ ស្រូវ អង្ករ កម្ពុជា

Cambodia Rice Federation

លេខ:១៥៥/១៦ ស.អ.ក

## ប្រកាស
## ស្តីពី
## ការកែសម្រួលសមាសភាព គណៈកម្មាធិការទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ និងដំណោះស្រាយឥណទាន

(Finance and Banking Solution Executive Committee)

**យោង៖** - អនុក្រឹត្យ ស្តីពី ការទទួលស្គាល់ការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា លេខ២២៨ អនក្រ.បក ចុះថ្ងៃទី៨ សីហា ឆ្នាំ២០១៤

- បានឃើញលក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាតកាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥
- យោងតាមការចាំបាច់របស់សហព័ន្ធស្រូវអង្ករកម្ពុជា

## សម្រេច

**ប្រការ១.**

កែសម្រួលគណៈកម្មាធិការ ទទួលបន្ទុកការកែទម្រង់ឲ្យមានការងារសម្របសម្រួលឥណទានជាមួយធនាគារ (Finance and Banking Solution Executive Committee) ដែលមានសមាសភាពចំនួន ១០រូប និងលេខាធិការ ០១រូប ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឧកញ៉ា ហ៊ុន ឡាក់ | ក្រុមហ៊ុន Mekong Oryza Trading Co. Ltd | ប្រធាន |
| ២. ឧកញ៉ា ភូ ពុយ | ក្រុមហ៊ុន Baitang (Kampuchea) Plc. | អនុប្រធាន |
| ៣. ឧកញ៉ា ច្រាយ សុន | ក្រុមហ៊ុនCapital Food Investment Import Export Co.,Ltd | អនុប្រធាន |
| ៤. លោក ឈុន ធំ | រោងម៉ាស៊ីនកិនស្រូវ ឈុនធំ | សមាជិក |
| ៥. លោក ឈិត ប៊ុនថន | រោងម៉ាស៊ីនកិនស្រូវ ឈិត ប៊ុនថន | សមាជិក |
| ៦. លោក ឡាយ ឈុនហួ | ក្រុមហ៊ុន City Rice Import Export Co. Ltd | សមាជិក |
| ៧. តំណាងធនាគារ ANZ Royal Bank | | សមាជិក |
| ៨. តំណាងធនាគារ Canadia Bank | | សមាជិក |
| ៩. តំណាងធនាគារ Acleda Bank | | សមាជិក |
| ១០. តំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | Idemitsu Saison Microfinance(Cambodia) Plc | សមាជិក |
| លោកបណ្ឌិត ហ៊ីន ធារ៉ា | ប្រធានផ្នែកហិរញ្ញវត្ថុនៃសហព័ន្ធស្រូវអង្ករកម្ពុជា | លេខាធិការ |

**ប្រការ២.**

គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្តលើកិច្ចការនៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងផែនការសកម្មភាព ដែលបានអនុម័តដោយ ក្រុមប្រឹក្សាភិបាលក្នុងតួនាទីដូចខាងក្រោម៖

១- ផ្តួចផ្តើមឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលចរចារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា



#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia - Tel: +855 23 722 250 - Mail: info@crf.org.kh

ធនាគារអភិវឌ្ឍន៍ជនបទ ធនាគារពាណិជ្ជ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្នុងការស្វែងរកយន្តការដោះស្រាយលើមធ្យោបាយផ្តល់ឥណទានដែលមានការប្រាក់ទាបជាងមុន ងាយស្រួល និងលក្ខណៈសម្បទានជាងមុន។

២- សិក្សាស្វែងរកប្រភពឥណទានដែលមានការប្រាក់ទាប រៀបចំនូវយុទ្ធសាស្ត្រ និងគំរូឥណទាន(Financing Model) ដែលសមស្របសម្រាប់ជាជម្រើសល្អប្រសើរមួយក្នុងការផ្តល់ឥណទានដល់ប្រជាកសិករ រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករកម្ពុជា។

៣- គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ជាទៀងទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណីការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលអនុញ្ញាតិសំរេចជាមុន។

៤- ក្នុងករណីចាំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និង ទីប្រឹក្សាសំរាប់គណៈកម្មាធិការនេះ។

**ប្រការ៣.**

កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន ដោយត្រូវមានការចូលរួមពីសមាជិកយ៉ាងតិច ៥១% នៃសមាសភាពសរុប និងអាចអនុម័តសម្រេចបាន ក៏ត្រូវមានសំលេង ២ភាគ៣ នៃសមាសភាពចូលរួម។

**ប្រការ៤.**

ក្រុមប្រឹក្សាភិបាល លេខាធិការដ្ឋាន ការិយាល័យសាខាតាមខេត្ត និង សាមីខ្លួន ត្រូវអនុវត្តប្រកាស នេះចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦

**ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា**

**ប្រធាន**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

**<u>ចម្លងជូន៖</u>**

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានកាំកុងត្រូល
- លេខាធិការដ្ឋានច្រកចេញចូលតែមួយ
- ធនាគារអភិវឌ្ឍន៍ជនបទ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

# គណៈកម្មាធិការប្រតិបត្តិកាត់បន្ថយថ្លៃដើម

## Cost Competitivenest Executive Committee

សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខៈ ១៥៧/១៦ ស.អ.ក

**ប្រកាស**

**ស្តីពី**

ការកែសម្រួលសមាសភាពគណៈកម្មាធិការ ទទួលបន្ទុកលើការកែទម្រង់ថ្លៃដើម
(Cost Competiveness Executive Committee)

**យោង៖** - អនុក្រឹត្យស្តីពីការទទួលស្គាល់ការបង្កើតសហព័ន្ធស្រូវអង្ករកម្ពុជា លេខ២២៨ អនក្រ.បក ចុះថ្ងៃទី៨ សីហា ឆ្នាំ២០១៤
- បានឃើញលក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាតកាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥
- យោងតាមការចាំបាច់របស់សហព័ន្ធស្រូវអង្ករកម្ពុជា

**សម្រេច**

**ប្រការ១.**

ការកែសម្រួលសមាសភាពគណៈកម្មាធិការទទួលបន្ទុកលើការកែទម្រង់ឲ្យមានការប្រកួតប្រជែងថ្លៃដើម (Cost Competiveness Executive Committee) ដែលមានសមាសភាពចំនួន ០៩រូប និងលេខាធិការ ០១រូប ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឧកញ៉ា វង្ស ប៊ុនហេង | ប្រធានក្រុមហ៊ុន VBH | ប្រធាន |
| ២. លោក យ៉ន សុវណ្ណ | ប្រធានក្រុមហ៊ុន Bayon Cereal | អនុប្រធាន |
| ៣. លោក សុខ វង់ | តំណាងក្រុមហ៊ុនអេងឌីប៉ូអភិវឌ្ឍន៍ | អនុប្រធាន |
| ៤. លោក វង្ស ជាឈៀង | រោងម៉ាស៊ីនកិនស្រូវ ហេង សម្បត្តិ | សមាជិក |
| ៥. លោក ត្រាញ់ ញ៉ | រោងម៉ាស៊ីនកិនស្រូវ មួយ លាង | សមាជិក |
| ៦. លោក ង៉ាង សុផន | រោងម៉ាស៊ីនកិនស្រូវ មុំសុផល | សមាជិក |
| ៧. លោក ស៊ឹម សុភា | ក្រុមហ៊ុន Crystal Rice | សមាជិក |
| ៨. លោក អ៊ឹង ពុទ្ធឫទ្ធី | ហាយលេវល ឡូជីស្ទិក | សមាជិក |
| ៩. តំណាងក្រុមហ៊ុនដំរះឯកសារ (Frieght Fowarder) | | សមាជិក |
| មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា | | អ្នកសម្របសម្រួល |

**ប្រការ២.**

គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្តលើកិច្ចការ នៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងផែនការសកម្មភាព ដែលបានអនុម័តដោយ ក្រុមប្រឹក្សាភិបាលតាមការងារដូចខាងក្រោម៖

1. ជូសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាល ដើម្បីសិក្សាលើថ្លៃដើមនៃការដាំដុះ ការផលិត ការកិនកែច្នៃ ការវេចខ្ចប់ ការដឹកជញ្ជូន ការធ្វើឯកសារនាំចេញអង្ករកម្ពុជា រួចស្នើរកដំណោះស្រាយរួមជាមួយរាជរដ្ឋាភិបាល សេវាករ វិស័យឯកជន ក្នុងការជម្រុញឲ្យការកាត់បន្ថយថ្លៃដើមផលិតកម្ម ការកែច្នៃ និងការនាំចេញ ទៅកាន់ទីផ្សារអន្តរជាតិឲ្យកាន់តែមានភាពប្រកួតប្រជែងប្រសើរជាងមុន ។
2. ជូសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាល សហព័ន្ធ ក្នុងការចរចារ ស្វែងរកដំណោះស្រាយ ជាមួយក្រសួង អាជ្ញាធរ អង្គភាពស្វយ័តនានារបស់រដ្ឋ និងបណ្តាក្រុមហ៊ុនផ្តល់សេវានានា ដែលពាក់ព័ន្ធដល់ដំណើរការ ផលិតកម្ម ការកិនកែច្នៃ និងការនាំចេញអង្ករបស់កម្ពុជា ។


#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia • Tel: +855 23 722 250 • Mail: info@crf.org.kh

3. ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាល សហព័ន្ធ ក្នុងការចរចារជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍នានា ក្នុងការស្វែងរកនូវ កិច្ចសហប្រតិបត្តិការ ការកៀងគរ រកនូវជំនួយសំរាប់ជួយដល់ការធ្វើសកម្មភាពការជម្រុញឲ្យមានការវិនិយោគ ជួយឧបត្ថម្ភដល់វិស័យស្រូវអង្ករកម្ពុជា ។
4. គណៈគម្មាធិការត្រូវធ្វើរបាយការណ៍ ជាទៀងទាត់ជូនដល់ក្រុមប្រឹក្សាភិបាល សហព័ន្ធស្រូវអង្ករកម្ពុជា ។ ចំពោះករណី ការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលអនុញ្ញាត្តិសំរេចជាមុន ។
5. ក្នុងករណីចំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និង ទីប្រឹក្សាសំរាប់គណៈកម្មាធិការនេះ ។

**ប្រការ៣.**

កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន ដោយត្រូវមានការចូលរួមពីសមាជិកយ៉ាងតិច ៥០%+១ នៃសមាសភាពសរុប និងអាចអនុម័តសម្រេចបាន ក៏ត្រូវមានសំលេង២ភាគ៣ នៃសមាសភាពចូលរួម។

**ប្រការ៤.**

ក្រុមប្រឹក្សាភិបាល លេខាធិការដ្ឋាន ការិយាល័យសាខាតាមខេត្ត និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦

**ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា**

**ប្រធាន**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

បម្លងជូន៖

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានកសិកម្ម
- លេខាធិការដ្ឋានច្រកចេញចូលតែមួយ
- ធនាគារអភិវឌ្ឍន៍ជនបទ
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

# គណៈកម្មាធិការប្រតិបត្តិក្រមសីលធម៌និងវិន័យ

## Code Conduct and Ethic Executive Committee

សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខៈ ១៥៩/១៦ ស.អ.ក

**ប្រកាស**

**ស្តីពី**

**ការកែសម្រួលសមាសភាពគណៈកម្មាធិការទទួលបន្ទុកការងារក្រមសីលធម៌ និងវិន័យ**

(Code of Conduct and Ethics Executive Committee)

**យោង៖** - អនុក្រឹត្យ ស្តីពី "ការទទួលស្គាល់សហព័ន្ធស្រូវអង្ករកម្ពុជា" លេខ ២២៨ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤
- លក្ខន្តិកៈសហព័ន្ធស្រូវអង្ករកម្ពុជា អនុម័តដោយអង្គមហាសន្និបាត កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥
- យោងតាមការចាំបាច់ របស់សហព័ន្ធស្រូវអង្ករកម្ពុជា។

**សម្រេច**

**ប្រការ១.**

ការកែសម្រួលសមាសភាពគណៈកម្មាធិការទទួលបន្ទុកការងារវិន័យនិងក្រមសីលធម៌ (Code of Conduct and Ethics Executive Committee) ដែលមានសមាសភាពចំនួន០៧រូប និងលេខាធិការ ០១រូប ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក ហេង ផេង | ប្រធានរោងម៉ាស៊ីន សៀ ហេង | ប្រធាន |
| ២. លោក ចាន់ ពេជ្រ | អ្នកគ្រប់គ្រងក្រុមហ៊ុន SOA | អនុប្រធាន |
| ៣. លោក ហ៊ី ហ៊ត | រោងម៉ាស៊ីន ណមស្រ៊ឹម | អនុប្រធាន |
| ៤. លោក ម៉ាន់ រ៉េងអាន | រោងម៉ាស៊ីនកិនស្រូវ Yin Mann | សមាជិក |
| ៥. លោក រិទ្ធ សីហា | នាយកប្រតិបត្តិក្រុមហ៊ុន Mekong Agro | សមាជិក |
| ៦. លោក អែល រ៉ូសាត | តំណាងក្រុមហ៊ុន Sok Keo | សមាជិក |
| ៧. លោក លឹម ពិសាន | តំណាងក្រុមហ៊ុន Golden Duan Keo | សមាជិក |
| មន្ត្រីសហព័ន្ធស្រូវអង្ករកម្ពុជា | | លេខាធិការ |

**ប្រការ២.**

គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្ត លើកិច្ចការនៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងផែនការសកម្មភាព ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលសហព័ន្ធ តាមការងារដូចខាងក្រោម៖

1. ជូសមុខអោយសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ធ្វើការរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាព និងអនុវត្តវិធានការជម្រុញការទប់ស្កាត់ការនាំអង្ករពីប្រទេសជិតខាង ដែលបាននាំចូលមិនស្របច្បាប់ ក្នុងការផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក និងកែច្នៃដើម្បីនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។
2. ទទួលបន្ទុកការងារវិន័យនិងអធិការកិច្ចនៃក្រមសីលធម៌ ដោយជំរុញអោយគ្រប់សមាជិកទាំងអស់អនុវត្ត និងគោរពតាមក្របខណ្ឌក្រមសីលធម៌និងគោលការណ៍នៃការងារ រួមមាន សុចរិតភាព តម្លាភាព ការអនុវត្តជាក់ស្តែង ភាពលឿន សាមត្ថិភាព និងរក្សាអោយបាននូវក្រមសីលធម៌ខ្ពស់បំផុតក្នុងសកម្មភាពជំនួញជាមួយភាគីពាក់ព័ន្ធទាំងអស់។
3. កំណត់ពីផែនការ និងនីតិវិធីក្នុងការដាក់ពិន័យចំពោះសមាជិកណាដែលមិនបានអនុវត្តតាមក្រមសីលធម៌ បទបញ្ជាផ្ទៃក្នុង

- 1 -

#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia • Tel: +855 23 722 250 • Mail: info@crf.org.kh

និងលក្ខន្តិកៈរបស់សហព័ន្ធស្រូវអង្ករកម្ពុជា។

4. ជួសមុខអោយសហព័ន្ធ ក្នុងការសហការជាមួយក្រសួងពាក់ព័ន្ធ ស្ថាប័នជាតិ ភ្នាក់ងារពាក់ព័ន្ធនានា ក្នុងការស្វែងរកនូវវិធានការទប់ស្កាត់និងការដាក់ពិន័យដល់អ្នកដែលនាំអង្ករពីប្រទេសជិតមិនត្រឹមត្រូវតាមច្បាប់ និងការធ្វើសកម្មភាពជំរុញការផ្សព្វផ្សាយ ការងារអប់រំពន្យល់ដល់អ្នកពាក់ព័ន្ធអំពីផលប៉ះពាល់ក្នុងការនាំអង្ករពីប្រទេសជិតខាងទាំងការប្រើប្រាស់ក្នុងស្រុក និងកែឆ្នៃដើម្បីនាំចេញបន្តទៅកាន់ទីផ្សារអន្តរជាតិ ក្រោមរូបភាពម៉ាកអង្ករកម្ពុជា។
5. គណៈកម្មាធិការ ត្រូវធ្វើរបាយការណ៍ទៀតទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណីការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលឲ្យអនុញ្ញាតសម្រេចជាមុនសិន។
6. ក្នុងករណីចាំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និងទីប្រឹក្សាសំរាប់គណៈកម្មាធិការ ទៅក្រុមប្រឹក្សាភិបាលសហព័ន្ធ។

**ប្រការ៣.**

កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន ដោយត្រូវមានការចូលរួមពីសមាជិក ២ភាគ៣ នៃសមាសភាពសរុប និងអាចអនុម័តសម្រេចបានក៏ត្រូវមានសំលេង ២ភាគ៣ នៃសមាសភាពចូលរួម។

**ប្រការ៤.** ក្រុមប្រឹក្សាភិបាល លេខាធិការដ្ឋាន ការិយាល័យសាខាតាមខេត្ត និង សាមីខ្លួន ត្រូវអនុវត្តប្រកាស នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ខែកក្កដា ឆ្នាំ២០១៦

**ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា**

**ប្រធាន**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធិវុធ**

ចម្លងជូន៖

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានកសិកម្ម
- លេខាធិការដ្ឋានច្រកចេញចូលតែមួយ
- ធនាគារអភិវឌ្ឍន៍ជនបទ
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

# 2. សកម្មភាពការងារនិងសមិទ្ធផលសំខាន់ៗ

## 2.1 គណៈកម្មាធិការប្រតិបត្តិផ្សព្វផ្សាយទីផ្សារនិងការនាំចេញ ( Executive Committee of Global Market Promotion )



ឯកឧត្តម សុខ ពុទ្ធិវុធ

សមាសភាពនៃគណៈកម្មាធិការជំរុញនិងផ្សព្វផ្សាយទីផ្សារ ត្រូវបានបង្កើតឡើងនៅ **ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦** តាមរយៈប្រកាសលេខ១៥៨/១៦ ដោយមានសមាជិកចំនួន១១រូប ដែលមានសមាសភាពមកពីរោងម៉ាស៊ីន ក្រុមហ៊ុនកិនកែច្នៃ និងអ្នកនាំចេញអង្ករ។ គណៈកម្មាធិការនេះមានភារកិច្ចអនុវត្តការងារដូចខាងក្រោម៖

- បង្កើនប្រសិទ្ធភាព និងការនាំចេញអង្កររបស់កម្ពុជាទាំងទីផ្សារដែលកំពុងមានស្រាប់ និងស្វែងរកទីផ្សារថ្មីៗបន្ថែមទៀត
- ពង្រីកទំនាក់ទំនងជាមួយបណ្តាប្រទេសនាំចូលនិងនាំចេញអង្ករ និងសមាគមស្រូវអង្ករ ព្រមទាំងក្រុមហ៊ុនស្រូវអង្ករធំៗនៅបរទេស
- រៀបចំបង្កើត និងការពារម៉ាកអង្ករកម្ពុជា ដើម្បីបង្កើនទំនុកចិត្តនិងតម្លៃអង្ករកម្ពុជានៅឆាកអន្តរជាតិ
- ចូលរួមសហការជាមួយរាជរដ្ឋាភិបាល ដឹកនាំផ្សព្វផ្សាយពីអង្ករកម្ពុជា និងចូលរួមពិព័រណ៍អន្តរជាតិ
- សហការជាមួយក្រុមហ៊ុនព្រ្គីនជ្រេត នៃក្រសួងពាណិជ្ជកម្ម ដើម្បីអនុវត្តលើកូតាអង្ករដែលកម្ពុជាទទួលបានឱ្យមានប្រសិទ្ធភាពខ្ពស់
- សម្របសម្រួលនិងរៀបចំយុទ្ធសាស្ត្រនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិជាមួយសមាជិកនិងភាគីពាក់ព័ន្ធ។ល។



**សមិទ្ធផលដែលគណៈកម្មាធិការសម្រេចបាន ៖**

### 2.1.1 កម្ពុជាឈ្នះពានរង្វាន់អង្ករល្អបំផុតពិភពលោកចំនួន៤លើក

ក្រោយពីរាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវគោលនយោបាយស្តីពី "**ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ**" នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០ យើងសង្កេតឃើញថា បរិមាណនៃការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិបានកើនឡើងជាលំដាប់ ហើយអង្ករក្រអូបប្រណីតរបស់កម្ពុជាបានទទួលពានរង្វាន់អង្ករដែលមានគុណភាពល្អជាងគេលើពិភពលោក ចំនួន៤លើក គឺឆ្នាំ២០១២ ២០១៣ ២០១៤ និងឆ្នាំ២០១៨ ក្នុងសន្និសីទស្រូវអង្ករពិភពលោកដែលរៀបចំឡើងដោយ The Rice Trader (TRT)។




ពានរង្វាន់អង្ករល្អបំផុតពិភពលោក

នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២ ជាលើកទី១ និងជាប្រវត្តិសាស្ត្រសម្រាប់វិស័យស្រូវអង្ករកម្ពុជា ដែលអង្ករក្រអូបប្រណីតរបស់កម្ពុជាទទួលបានពានរង្វាន់ជាអង្ករមានគុណភាពល្អជាងគេលើពិភពលោកនៅបាលី ប្រទេសឥណ្ឌូនេស៊ី នៅ ក្នុងសន្និសីទស្រូវអង្ករពិភពលោកលើកទី៤។ បន្ទាប់មកនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ កម្ពុជាបានបន្តគ្រងតំណែងជាអង្ករមានគុណភាពល្អជាងគេលើពិភពលោកជាលើកទី២ ក្នុងសន្និសីទស្រូវអង្ករពិភពលោកលើកទី៥ នៅទីក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន។ នៅខែវិច្ឆិកាឆ្នាំ២០១៤ អង្ករក្រអូបប្រណីតរបស់កម្ពុជាទទួលបានពានរង្វាន់ជាអង្ករមានគុណភាពល្អជាងគេលើពិភពលោកជាលើកទី៣ នៅរាជធានីភ្នំពេញ។ ជាថ្មីម្តងទៀត អង្ករក្រអូបប្រណីតរបស់កម្ពុជាបាន ដណ្តើមយកពានរង្វាន់ជាអង្ករមានគុណភាពល្អជាងគេលើពិភពលោកជាលើកទី៤ ក្នុងសន្និសីទស្រូវអង្ករពិភពលោកលើកទី១០ នៅប្រទេសវៀតណាម។

ភាពជោគជ័យទាំងនេះ កើតឡើងដោយសារការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាល ពិសេសក្រោមការដឹកនាំចូលរួមរបស់ឯកឧត្តម សុខ ពុទ្ធិវុធប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងសមាជិកសមាជិកា ក្នុងការបន្តកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍និងភាគីពាក់ព័ន្ធនានា ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែងតាមរយៈការពង្រឹងស្តង់ដារអនាម័យ គុណភាពអង្ករ កាត់បន្ថយថ្លៃដើម ជាពិសេសគឺការជំរុញលើកទឹកចិត្តការប្រើប្រាស់ពូជសុទ្ធក្នុងការដាំដុះ ជាដើម។



កម្មវិធីអបអរសាទរ ការឈ្នះគុណភាពល្អជាងគេលើពិភពលោកជាលើកទី ៤ នៅសណ្ឋាគារសុខា ភ្នំពេញ កាលពីខែកុម្ភៈ ឆ្នាំ២០១៩

## 2.1.2 ការបង្កើតនិងដាក់សម្ពោធម៉ាកអង្ករជាតិ «ម្លិះអង្គរ (MALYS ANGKOR)» អង្ករក្រអូបប្រណីត

ម៉ាកអង្ករនេះ ត្រូវបានប្រឹក្សាយោបល់និងពិភាក្សាទាំងផ្នែកច្បាប់ជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាច្រើនលើកអំពីការប្រើឈ្មោះ រូបភាព និងការប្រើប្រាស់ រហូតទទួលបានការឯកភាពគ្រប់ភាគី ត្រូវប្រើពេលវេលាជាង៣ឆ្នាំទើបបង្កើតម៉ាកវិញ្ញាតកម្មនេះចប់។



ការសម្ពោធជាផ្លូវការក្នុងវេទិកាស្រូវអង្ករកម្ពុជាកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨

"**ម្លិះអង្គរ**" បានទទួលការចុះបញ្ជីពីក្រសួងពាណិជ្ជកម្មកម្ពុជា និងដាក់សម្ពោធជាផ្លូវការក្នុងវេទិកាស្រូវអង្ករកម្ពុជាកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សហព័ន្ធស្រូវអង្ករកម្ពុជា បាននិងកំពុងរៀបចំធ្វើការផ្សព្វផ្សាយ និងចុះឈ្មោះសម្រាប់ជ្រើសរើសក្រុមហ៊ុនត្រួតពិនិត្យគុណភាពដើម្បីធ្វើជាអ្នកត្រួតពិនិត្យគុណភាពនិងស្តង់ដារអង្ករដែលនឹងប្រើប្រាស់ម៉ាកសញ្ញានេះ។ជាមួយគ្នានេះដែរ សហព័ន្ធស្រូវអង្ករកម្ពុជា ក៏កំពុងរៀបចំផ្សព្វផ្សាយពន្យល់ និងបង្ហាញដល់រោងម៉ាស៊ីនកិនកែច្នៃនិងនាំចេញអង្ករ ដើម្បីរៀបចំខ្លួននិងដាក់ពាក្យប្រើប្រាស់ម៉ាកអង្ករនេះផងដែរ។



សិក្ខាសិលាស្តីពីនីតិវិធីនៃការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម ម្លិះអង្គរ» កាលពីខែមេសា ឆ្នាំ២០១៨

បច្ចុប្បន្ន ម៉ាកវិញ្ញាតកម្មនេះបាននិងកំពុងបន្តចុះបញ្ជីនៅលើទីផ្សារអន្តរជាតិប្រមាណជាង៥០ប្រទេស និងកំពុងបន្តការស្វែងរកការគាំទ្រជំនួយផ្នែកហិរញ្ញវត្ថុពីភាគីពាក់ព័ន្ធសម្រាប់ជួលមេធាវីនិងអ្នកជំនាញការជួយរៀបចំឯកសារក្នុងការចុះបញ្ជីឱ្យបានរួចរាល់នៅទីផ្សារអន្តរជាតិ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយនិងមានប្រសិទ្ធភាព ដោយរំពឹងថានឹងបញ្ចប់ការចុះបញ្ជីនៅលើទីផ្សារអន្តរជាតិនៅឆ្នាំ២០២០ ខាងមុខនេះ។

## 2.1.3 រៀបចំវេទិកាស្រូវអង្ករថ្នាក់ជាតិនិងអន្តរជាតិ និងពិធីបុណ្យស្រូវអង្ករកម្ពុជាជាប្រចាំ







សហព័ន្ធស្រូវអង្ករកម្ពុជាបានរៀបចំវេទិកាស្រូវអង្ករកម្ពុជាថ្នាក់ជាតិនិងអន្តរជាតិចំនួន៣លើករួចមកហើយ ដោយ មានវត្តមានដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជានិងតំណាងមន្ត្រីជាន់ខ្ពស់បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់នៅក្នុងកម្មវិធីនោះ។ សម្រាប់សមាសភាពចូលរួមមកពីសមាជិកសមាជិកា ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន វិទ្យាស្ថានស្រាវជ្រាវ និងអ្នកជំនាញពីក្នុងនិងក្រៅប្រទេស។ វេទិកានេះ មានគោលបំណងផ្លាស់ប្តូរយោបល់និងបទពិសោធន៍រវាងគ្នាជាមួយអ្នកជំនាញ និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងវិស័យស្រូវអង្ករ សំដៅស្វែងរកដំណោះស្រាយនានាដល់បញ្ហាប្រឈម ពិសេសការជំរុញឱ្យមានការធ្វើទំនើបកម្មវិស័យស្រូវអង្ករនៅកម្ពុជាតាមទស្សនវិស័យរបស់ឯកឧត្តម សុខ ពុទ្ធិវុធ ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកសមាជិកាសហព័ន្ធស្រូវអង្ករកម្ពុជា។

សហព័ន្ធស្រូវអង្ករកម្ពុជា ក៏បានទាញយកនូវលទ្ធផលចេញពីវេទិកាដ៏មានសារៈសំខាន់នោះមកចងក្រងបញ្ចូល ក្នុងផែនការយុទ្ធសាស្រ្តនិងផែនការសកម្មភាពរបស់ខ្លួន ព្រមទាំងបានយកជាធាតុចូលសំខាន់ៗស្នើដាក់បញ្ចូលក្នុងសេចក្តីព្រាងគោលនយោបាយស្រូវអង្ករកម្ពុជាថ្មី ដែលបាននិងកំពុងរៀបចំឡើងដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិនិងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា។

វេទិកានេះបានបង្ហាញពីនិន្នាការទីផ្សារអង្ករនៅលើទីផ្សារអន្តរជាតិ ព្រមទាំងបានបង្ហាញពីការធ្វើទំនើបកម្មស្រូវអង្ករកម្ពុជា (Cambodia Rice Modernization) នៅក្នុងខ្សែចង្វាក់ផលិតកម្មស្រូវអង្ករ ការបង្ហាញពីស្តង់ដារ ការកាត់បន្ថយថ្លៃដើម ការបង្កើនផលិតភាព និងជំរុញការនាំចេញឱ្យស្របតាមគោលនយោបាយស្រូវអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា ជាដើម។

ស្របពេលជាមួយគ្នានោះដែរ សហព័ន្ធស្រូវអង្ករកម្ពុជា បានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងទេសចរណ៍ ក្រសួងពាណិជ្ជកម្ម និងដៃគូអភិវឌ្ឍន៍នានា ដូចជា IFC AFD GIZ រៀបចំកម្មវិធីបុណ្យអង្ករកម្ពុជាក្នុងពេលជាមួយគ្នានៃការរៀបចំវេទិកាស្រូវអង្ករកម្ពុជា ដើម្បីរំលឹកពីប្រពៃណីទំនៀមទំលាប់ និងការជួបជុំគ្នាបន្ទាប់ពីរដូវប្រមូលផលស្រូវវស្សារួចរាល់។

ពិសេសនៅក្នុងវេទិកានេះ ជារៀងរាល់លើកយើងតែងតែមានការលើកទឹកចិត្តដល់សមាជិកសមាជិកា និងភាគីពាក់ព័ន្ធ ពិសេសអ្នកកិនកែច្នៃនាំចេញអង្ករ និងសហគមន៍កសិកម្ម ដោយយើងបានរៀបចំឱ្យមានការប្រកួតជ្រើសរើសសហគមន៍និងអ្នកផលិតស្រូវអង្ករថ្នាក់ជាតិ និងផ្តល់រង្វាន់លើកទឹកចិត្តចំពោះជ័យលាភីលើស្រូវនិងអង្ករល្អជាងគេបំផុតប្រចាំប្រទេសកម្ពុជា ដើម្បីយកជ័យលាភីអង្ករល្អបំផុតនោះ ទៅប្រកួតជ្រើសយកពានរង្វាន់អង្ករល្អបំផុតពិភពលោក។

ជាលទ្ធផលនៃការប្រកួតជ្រើសរើសដោយទទួលបានពីការ សម្រិតសម្រាំងនិងការដាក់ពិន្ទុយ៉ាងហ្មត់ចត់ពីគណៈកម្មការ បានបង្ហាញថាក្រុមហ៊ុន រោងម៉ាស៊ីន និងសហគមន៍កសិកម្មបានទទួលជ័យលាភីពីការប្រកួតប្រជែងនេះ រួមមាន៖

## ជ័យលាភីអង្ករល្អបំផុតប្រចាំប្រទេសកម្ពុជាលើកទី៣ ប្រចាំឆ្នាំ២០១៨

ពានរង្វាន់អង្ករក្រអូបប្រណីតល្អបំផុតរបស់កម្ពុជា បានទៅលើក្រុមហ៊ុនស៊ីធីរ៉ាយស៍
ពានរង្វាន់អង្ករក្រអូបធម្មតារបស់កម្ពុជា បានទៅលើរោងម៉ាស៊ីនថ្មគោល
ពានរង្វាន់អង្ករសគ្រាប់វែងរបស់កម្ពុជា បានទៅលើរោងម៉ាស៊ីនវង្សប៊ុនហេង

## ជ័យលាភីអង្ករល្អបំផុតប្រចាំប្រទេសកម្ពុជាលើកទី២ ប្រចាំឆ្នាំ២០១៧

ពានរង្វាន់អង្ករក្រអូបប្រណីតល្អបំផុតរបស់កម្ពុជា បានទៅលើក្រុមហ៊ុនស៊ីធីរ៉ាយ
ពានរង្វាន់អង្ករក្រអូបធម្មតារបស់កម្ពុជា បានទៅលើក្រុមហ៊ុនបាយ័នសីរៀល
ពានរង្វាន់អង្ករសគ្រាប់វែងរបស់កម្ពុជា បានទៅលើរោងម៉ាស៊ីនអប្សរ៉ាយស៍

## ជ័យលាភីអង្ករល្អបំផុតប្រចាំប្រទេសកម្ពុជាលើកទី១ ប្រចាំឆ្នាំ២០១៦

ពានរង្វាន់អង្ករក្រអូបប្រណីតល្អបំផុតរបស់កម្ពុជា បានទៅលើក្រុមហ៊ុនស៊ីធីរ៉ាយស៍
ពានរង្វាន់អង្ករក្រអូបធម្មតារបស់កម្ពុជា បានទៅលើក្រុមហ៊ុនហុងហៀបគ្រុប
ពានរង្វាន់អង្ករចំហុយរបស់កម្ពុជា បានទៅលើក្រុមហ៊ុនស៊ីកនេតឈ័រ អហ្វ អេស៊ា
ពានរង្វាន់អង្ករសគ្រាប់វែងរបស់កម្ពុជា បានទៅលើក្រុមហ៊ុនអេមរ៉ូរ៉ាយស៍











## 2.1.4 ការដឹកនាំសមាជិកចូលរួមផ្សព្វផ្សាយអត្តសញ្ញាណនិងចាប់ដៃគូពាណិជ្ជកម្ម

ដោយមានចក្ខុវិស័យប្រែក្លាយប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសនាំមុខក្នុងការនាំចេញអង្ករមានគុណភាពល្អបំផុត ក្នុងមួយឆ្នាំៗ សហព័ន្ធស្រូវអង្ករកម្ពុជា បានបង្កើនកិច្ចសហប្រតិបត្តិការទាំងថ្នាក់តំបន់ និងអន្តរជាតិដើម្បីពង្រឹងយុទ្ធសាស្ត្រទីផ្សាររបស់ខ្លួន ក្នុងនោះសហព័ន្ធបានរៀបចំបង្កើតឱ្យមានម៉ាកវិញ្ញាតកម្ម«ផ្កាម្លិះអង្ករ» ដែលតំណាងឱ្យអត្តសញ្ញាណនៃអង្ករក្រអូបប្រណីតរបស់កម្ពុជា ដែលជាប់ពានរង្វាន់ជាអង្ករល្អបំផុតលើពិភពលោក និងការផ្សព្វផ្សាយ ការស្វែងរកដៃគូ និងការសម្របសម្រួលពាណិជ្ជកម្មជាមួយបណ្តាប្រទេសយុទ្ធសាស្ត្រក្នុងតំបន់ និងអន្តរជាតិ។

ដោយមានចក្ខុវិស័យវែងឆ្ងាយ សហព័ន្ធបានរៀបចំវេទិកាស្រូវអង្ករជារៀងរាល់២ឆ្នាំម្តង ក្នុងគោលបំណងផ្សព្វផ្សាយពីវឌ្ឍនភាព សក្តានុពល និងកេរ្តិ៍ឈ្មោះវិស័យស្រូវអង្ករកម្ពុជា និងប្រមូលធាតុចូលសំខាន់ៗពីដៃគូពាក់ព័ន្ធ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រដែលឆ្លើយតបតាមបម្រែបម្រួលតម្រូវការទីផ្សារថ្នាក់ជាតិ ក្នុងតំបន់ និងអន្តរជាតិ។

ជាមួយគ្នានេះដែរ សហព័ន្ធបានដឹកនាំសមាជិកសមាជិកាបន្តបង្កើនកិច្ចសហប្រតិបត្តិការទាំងក្នុងតំបន់ និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយពីកេរ្តិ៍ឈ្មោះ សក្តានុពល និងស្វែងរកដៃគូពាណិជ្ជកម្មបន្ថែម ដូចជាការចូលរួមយ៉ាងសកម្មក្នុងកម្មវិធី និងពិព័រណ៍អន្តរជាតិនានា រួមមាន សន្និសីទស្រូវអង្ករអន្តរជាតិ(TRT) ពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ាន ពិព័រណ៍ពាណិជ្ជកម្មសៀងហៃ និងពិព័រណ៍ម្ហូបអាហារប្រចាំតំបន់អាស៊ី និងអឺរ៉ុប ដូចជា THIAFEX, SIAL PARIS ជាដើម។ កាលពីពេលថ្មីនេះ ស្តង់ពិព័រណ៍របស់សហព័ន្ធស្រូវអង្ករកម្ពុជា បានទទួលវិញ្ញាបនបត្រជាស្តង់ដែលល្អជាងគេបំផុត (BEST Exhibitor) នៅក្នុងពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ាន នៅទីក្រុងនានណីង ខេត្តក្វាងស៊ីរបស់ចិន។

ចុងក្រោយនេះ អង្កររបស់កម្ពុជាបានបន្តគ្រងតំណែងជាអង្ករល្អបំផុតលើពិភពលោកលើកទី៤ក្នុងសន្និសីទស្រូវអង្ករអន្តរជាតិ(TRT) លើកទី១០ នៅប្រទេសវៀតណាម កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ បន្ថែមពីនេះ ដោយសារគុណភាព រសជាតិ និងកេរ្តិ៍ឈ្មោះនៃអង្ករកម្ពុជាមានការគាំទ្រខ្ពស់ពីលើឆាកអន្តរជាតិ យើងសង្កេតឃើញថា បរិមាណនៃការនាំចេញអង្ករមានកំណើនខ្ពស់ គឺក្នុងឆ្នាំ២០១២ ការនាំចេញមានចំនួនត្រឹមតែ២០ម៉ឺនតោន និងនៅឆ្នាំ២០១៨ គឺមានចំនួនរហូតដល់៦៣.៥ម៉ឺនតោន ពោលកើនឡើងចំនួន២០០%។ សមិទ្ធផលទាំងនេះ គឺសបញ្ជាក់ពីភាពរីកចម្រើននិងភាពជោគជ័យនៃវិស័យស្រូវអង្កររបស់កម្ពុជានាពេលបច្ចុប្បន្ន។

## 2.1.5 ចូលរួមពង្រឹងនិងពង្រីកការអនុវត្តកូតានាំចេញទៅកាន់ទីផ្សារចិននិងប្រទេសនានា

- **ទីផ្សារប្រទេសចិន៖**



សហព័ន្ធស្រូវអង្ករកម្ពុជា បានសហការជាមួយក្រសួងពាណិជ្ជកម្ម ជាពិសេសតាមរយៈគណៈកម្មាធិការជំរុញនិងផ្សព្វផ្សាយទីផ្សារដែលដឹកនាំដោយ**ឯកឧត្តម សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងក្រុមហ៊ុនហ្គ្រីនត្រេដ ក្នុងការចរចាជាមួយក្រុមហ៊ុនចិនCOFCO និងបណ្តាក្រុមហ៊ុននាំចេញទៅប្រទេសចិន ដើម្បីបង្កើនកិច្ចសហការឲ្យបានស៊ីជម្រៅថែមទៀត និងជំរុញការនាំចេញឱ្យបានច្រើនបំផុត។ ក្នុងឆ្នាំ២០១៧ ការនាំចេញអង្ករទៅប្រទេសចិនសម្រេចបាន១៨ម៉ឺនតោនទ្វេដងធៀបនឹងឆ្នាំកន្លងទៅ និងនៅឆ្នាំ២០១៨សម្រេចបានតែជាង១៧ម៉ឺនតោន។ លើសពីនេះទៅទៀតគណៈកម្មាធិការជំរុញនិងផ្សព្វផ្សាយទីផ្សារ និងក្រុមហ៊ុនហ្គ្រីនត្រេដនឹងបន្តចរចាពិភាក្សាជាមួយភាគីចិនដើម្បីឲ្យការនាំចេញទៅប្រទេសចិនកាន់តែល្អ និងព្យាយាមសម្រេចឲ្យបាន៣០ម៉ឺនតោននាឆ្នាំ២០១៩ និង៤០ម៉ឺនតោនឆ្នាំ២០២០ខាងមុខៗ។

បញ្ហាប្រឈមក្នុងការអនុវត្តកូតានេះ គឺក្រុមហ៊ុនចិនCOFCOជាក្រុមហ៊ុនផ្តាច់មុខក្នុងការអនុវត្តកូតានេះ ដូចនេះហើយCOFCOមានអំណាចក្នុងការចរចាតម្លៃជាមួយក្រុមហ៊ុននិងរោងម៉ាស៊ីនទាំងអស់នៅកម្ពុជា ដោយគាត់មិនអនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្ម ឬក្រុមហ៊ុនហ្គ្រីនត្រេដ និងសហព័ន្ធស្រូវអង្ករកម្ពុជាជាអ្នកតំណាងចរចាតម្លៃទិញលក់អង្ករនោះទេ គឺក្រុមហ៊ុននីមួយៗរបស់កម្ពុជាត្រូវផ្តល់តម្លៃផ្ទាល់ដែលធ្វើឱ្យតម្លៃអង្ករកម្ពុជាលក់ចេញមានតម្លៃមិនសូវខ្ពស់ និងបរិមាណមិនបានច្រើន។

ចំពោះបញ្ហាខាងលើនេះថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា និងក្រសួងពាណិជ្ជកម្ម ក៏បានជួបប្រជុំជាមួយលោកស្រី Yang Hong នាយកគ្រប់គ្រងរបស់ក្រុមហ៊ុន COFCO ជាច្រើនលើក ដើម្បីពិភាក្សាស្វែងយល់និងរកដំណោះស្រាយសមស្របឈ្នះៗរវាងភាគីទាំងពីរក្នុងការបង្កើនកិច្ចសហការឱ្យបានស៊ីជម្រៅថែមទៀតក្នុងការនាំចេញអង្ករឱ្យបានតាមចំនួនកូតាដែលបានកំណត់ក្នុងអនុស្សរណៈយោគយល់គ្នានៃឆ្នាំនីមួយៗ។

ស្របពេលជាមួយគ្នានេះ សហព័ន្ធស្រូវអង្ករកម្ពុជាបានព្យាយាមចរចានិងពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន អគ្គនាយកដ្ឋានគយនិងរដ្ឋាករ កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ ជាដើម ក្នុងគោលបំណងដោះស្រាយបញ្ហានានាដែលធ្វើឱ្យមានការរាំងស្ទះដល់ការនាំចេញ និងចូលរួមកាត់បន្ថយថ្លៃដើមក្នុងខ្សែចង្វាក់ផលិតកម្មស្រូវអង្ករកម្ពុជាទាំងមូល។

- **កម្ពុជា នឹងបង្កើនការនាំចេញអង្ករទៅទីផ្សារផ្សេងៗទៀត៖**



ការចុះហត្ថលេខាដើម្បីនាំចេញអង្ករទៅប្រទេសបង់ក្លាដេស

- សហព័ន្ធស្រូវអង្ករកម្ពុជាបានពិភាក្សាជាមួយសមាជិកក្នុងការផ្គត់ផ្គង់អង្ករទៅប្រទេសឥណ្ឌូនេស៊ី
- សហការជាមួយក្រុមហ៊ុនហ្គ្រីនត្រេដក្នុងការបន្តពិភាក្សានិងរៀបចំយន្តការផ្គត់ផ្គង់អង្ករទៅប្រទេសបង់ក្លាដេស ក្នុងការនាំចេញអង្ករចំនួន២៥ម៉ឺនតោនក្នុងមួយឆ្នាំ
- ចូលរួមការដេញថ្លៃផ្គត់ផ្គង់អង្ករដល់ប្រទេសភីលីពីន
- ប្រសិនបើកម្ពុជាអាចសម្រេចបានផែនការនាំចេញបន្ថែមនេះ និងរក្សាបានទីផ្សារដែលកំពុងមានស្រាប់ កម្ពុជានឹងអាចសម្រេចបានគោលនយោបាយនាំចេញអង្ករ១លានតោនក្នុងមួយឆ្នាំៗ។

- **សហព័ន្ធស្រូវអង្ករកម្ពុជា ប្តេជ្ញាបន្តការការពារទីផ្សារសហភាពអឺរ៉ុបជូនសមាជិក៖**



- សហព័ន្ធស្រូវអង្ករកម្ពុជា បានសម្រេចដាក់ពាក្យបណ្តឹងទៅកាន់តុលាការសហភាពអឺរ៉ុប ករណីអឺរ៉ុបដាក់ពន្ធលើការនាំចូលអង្ករពីកម្ពុជា
- បន្តការសហការជាមួយសហគមន៍អឺរ៉ុប ដើម្បីផ្លាស់ប្តូរព័ត៌មានទិន្នន័យ ដើម្បីធានាសុវត្ថិភាពពាណិជ្ជកម្មអង្ករទាំងសងខាង។

- **សម្របសម្រួលសមាជិកចូលរួមពិព័រណ៍ក្នុងនិងក្រៅប្រទេស៖**

- ដឹកនាំសមាជិកចូលរួមសម្រិតសម្រាំង"អង្ករល្អជាងគេបំផុត" យកទៅប្រកួតក្នុងកម្មវិធីវេទិកាស្រូវអង្ករពិភពលោកជារៀងរាល់ឆ្នាំរហូតទទួលបានជ័យជំនះចំនួន៤លើករួចមកហើយ
- សហព័ន្ធស្រូវអង្ករកម្ពុជា រៀបចំដឹកនាំសមាជិកទៅចូលរួមនិងសម្រិតសម្រាំង "អង្ករល្អជាងគេបំផុត" ទៅប្រកួតសារជាថ្មីក្នុងកម្មវិធីវេទិកាស្រូវអង្ករពិភពលោកលើកទី៩ នៅទីក្រុងម៉ាកាវ ប្រទេសចិន
- ដឹកនាំសមាជិកចូលរួមពិព័រណ៍ចិន-អាស៊ានលើកទី១៣ និងលើកទី១៤នៅទីក្រុងណាននីង ខេត្តក្វាងស៊ី ប្រទេសចិន
- សម្របសម្រួលសមាជិកចូលរួមដាក់តាំងពិព័រណ៍ពាណិជ្ជកម្មនានាដែលរៀបចំនៅក្នុងនិងក្រៅប្រទេស។

## 2.1.6 ការប្តឹងតវ៉ាករណីសហភាពអឺរ៉ុបដាក់ពន្ធលើការនាំចូលអង្ករកម្ពុជា និងពង្រឹងទីផ្សារអង្ករអឺរ៉ុប

សូមជម្រាបជូនពីដំណើរដើមចមថា ចាប់តាំងពីពេលដែលគេប្រកាស នឹងមានការស៊ើបអង្កេតនេះនៅក្នុងខែមីនាឆ្នាំ២០១៨ ដោយខាងប្រទេសអ៊ីតាលី និងអេស្ប៉ាញ គេបានតវ៉ាថាអង្ករកម្ពុជាដែលយើងនាំចូលដោយមិនយកពន្ធនេះបានធ្វើឲ្យប៉ះពាល់ទៅដល់ទីផ្សារក៏ដូចជាផលិតកម្មស្រូវនៅប្រទេសរបស់គេនៅអឺរ៉ុប។

- ក្រោយពីការបញ្ចេញនូវសេចក្តីប្រកាសអំពីការស៊ើបអង្កេតខាងលើនេះ សហព័ន្ធស្រូវអង្ករកម្ពុជា បានទទួលការឯកភាពពីក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធ នៅក្នុងកិច្ចប្រជុំកាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ សហព័ន្ធស្រូវអង្ករកម្ពុជាក៏បានសម្រេចជួលមេធាវីអន្តរជាតិដែលគាត់ធ្លាប់ការពាររឿងក្តីស្រដៀងគ្នាដែរហើយធ្លាប់ទទួលបានជោគជ័យដើម្បីជួយការពាររឿងក្តីនេះដោយមានការសហការពីដៃគូអភិវឌ្ឍន៍លើការជួលកុងស៊ុលតង់ និងមានការសហការពីក្រសួងពាណិជ្ជកម្ម។

- សហព័ន្ធស្រូវអង្ករកម្ពុជា ក៏បានធ្វើការងារនេះដោយយើងបានសហការជាមួយសមាជិករបស់យើងដែលជាអ្នកនាំចេញធំៗទាំង២០ ក្នុងការដាក់ចំណាប់អារម្មណ៍ទៅលើករណីនេះ ហើយចូលរួមក្នុងការផ្តល់ព័ត៌មានផ្សេងៗក្នុងការស៊ើបអង្កេតនេះ ដើម្បីបញ្ជាក់ថាអង្ករកម្ពុជានេះមិនបានផ្តល់ផលប៉ះពាល់ដល់ទីផ្សារ ឬផលិតកម្មស្រូវអង្ករនៅក្នុងប្រទេសអឺរ៉ុបដូចដែលមានការចោទប្រកាន់ពីប្រទេស២ក្នុងចំណោមប្រទេសទាំង២៨នៅសហភាពអឺរ៉ុប។



ប្រជុំជាមួយសមាជិក កាលពីខែមីនា ឆ្នាំ២០១៩

- ក្រោយពីការស៊ើបអង្កេត និងការវាយតម្លៃទៅលើដើមបណ្តឹង និងចុងបណ្តឹង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ខាងសហភាពអឺរ៉ុបគេបញ្ចេញព័ត៌មានលើសេចក្តីសម្រេចនេះ ថាការនាំចេញពីកម្ពុជា និងមីយ៉ាន់ម៉ា។ ធ្វើអោយមានការប៉ះពាល់ទីផ្សារអឺរ៉ុប ដោយមិនមានហេតុផលនិងភស្តុតាងគ្រប់គ្រាន់នោះឡើយ ដែលវាជារឿងអយុត្តិធម៌សម្រាប់អ្នកនាំចេញអង្ករកម្ពុជា ពិសេសប្រជាកសិករដែលរងគ្រោះមកជាមួយ។ ខណៈនោះសហភាពអឺរ៉ុបបានទុកពេលឲ្យយើងតវ៉ាចំនួន៣សប្តាហ៍ ហេតុដូចនេះខាងសហព័ន្ធស្រូវអង្ករកម្ពុជាបានសហការជាមួយខាងក្រសួងពាណិជ្ជកម្ម ក្នុងការស្នើសុំបើកនិងស្តាប់សាវនាការ និងបានឆ្លើយតបលិខិតជាលាយលក្ខអក្សរទៅតាមទល្លីករមួយៗដែលខាងគណៈកម្មការអឺរ៉ុប បានវាយតម្លៃដោយយើងបានធ្វើការបកស្រាយតាមចំណុចនីមួយៗដែលEUបានលើកឡើង ដោយនៅក្នុងសេចក្តីប្រកាសរបស់EUនោះមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយហើយជាការវាយតម្លៃមិនបានតាមទិដ្ឋភាពជាក់ស្តែង ដូច្នេះយើងត្រូវលើកយកចំណុចជាច្រើននៅក្នុងនោះមកពិភាក្សាឡើងវិញ។

- ជាមួយគ្នានេះយើងក៏បានស្នើសុំឲ្យមានសវនាការដោយផ្ទាល់មាត់ទល់មុខគ្នាដើម្បីឲ្យមេធាវីយើង ក៏ដូចជាមេធាវីអន្តរជាតិបានបកស្រាយ និងចូលរួមក្នុងសវនាការនេះ ដោយមានឯកឧត្តម សុខ ពុទ្ធិវុធ ប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា និងតំណាងរបស់ក្រសួងពាណិជ្ជកម្ម ជាមួយមេធាវីយើងបានចូលរួមផ្តល់ការពន្យល់និងបទបង្ហាញដើម្បីការពារវិស័យស្រូវអង្ករកម្ពុជា ដោយផ្ទាល់មាត់ជាមួយខាងគណៈកម្មាធិការអឺរ៉ុបនៅទីក្រុងប្រ៊ុសសែល ប្រទេសប៊ែលសិក កាលពីនៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៨។





- សហព័ន្ធស្រូវអង្ករកម្ពុជា ក៏បានបន្តសហការជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការធ្វើលិខិតទៅដល់ប្រធានគណៈកម្មាការអឺរ៉ុបដែលទទួលបន្ទុកផ្នែកនេះ ហើយក៏បានចម្លងជូនឯកសារនោះទៅរដ្ឋជាសមាជិកតាមរយៈស្ថានទូតប្រទេសដែលជាសមាជិកEUដែលមាននៅកម្ពុជា ក៏ដូចជាទៅប្រធានរបស់សភាអឺរ៉ុប ប្រធានក្រុមគណៈកម្មាការអឺរ៉ុប ទៅដល់អគ្គរដ្ឋទូតអឺរ៉ុបនៅអាស៊ានជាដើម ដោយផ្តោតលើអ្វីដែលយើងខំប្រឹងធ្វើពីមុនមករហូតដល់ឥឡូវនេះ យើងបានខិតខំដោយការយកចិត្តទុកដាក់បំផុតដែលយើងបានធ្វើការជាប្រចាំជាមួយមេធាវីក៏ដូចជាក្រសួង-ស្ថាប័នពាក់ព័ន្ធ ឲ្យតាមដានការងារនេះ។ ជាមួយគ្នានេះដែរ ក៏យើងស្នើសុំសមាជិកសមាជិករបស់យើងដែលជាអ្នកនាំចេញជួយពន្យល់បន្ថែមដល់សហគមន៍អឺរ៉ុប អំពីផលប៉ះពាល់ប្រសិនបើគេដាក់ពន្ធនោះមែន។

- ស្របពេលជាមួយគ្នានោះ យើងមានជំនួបតាមស្ថានទូតនានា ដើម្បីតវ៉ារឿងក្តីដែលគណៈកម្មការសហភាពអឺរ៉ុបគ្រោងដាក់ពន្ធការនាំចេញអង្ករបស់កម្ពុជាដែលនាំចូលទៅកាន់ទីផ្សារអ៊ឺរ៉ុប។ សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងនាមជាតំណាងវិស័យឯកជនផ្នែកស្រូវអង្ករ ដែលរួមមានសមាជិកជាសហគមន៍កសិកររាប់ម៉ឺនគ្រួសារ តំណាងរោងម៉ាស៊ីនរាប់រយគ្រួសារ នឹងតំណាងក្រុមហ៊ុននាំចេញអង្ករទាំងអស់ សង្ឃឹមថាគណៈកម្មការសហគមអឺរ៉ុប ក៏ដូចជាបណ្តាប្រទេសទាំងឡាយប្រមាណ២៨ប្រទេសនៅសហគមន៍អឺរ៉ុប នឹងពិនិត្យឡើងវិញលើសំណើពីសហព័ន្ធស្រូវអង្ករកម្ពុជា និងស្ថាប័នពាក់ព័ន្ធ ឲ្យបានគ្រប់ជ្រុងជ្រោយមុននឹងសម្រេចដាក់ពន្ធលើការនាំចូលអង្ករពីកម្ពុជា ដោយផ្អែកលើមូលដ្ឋានត្រឹមត្រូវ គឺមិនត្រូវផ្អែកលើត្រឹមតែ២ប្រទេសដែលបានលើកឡើងមិនសមហេតុផលនោះ។ម្យ៉ាងវិញទៀត ការដាក់វិធានការនោះមិនត្រឹមតែប៉ះពាល់ដល់អ្នកនាំចេញអង្ករកម្ពុជាទេ ក៏នឹងប៉ះពាល់ដល់អ្នកនាំចូលនិងអ្នកបរិភោគខ្លួនឯងនៅអឺរ៉ុបផងដែរ។

- រហូតមកដល់ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ សហគមន៍អឺរ៉ុបមានការបោះឆ្នោតចំពោះការដាក់ពន្ធលើការនាំចូលអង្ករពីកម្ពុជា ដោយក្នុងចំណោម២៨ប្រទេស ដែលជាសមាជិកសហភាពអឺរ៉ុប គឺមាន១៣ប្រទេសគាំទ្រការដាក់ពន្ធ ប៉ុន្តែការសម្រេចនោះមិនគ្រប់ក្នុងការសម្រេចដាក់វិធានការបានទេ ដោយមាន៧ប្រទេសអនុប្រវាទ និង៨ប្រទេសប្រឆាំងទៅលើការដាក់ពន្ធទៅលើអង្ករកម្ពុជា ដែលនេះឆ្លុះបញ្ចាំងឲ្យឃើញថាប្រទេសមួយចំនួនគេបានគាំទ្រអង្ករកម្ពុជាយើង ដូចជា ចក្រភពអង់គ្លេសគាំទ្រមិនដាក់ពន្ធ សហព័ន្ធអាលឺម៉ង់បានធ្វើអនុប្រវាទ ជាដើម។ បើទោះបីជាការបោះឆ្នោតនៅក្នុងចំណោមប្រទេសទាំង ២៦ នៅសហភាពអឺរ៉ុបមិនបានជោគជ័យ តែគណៈកម្មការសហភាពអឺរ៉ុបនៅតែបន្តនីតិវិធីសម្រេចដាក់ពន្ធលើការនាំចូលអង្ករពីកម្ពុជានិងមីយ៉ាន់ម៉ាទាល់តែបាននៅដើមឆ្នាំ២០១៩នេះ។







- កាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ ដោយមើលឃើញពីភាពអយុត្តិធម៌ និងដើម្បីការពារវិស័យស្រូវអង្ករកម្ពុជាទាំងមូលក្រុមប្រឹក្សាភិបាល ដែលដឹកនាំដោយ**ឯកឧត្តម សុខ ពុទ្ធិវុធ** និងសមាជិកសមាជិកាទាំងអស់ និងក្រុមការងារវេទិការាជរដ្ឋាភិបាល-វិស័យឯកជនផ្នែកស្រូវអង្ករ (ក្រុមការងារទី៩) បានឯកភាពគ្នា និងបានសម្រេចឱ្យដាក់ពាក្យបណ្តឹងស្នើសុំមោឃភាពលើសេចក្តីសម្រេចលេខ២០១៩/៦៧របស់គណៈកម្មការសហភាពអឺរ៉ុប ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ លើវិធានការការពារទាក់ទងនឹងការនាំចូលអង្ករ Indica ដែលមានប្រភពចេញពីប្រទេសកម្ពុជានិងមីយ៉ាន់ម៉ា។ វិធានការការពារត្រូវបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការនាំចូលអង្ករជាទូទៅពីព្រះរាជាណាចក្រកម្ពុជា ដោយមិនមានការពិចារណាលើភាពអយុត្តិធម៌ណាមួយឡើយ។ កន្លងមក ការនាំចេញអង្ករ Indica ដែលមានប្រភពចេញពីព្រះរាជាណាចក្រកម្ពុជាត្រូវបានលើកលែងពន្ធនាំចូល ក្រោមកិច្ចព្រមព្រៀងពិសេសសហភាពអឺរ៉ុប ដែលបានផ្តល់ប្រព័ន្ធអនុគ្រោះពន្ធគ្រប់ប្រភេទលើកលែងតែអាវុធ( EBA) សម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិចតួច ដែលនេះជាផ្នែកមួយនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP)។

វិធានការការពារជាមូលដ្ឋានត្រូវបានគេយល់ខុស ហើយការអនុវត្តច្បាប់នៃសហភាពអឺរ៉ុបគឺមិនមានភាពត្រឹមត្រូវ។ បទប្បញ្ញត្តិចម្រូងចម្រាសនេះកំណត់ឲ្យអនុវត្តវិធានការការពារនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP)។ នេះគឺជាការអនុវត្តលើកដំបូង ដែលវាគួរត្រូវអនុវត្តតាមស្តង់ដារច្បាប់ឲ្យបានត្រឹមត្រូវ។ គណៈកម្មការបរាជ័យក្នុងការប្រមូលភស្តុតាងដែលចាំបាច់ទាំងអស់ ក្នុងអំឡុងពេលនៃការស៊ើបអង្កេតជាមូលដ្ឋាននាំឱ្យមានការដកហូតការអនុគ្រោះពន្ធ។ សេចក្តីសរុបទូទៅនៃការដកប្រព័ន្ធអនុគ្រោះពន្ធត្រូវបានធ្វើឡើង ដោយមិនបានពិចារណាលើទិន្នន័យដែលអាចរារាំងការដាក់វិធានការនេះ។ ការនាំចូលស្រូវពីសាធារណរដ្ឋហ្គាយ៉ាណា ជាក់ស្តែងអង្ករ Indica មិនមែនជាអង្ករក្រអូបហើយមិនមានការប្រកួតប្រជែងជាមួយអង្ករក្រអូបទេ និងការប្រមូលទិន្នន័យនាំចូលមិនត្រឹមត្រូវពីប្រទេសកម្ពុជា និងមីយ៉ាន់ម៉ាដែលជាឧទាហរណ៍នាំឲ្យមានដំណោះស្រាយដែលមិនត្រឹមត្រូវនេះ។ លើសពីនេះទៅទៀត ការវាយតម្លៃលើផលប៉ះពាល់នៃការនាំចូលពីប្រទេសកម្ពុជាមានភាពមិនត្រឹមត្រូវ ហើយមិនបានបង្ហាញនូវផលវិបាកដែលឧស្សាហកម្មស្រូវអង្ករបានជួបប្រទះ និងផលវិបាកពាក់ព័ន្ធនឹងបរិមាណ និងតម្លៃនៃការនាំចូលរបស់កម្ពុជា។ ការដាក់ពន្ធនាំចូលឡើងវិញបានប៉ះពាល់ឧស្សាហកម្មស្រូវអង្ករ ជាពិសេសប៉ះពាល់ដល់ប្រជាកសិករ។

**ឯកឧត្តម សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាបានមានប្រសាសន៍ថា៖ "សហគមន៍អឺរ៉ុបជាដៃគូពាណិជ្ជកម្មដ៏រឹងមាំ និងយូរអង្វែងរបស់កម្ពុជា ហើយកម្ពុជារំពឹងនូវការទទួលបានសវនាការមួយដែលប្រកបដោយភាពយុត្តិធម៌ និងពេញលេញ។ សហព័ន្ធស្រូវអង្ករកម្ពុជាមានទំនុកចិត្តថា វិធានការនេះមិនត្រូវបានអនុវត្តទេ ហើយសង្ឃឹមថាសហភាពអឺរ៉ុបនឹងមានឆន្ទៈពិចារណាលើវិសាស្រ្តរបស់ខ្លួនឡើងវិញនៅពេលដែលសហភាពអឺរ៉ុបបានវិភាគលើភស្តុតាងទាំងអស់ ហើយនឹងផ្តល់ឱកាសដល់កម្ពុជាដើម្បីបង្ហាញរូបភាពពេញលេញមួយដល់សវនាការនាពេលខាងមុខ។

## 2.2 គណៈកម្មាធិការរោងម៉ាស៊ីន-ការកិនកែច្នៃ និងឡសម្ងួត

Executive Committee of Milling, Processing and Storage



**លោក នង ចាសនា**

គណៈកម្មាធិការទទួលបន្ទុកការងាររោងម៉ាស៊ីន និងឃ្លាំងត្រូវបានបង្កើតឡើងនៅ**ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦** ស្របតាមប្រកាសលេខ ១៥៥.១៦ ស.អ.ក ស្តីពី ការបង្កើតគណៈកម្មាធិការទទួលបន្ទុកការងាររោងម៉ាស៊ីន និងឃ្លាំង។ បច្ចុប្បន្នគណៈកម្មាធិការនេះ មានសមាជិកចំនួន ១១រូប ដែលមានសមាសភាពមកពីបណ្តារោងម៉ាស៊ីនកិននិងកែច្នៃស្រូវអង្ករធំៗ ដែលមានបច្ចេកវិទ្យា និងសមត្ថភាពផលិតខ្ពស់។ គណៈកម្មាធិការ ត្រូវអនុវត្តតាមការងារដូចខាងក្រោម៖

- ពង្រីកនិងអភិវឌ្ឍសមត្ថភាពឃ្លាំងស្តុក និងឡសម្ងួត ដើម្បីពង្រីកសក្តានុពលនៃការប្រមូលស្រូវពីកសិករទាន់ពេលវេលាយកមកសម្ងួត និងស្តុកទុកតាមរយៈគម្រោងរបស់រាជរដ្ឋាភិបាល។
- ពង្រីក និងពង្រឹងសុវត្ថិភាព គុណភាព ស្តង់ដារ និងសមត្ថភាពក្នុងការកិនកែច្នៃស្រូវអង្ករកម្ពុជា ដើម្បីផ្គត់ផ្គង់ដល់ការនាំចេញអង្ករឱ្យបាន១លានតោន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- ធ្វើការអភិវឌ្ឍសមត្ថភាពរបស់ម៉ាស៊ីនកិន និងកែច្នៃស្រូវអង្ករពីកម្រិតតូច ទៅកម្រិតមធ្យម និងពីកម្រិតមធ្យម ទៅកម្រិតធំៗ តាមរយៈគម្រោងហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល។
- ធ្វើការបណ្តុះបណ្តាលដល់សមាជិករោងម៉ាស៊ីនកិន និងកែច្នៃស្រូវអង្ករអំពី ស្តង់ដារសុវត្ថិភាពចំណីអាហារ និងប្រព័ន្ធគ្រប់គ្រងរោងចក្រ សហគ្រាសប្រកបដោយប្រសិទ្ធិភាព ដោយសហការជាមួយស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា។



## សមិទ្ធផលដែលគណៈកម្មាធិការសម្រេចបាន ៖

### 2.2.1 គម្រោងឃ្លាំង-ឡសម្ងួត

ដើម្បីឱ្យគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយភាពប៉ិនប្រសប់ គតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលបានជោគជ័យនិងជាការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាកសិករ និងធុរជនក្នុងវិស័យស្រូវ-អង្ករ ដែលប្រឈមនឹងតម្លៃស្រូវទាប(នៅក្នុងរដូវប្រមូលផល) កង្វះស្រូវសម្រាប់ការកិននាំចេញអង្ករ(ក្រោយរដូវប្រមូលផល) កង្វះទុនបង្វិល និងកង្វះឡសម្ងួតនិងឃ្លាំងសម្រាប់ប្រមូលទិញស្រូវស្តុកទុកសម្រាប់កិន-កែច្នៃ ក្នុងការផ្គត់ផ្គង់អង្ករដល់ទីផ្សារអន្តរជាតិក្នុងទ្រង់ទ្រាយធំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា បានស្នើរាជរដ្ឋាភិបាលឱ្យពង្រីកសមត្ថភាពឃ្លាំងស្តុក និងឡសម្ងួត និងទុនបង្វិលបន្ថែមទៀតសម្រាប់វិស័យស្រូវ-អង្ករកម្ពុជា ជាលទ្ធផលគឺ៖

- រាជរដ្ឋាភិបាលបានសម្រេចអនុម័តបញ្ចេញកញ្ចប់ថវិកាជាតិចំនួន៨០លានដុល្លារ សម្រាប់ពង្រឹងវិស័យស្រូវ-អង្ករកម្ពុជា ក្នុងនោះដំណាក់កាលទី១ មានចំនួន៣០លានដុល្លារ ប្រើប្រាស់សម្រាប់កម្ចីក្នុងរយៈពេលខ្លីដើម្បីពង្រីកទុនបង្វិលក្នុងការប្រមូលទិញស្តុកទុកស្រូវសម្រាប់កិន-កែច្នៃ។ ដំណាក់កាលទី២ មានចំនួន៥០លានដុល្លារ ប្រើប្រាស់សម្រាប់ពង្រីកសមត្ថភាពឃ្លាំងស្តុក និងឡសម្ងួត ក្នុងនោះមានសហគ្រាសរោងម៉ាស៊ីនកិន-កែច្នៃស្រូវអង្ករចំនួន៣ ដែលទទួលបានកញ្ចប់ថវិកានេះក្នុងការសាងសង់ឃ្លាំងស្តុក និងឡសម្ងួតនៅខេត្តតាកែវ កំពង់ធំ និងបាត់ដំបង។
- ក្រោមឥណទានសម្បទានពីរាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្មជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីគម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករជាមួយរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្នុងគោលបំណងរៀបចំនិងអនុវត្តគម្រោងសាងសង់ប្រព័ន្ធឃ្លាំងសាធារណៈសម្រាប់ស្តុកស្រូវ-អង្ករ។ ផ្អែកតាមរបាយការណ៍បឋម គម្រោងនេះនឹងសាងសង់ប្រព័ន្ធឃ្លាំងស្តុក និងឡសម្ងួតស្រូវ-អង្ករចំនួន១៥កន្លែង ដែលមានសមត្ថភាពសម្ងួតស្រូវសើមដល់ទៅ១៩.៥ពាន់តោនក្នុងមួយថ្ងៃ និងមានសមត្ថភាពស្តុកស្រូវ-អង្ករស្ងួតបានដល់ទៅ១លានតោន គ្របដណ្តប់លើខេត្តចំនួន១១ ដែលមានសក្តានុពលក្នុងការផលិតស្រូវ-អង្ករ។
- ប៉ុន្តែនៅមិនទាន់ឃើញមានការវិវត្តពីដំណើរការនៃឃ្លាំងនិងឡសម្ងួតតាមរយៈគម្រោងខាងលើ។

### 2.2.2 កាត់បន្ថយចំណាយលើការវាយតម្លៃផលប៉ះពាល់បរិស្ថាន

ដោយមើលឃើញពីភាពចាំបាច់ក្នុងការចូលរួមការពារបរិស្ថាន និងសម្រួលដល់ការលំបាកនានារបស់សមាជិកសហគ្រាសរោងម៉ាស៊ីនកិន-កែច្នៃស្រូវអង្ករពាក់ព័ន្ធនឹងបរិស្ថាន សហព័ន្ធស្រូវអង្ករកម្ពុជាបានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន ដើម្បីសិក្សាពីលទ្ធភាពក្នុងការសម្រួលដល់កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើសហគ្រាសនានាក្នុងវិស័យស្រូវអង្ករ។ ជាលទ្ធផល ក្រសួងបរិស្ថាន និងសហព័ន្ធបានសម្រេចជាផ្លូវការនូវអនុស្សរណៈយោគយល់គ្នាមួយស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន កាលពីថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០១៦ កន្លងទៅ។ គោលបំណងនៃអនុស្សរណៈយោគយល់គ្នានេះ គឺ៖

- អនុវត្តគោលនយោបាយនៃការនាំចេញអង្ករឱ្យបាន ១លានតោនក្នុងមួយឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា
- ជំរុញការលើកទឹកចិត្តដល់កសិករ សហគ្រិន និងវិនិយោគិនក្នុងការផលិតអង្ករ និងប្រកួតប្រជែងសម្រាប់ការនាំចេញអង្ករទៅក្រៅប្រទេស
- បង្កើនគុណភាពអង្ករនៅកម្ពុជាដែលគ្មានជាតិគីមី និងមានការជឿជាក់ពីអតិថិជន
- ធានាការចូលរួមអភិវឌ្ឍន៍សហគ្រាសរោងម៉ាស៊ីនកិន-កែច្នៃស្រូវអង្ករ ប្រកបដោយនិរន្តរភាពបរិស្ថាន

ជាមួយគ្នានេះដែរ អនុស្សរណៈនៃការយោគយល់គ្នានេះ មានវិសាលភាពអនុវត្តសម្រាប់ប្រភេទគម្រោងបង្កើតរោងចក្រម៉ាស៊ីនកិន-កែច្នៃស្រូវអង្ករនៅព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យរៀបចំកិច្ចសន្យាការពារបរិស្ថាន ដោយភ្ជាប់ជាមួយនូវផែនការគ្រប់គ្រងបរិស្ថាន។

### 2.2.3 សម្របសម្រួលជាមួយអគ្គនាយកដ្ឋានកសិកម្ម និង AQSIQ

ដើម្បីធានាគុណភាព អនាម័យ និងកេរ្តិ៍ឈ្មោះអង្កររបស់កម្ពុជា និងជំរុញកំណើននៃការនាំចេញទៅកាន់ទីផ្សារប្រទេសចិន សហព័ន្ធស្រូវអង្ករបានចូលរួមសហការ និងសម្របសម្រួលកិច្ចដំណើរការធ្វើត្រួតពិនិត្យ និងវាយតម្លៃសហគ្រាសរោងម៉ាស៊ីនកិន-កែច្នៃស្រូវអង្ករ ជាមួយមន្ត្រីត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័កសាធារណៈរដ្ឋប្រជាមានិតចិន (AQSIQ) និងអគ្គនាយកដ្ឋានកសិកម្ម (GDA) ចំនួន២លើកគឺ៖



លើកទី១៖ ដោយមានការចូលរួមពីសមាជិក និងកិច្ចខិតខំប្រឹងប្រែងក្នុងការសម្របសម្រួលពីសហព័ន្ធ ក្រុមហ៊ុន និងសហគ្រាសរោងម៉ាស៊ីនកិន-កែច្នៃស្រូវអង្ករចំនួន២៦ ត្រូវបានអនុញ្ញាតឱ្យធ្វើការកិន-កែច្នៃនិងនាំចេញទៅកាន់ទីផ្សារប្រទេសចិន ក្រោមលក្ខខណ្ឌពិធីសារ (MOU) អនាម័យ និងភូតគាមអនាម័យ (SPS) រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន។

លើកទី២៖ ដោយមើលឃើញពីសក្តានុពល និងកំណើនកូតាសម្រាប់អង្ករកម្ពុជាលើទីផ្សារប្រទេសចិន និងផលវិបាករបស់សមាជិកមួយចំនួនដែលមិនទាន់បានទទួលការវាយតម្លៃ សហព័ន្ធស្រូវអង្ករកម្ពុជា បានសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម ចុះធ្វើការវាយតម្លៃ និងត្រួតពិនិត្យបឋមលើក្រុមហ៊ុន និងសហគ្រាសរោងម៉ាស៊ីនកិន-កែច្នៃស្រូវអង្ករចំនួន៦៥បន្ថែមទៀត ក្នុងគោលបំណងរៀបចំរបាយការណ៍បឋម និងធ្វើលិខិតទៅអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័កសាធារណរដ្ឋប្រជាមានិតចិន (AQSIQ) ចុះមកពិនិត្យ និងវាយតម្លៃជាលើកទី២។ ជាលទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃបឋម ក្រុមហ៊ុន និងសហគ្រាសរោងម៉ាស៊ីនកិន-កែច្នៃចំនួន ៤០ ត្រូវបានជ្រើសរើសក្នុងការដំណើរការត្រួតពិនិត្យ និងវាយតម្លៃជាលើកទី២។

ការវាយតម្លៃ និងត្រួតពិនិត្យនេះ គឺផ្តោតលើ(១) ច្បាប់ស្តីពីសុវត្ថិភាពអាហាររបស់សាធារណរដ្ឋប្រជាមានិតចិន និងលិខិតបទដ្ឋានសម្រាប់អនុវត្តច្បាប់នេះ (២) ច្បាប់ស្តីពីការនាំចេញ នាំចូលសត្វ និងភូតគាមអនាម័យរបស់សាធារណរដ្ឋប្រជាមានិតចិន និងលិខិតបទដ្ឋានសម្រាប់អនុវត្តច្បាប់នេះ។

## 2.2.4 សម្របសម្រួលជាមួយអគ្គនាយកដ្ឋានពន្ធដាររៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីស្តង់ដារប្រព័ន្ធគណនេយ្យ ភាតព្វកិច្ចជាប់ពន្ធ

ដើម្បីចូលរួមគាំទ្រគោលនយោបាយរាជរដ្ឋាភិបាល និងលើកទឹកចិត្តឱ្យមានការចូលរួមបំពេញកាតព្វកិច្ចពន្ធដារ នៅរសៀលថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ០១៨ លេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា និងសមាជិក បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបច្ចុប្បន្នភាពនៃច្បាប់សារពើពន្ធ" សម្រាប់សហគ្រាសអ្នកជាប់ពន្ធ ដែលប្រព្រឹត្តិនៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ប៊ូ ថារិន អគ្គលេខាធិការនៃ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ឌី តាយី** រដ្ឋលេខាធិការ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ច្បាប់ស្តីពី កាតព្វកិច្ចគណនេយ្យ និងសវនកម្មនេះ បានបង្កើតឡើងតាំងពីឆ្នាំ២០០២ ហើយមកដល់បច្ចុប្បន្នមានក្រុមហ៊ុនចំនួន ៥១ ហើយដែលទទួលបានអាជ្ញាប័ណ្ណ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ឯកឧត្តមមានប្រសាសន៍ និងស្នើសុំឲ្យ សហគ្រាសទាំងអស់ ប្រើប្រាស់និងអនុវត្តរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារគណនេយ្យកម្ពុជា (CIFRS = IFRS , CIFRS for SME = IFRS for SME and CISA= ISA ) ដើម្បីឲ្យរបាយការណ៍ហិរញ្ញវត្ថុមានស្តង់ដារតែមួយ មានតម្លាភាព និងភាពស្មោះត្រង់ចំពោះច្បាប់សារពើពន្ធ  សម្រាប់ប្រើប្រាស់ក្នុងសហគ្រាសផ្ទាល់ សម្រាប់សវនកម្ម សម្រាប់រាយការណ៍ជូនក្រុមប្រឹក្សាជាតិគណនេយ្យ និងសម្រាប់ប្រកាសពន្ធតាមច្បាប់សារពើពន្ធ។



**កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបច្ចុប្បន្នភាពនៃច្បាប់សារពើពន្ធ**

## 2.2.5 សហការជាមួយ SGS, Bureau Veritas បណ្តុះបណ្តាលពង្រឹងគុណភាព និងស្តង់ដាររោងម៉ាស៊ីន

ដោយមើលឃើញពីតម្រូវការចាំបាច់របស់សមាជិក ដើម្បីបង្កើនភាពប្រកួតប្រជែង តាមរយៈគុណភាព សុវត្ថិភាព និងស្តង់ដារអនាម័យ សហព័ន្ធស្រូវអង្ករ បានសហការជាមួយក្រុមហ៊ុន SGS CAMBODIA ដើម្បីរៀបចំសិក្ខាសាលាស្តីពីស្តង់ដារ និងអនាម័យដល់បណ្តាសមាជិករោងម៉ាស៊ីនកិន-កែច្នៃស្រូវអង្ករទាំងអស់ ក្នុងគោលបំណងពង្រីកសមត្ថភាព និងចំណេះ ស្តីពីស្តង់ដារ និងអនាម័យ ដល់បណ្តារោងម៉ាស៊ីនកិន-កែច្នៃដែលជាសមាជិក។

## 2.2.6 ប្រមូល និងផលិតទិន្នន័យ

សហព័ន្ធស្រូវអង្ករកម្ពុជា
CAMBODIA RICE FEDERATION

CAMBODIAN WEEKLY FOB INDICATION PRICE

Week 18th : 30/Apr - 06/May/2018

| No | Rice Variety | Abbreviation | FOB (USD Per Ton) | (%) Change* |
|---|---|---|---|---|
| I. | Cambodian Long Grain Fragrant | | | |
| 1 | Premium Jasmine Rice 5% (Purity 90%) | PJR 5% | $ 970 | 0.5% |
| 2 | Jasmine Rice 5% (Purity 85%) | JR 5% | $ 960 | 1.1% |
| 3 | Premium Sen Kra-Ob 5% (Purity 90%) | PSKO 5% | $ 905 | 1.7% |
| 4 | Sen Kra-Ob 5% (Purity 85%) | SKO 5% | $ 895 | 2.3% |
| 5 | A1 Extra Super 100% Broken (Fragrant) | AESB 100% Broken | $ 610 | 0.0% |
| 6 | A1 Super 100% Broken (Fragrant) | ASB 100% Broken | $ 500 | 0.0% |
| II. | Cambodian Long Grain White Rice | | | |
| 7 | Long Grain White Rice 5% | LGWR 5% | $ 500 | 2.0% |
| 8 | Long Grain White Rice 10% | LGWR 10% | $ 490 | 2.1% |
| 9 | A1 Super 100% Broken (LGWR) | ASB 100% Broken | $ - | N/A |
| III. | Cambodian Parboiled Rice | | | |
| 10 | Parboiled Rice 5% Broken | PRB 5% Broken | $ 565 | 6.6% |




- ធ្វើការប្រមូលនូវទិន្នន័យភូមិសាស្ត្រដែលទាក់ទងនឹងវិស័យកសិកម្ម ដូចជាការគូសក្បាលដីស្រែ ការកំណត់បង្ហាញទីតាំងសហគមន៍កសិកម្ម និងទីតាំងរោងម៉ាស៊ីនកិននិងកែច្នៃស្រូវអង្ករ និងការរៀបចំផែនទី។
- ធ្វើការប្រមូលទិន្នន័យតម្លៃអង្ករសម្រាប់នាំចេញ (FOB Indication Price)ប្រចាំសប្ដាហ៍ និងផ្សព្វផ្សាយទិន្នន័យនេះដល់សមាជិកទាំងអស់។
- ធ្វើការប្រមូលទិន្នន័យនាំចេញអង្កររបស់ប្រទេសកម្ពុជា (Rice Export Statistics) ជាប្រចាំខែ និងផ្សព្វផ្សាយរបាយការណ៍នេះដល់សមាជិកពាក់ព័ន្ធទាំងអស់។

## 2.3 គណៈកម្មាធិការផលិតកម្ម ពូជ និងការងារសហគមន៍( ExCo PSF )

Executive Committee of Production, Seed and Farming



លោក ស៊ី រ៉ានី

គណៈកម្មាធិការផលិតកម្មនិងពូជស្រូវមានសមាជិកចំនួន១១រូប ដឹកនាំដោយលោក ស៊ី រ៉ានី អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ជាប្រធានគណៈកម្មាធិការ។ភារកិច្ចសំខាន់ៗរបស់គណៈកម្មាធិការផលិតកម្មនិងពូជស្រូវ រួមមាន៖

- ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់សហព័ន្ធ ដោយកំណត់លើប្រភេទពូជស្រូវ ដែលឆ្លើយតបតាមតម្រូវការទីផ្សារនិងម៉ាកយីហោអង្ករកម្ពុជា កំណត់ជី ថ្នាំសម្លាប់សត្វល្អិត និងការងារក្សេតសាស្ត្រ
- ជួយសម្របសម្រួលរៀបចំ និងសហការជាមួយក្រុមការងារតំបន់ទាំង៥ របស់សហព័ន្ធស្រូវអង្ករកម្ពុជា
- ចរចាជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍនានា ក្នុងការស្វែងរកនូវកិច្ចសហប្រតិបត្តិការ ការកៀរគររកជំនួយសម្រាប់ជួយដល់ការធ្វើសកម្មភាពការជំរុញ ការផ្សព្វផ្សាយ ការងារកិច្ចសន្យាកសិកម្ម ប្រព័ន្ធទិញលក់បែបទំនើប ការងារអប់រំការចងក្រងសហគមន៍កសិកម្ម និងកម្មវិធីនានាដែលជួយដល់និរន្តរភាពលើការអនុវត្តការដាំដុះ បច្ចេកទេសដាំដុះរបស់ប្រជាជន ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ និងសន្តិសុខស្បៀងក្នុងប្រទេស
- សម្របសម្រួលការអនុវត្តជាក់ស្តែងជាមួយសហគមន៍កសិករ ដូចជា ជំរុញផ្សព្វផ្សាយពូជ ជី ថ្នាំ បច្ចេកទេសការដាំដុះ និងការទុកដាក់ពេលប្រមូលផល។

## សមិទ្ធផលដែលគណៈកម្មាធិការសម្រេចបាន ៖

### 2.3.1 កម្មវិធីផលិតស្រូវតម្រូវទីផ្សារ

តាមរយៈកិច្ចសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម កាឌី និងការ៉ាក់ ដោយមើលឃើញពីសក្ដានុពលរបស់កម្ពុជាក្នុងការផលិតអង្ករដែលមានគុណភាព និងតម្រូវការទីផ្សារអង្ករក្រអូបកើនឡើងនិងមានតម្លៃខ្ពស់ សហព័ន្ធស្រូវអង្ករកម្ពុជា អគ្គនាយកដ្ឋានកសិកម្ម វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា និងកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា បានសហការគ្នាបង្កើតគម្រោងពីរដែលផ្ដោតទៅលើពូជស្រូវក្រអូបគឺគម្រោងបន្សុទ្ធពូជស្រូវសែនក្រអូប និងគម្រោងបង្កាត់ពូជស្រូវផ្ការំដួលមិនប្រកាន់រដូវ។



ក្នុងប្រទេសកម្ពុជាមានពូជស្រូវរាប់ពាន់ពូជដែលធ្វើការដាំដុះខុសៗគ្នាពីតំបន់មួយទៅតំបន់មួយ អាស្រ័យទៅលើរបបទឹកភ្លៀង កត្តាអាកាសធាតុ ដី សត្វល្អិតចង្រៃ ជម្ងឺ ចំណង់ចំណូលចិត្តរបស់ប្រជាកសិករនៅតាមមូលដ្ឋាន និងតម្រូវការទីផ្សារ។ ដើម្បីផ្ដល់ភាពងាយស្រួលក្នុងការជ្រើសរើសពូជស្រូវឲ្យត្រូវតាមតម្រូវការទីផ្សារ និងទទួលតម្លៃលក់ខ្ពស់ គណៈកម្មាធិការផលិតកម្មនិងពូជស្រូវនៃសហព័ន្ធស្រូវអង្ករកម្ពុជា បានជ្រើសរើស និងកំណត់ពូជស្រូវអាទិភាពចំនួន ១៧ពូជ ចែកចេញជា ៤ប្រភេទ ដូចខាងក្រោម៖



វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)

១-អង្ករក្រអូបស្រូវវស្សា រួមមាន៖ ពូជផ្ការំដួល ផ្កាម្លិះ ផ្ការំដេង ផ្ការមៀត និងសូម៉ាលីវស្សា
២-អង្ករសប្រណីត រួមមាន៖ ពូជនាងមិញ នាងខុន នាងស និងរាំងជ័យ
៣-ស្រូវឡើងទឹក រួមមាន៖ ពូជវារស និងវារគ្រាប់វែង
៤-ស្រូវមិនប្រកាន់រដូវ រួមមាន៖ ពូជសែនក្រអូប, សែនពិដោរ ,ជលសារ, អ៊ីអ៊ែរ៦៦ ,អ៊ីអ៊ែរ៨៥ និងនាងក្រអូប។

## 2.3.1.2 សម្រេចបាននូវការបន្សុទ្ធពូជសែនក្រអូប







បច្ចុប្បន្នស្រូវសែនក្រអូបកំពុងពេញនិយម និងមានតម្រូវការទីផ្សារនាំចេញច្រើន ជាពិសេសនាំចេញទៅទីផ្សារចិន ដោយសារពូជស្រូវនេះមានក្លិនក្រអូប បាយទន់ និងរសជាតិឆ្ងាញ់ ម្យ៉ាងទៀតស្រូវសែនក្រអូបជាប្រភេទពូជស្រូវមិនប្រកាន់រដូវដែលអាចផ្តល់លទ្ធភាពដល់កសិករធ្វើការដាំដុះបានច្រើនដងក្នុងមួយឆ្នាំ។ នេះជាចំណុចសក្តានុពលបើប្រៀបធៀបជាមួយពូជស្រូវក្រអូបផ្សេងទៀតដូចជា ផ្ការំដួល រំដេង រមៀតជាដើម ដែលប្រកាន់រដូវនិងអាចបង្កបង្កើនផលបានតែមួយដងប៉ុណ្ណោះក្នុងមួយឆ្នាំ។

បច្ចុប្បន្ន បញ្ហារបស់ពូជស្រូវសែនក្រអូបគឺប្រជាកសិករធ្វើការដាំដុះតៗគ្នា ភាពសុទ្ធ គុណភាពនិងរូបរាងមានលក្ខណៈមិនទៅតាមស្តង់ដារនៃពូជដោយប្រែប្រួលទៅតាមតំបន់ខុសៗគ្នា ហើយអ្វីដែលសំខាន់នោះគឺស្រូវសែនក្រអូបពុំទាន់បានចុះបញ្ជី(Register) បញ្ចេញ(Release) និងទទួលស្គាល់ជាផ្លូវការត្រឹមត្រូវនៅឡើយ។

ដោយមើលឃើញបញ្ហាខាងលើ គណៈកម្មាធិការផលិតកម្មនិងពូជស្រូវនៃសហព័ន្ធស្រូវអង្ករកម្ពុជាបានសហការជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI)និងដៃគូអភិវឌ្ឍន៍កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា(CAVAC)បង្កើត"គម្រោងបន្សុទ្ធពូជស្រូវសែនក្រអូប" ឡើងកាលពាក់កណ្តាលឆ្នាំ២០១៦កន្លងមកនេះ ក្នុងគោលបំណងបន្សុទ្ធពូជស្រូវសែនក្រអូបឲ្យមានស្តង់ដារតែមួយ មានគុណភាពនិងរូបរាងល្អសម្រាប់ទីផ្សារនាំចេញ និងទទួលបានការចុះបញ្ជីត្រឹមត្រូវតាមផ្លូវច្បាប់។ គម្រោងនេះត្រូវបានបញ្ចប់ និងកំពុងរៀបចំចុះបញ្ជីត្រឹមត្រូវតាមផ្លូវការនៅឆ្នាំ២០១៩នេះ។

## 2.3.1.2 កំពុងបង្កាត់ពូជផ្ការំដួលមិនប្រកាន់រដូវ

គម្រោងបង្កាត់ពូជស្រូវផ្ការំដួលមិនប្រកាន់ ចាប់ផ្តើមអនុវត្តនៅខែឧសភា ឆ្នាំ២០១៧ ស្របពេលនឹងគម្រោងបន្សុទ្ធពូជស្រូវសែនក្រអូបកំពុងដំណើរការ។ តាមរយៈគម្រោងនេះកម្ពុជា រំពឹងទទួលបានពូជស្រូវក្រអូបប្រណីតដែលមិនប្រកាន់រដូវថ្មីមួយទៀតក្នុងពេលខាងមុខនេះ។ តាមរយៈលទ្ធផលនៃការធ្វើបន្សុទ្ធពូជស្រូវផ្ការំដួលមិនប្រកាន់រដូវនេះ នៅមិនទាន់ទទួលបានលទ្ធផលដែលអាចចុះបញ្ជីនិងផ្សព្វផ្សាយបាននោះទេ។

## 2.3.2 រៀបចំការប្រកួតជ្រើសរើសជ័យលាភីសហគមន៍ដាំដុះស្រូវល្អជាងគេបំផុតប្រចាំកម្ពុជា



ដើម្បីជំរុញទឹកចិត្តនិងផ្តល់កិត្តិយសដល់អ្នកផលិតស្រូវ ចូលរួមផ្សព្វផ្សាយពីប្រភេទស្រូវដែលមានសក្តានុពលសម្រាប់នាំចេញអង្ករ ជាពិសេសដើម្បីរក្សាបាននូវគុណភាពគ្រាប់ស្រូវពូជសុទ្ធល្អ។ សហព័ន្ធស្រូវអង្ករកម្ពុជាបានផ្តួចផ្តើមឱ្យមានការរៀបចំប្រកួតស្រូវល្អបំផុតប្រចាំប្រទេសកម្ពុជាចំនួន៣លើក៖

- លើកទី១ រៀបចំធ្វើនៅឆ្នាំ២០១៦ មានសហគមន៍កសិកម្ម រោងម៉ាស៊ីនកិនស្រូវចំនួន៤០ មកពីទូទាំងប្រទេសបានដាក់សំណាកស្រូវល្អបំផុតចូលរួមការប្រកួត។

- ដោយទទួលបានការគាំទ្រពីអ្នកផលិតស្រូវជាពិសេសសហគមន៍កសិកម្ម ស.អ.ក បានរៀបចំការប្រកួតស្រូវល្អបំផុតលើកទី២ នៅដើមឆ្នាំ២០១៨ មានសហគមន៍កសិកម្មចំនួន៣២ សំណាកស្រូវ៤៤ដាក់ចូលរួមប្រកួត ស.អ.ក. បានផ្តល់រង្វាន់លើកទឹកចិត្តជាជីចំនួន៣តោន។

- និងលើកទី៣ នៅដើមឆ្នាំ២០១៩ មានសហគមន៍កសិកម្មចំនួន៤៥ និងមាន៦៦សំណាកស្រូវដាក់ស្រូវចូលរួមប្រកួត។ ប្រភេទស្រូវផ្ការំដួល ស្រូវសែនក្រអូប និងស្រូវអ៊ីអ៊ែរគ្រាប់វែង ជាប្រភេទស្រូវត្រូវបានដាក់ឱ្យប្រកួតដើម្បីស្វែងរកជ័យលាភីប្រចាំឆ្នាំនីមួយៗ។ សម្រាប់ការប្រកួតស្រូវល្អបំផុតលើកទី៣ ដែលប្រព្រឹត្តទៅកាលពីដើមឆ្នាំ២០១៩ កន្លងមកនេះ ស.អ.ក. បានផ្តល់រង្វាន់លើកទឹកចិត្តជាម៉ាស៊ីនព្រោះគ្រាប់ស្រូវជាជួរ (Eli Seeder) ចំនួន៣គ្រឿងដល់សហគមន៍ដែលទទួលបានជ័យលាភី។

**ជ័យលាភីស្រូវល្អជាងគេបំផុតប្រចាំប្រទេសកម្ពុជា រួមមាន៖**

**ជ័យលាភីស្រូវល្អបំផុតប្រចាំប្រទេសកម្ពុជាលើកទី៣ ប្រចាំឆ្នាំ២០១៨**
- ពានរង្វាន់ស្រូវផ្ការំដួល បានទៅលើសហគមន៍ស្វាយរន្ទអមតៈខេត្តតាកែវ
- ពានរង្វាន់ស្រូវសែនក្រអូប បានទៅលើសហគមន៍ជ្រៃសាមគ្គីបង្កើនផល ខេត្តបាត់ដំបង
- ពានរង្វាន់ស្រូវអ៊ីអែរ បានទៅលើសហគមន៍អភិវឌ្ឍន៍សង្គមកម្ពុជា ខេត្តកំពង់ឆ្នាំង

**ជ័យលាភីស្រូវល្អបំផុតប្រចាំប្រទេសកម្ពុជាលើកទី២ ប្រចាំឆ្នាំ២០១៧**
- ពានរង្វាន់ស្រូវផ្ការំដួលល្អបំផុតរបស់កម្ពុជា បានទៅលើសហគមន៍កសិកម្មជ្រៃសាមគ្គីបង្កើនផល ខេត្តបាត់ដំបង
- ពានរង្វាន់ស្រូវសែនក្រអូបរបស់កម្ពុជា បានទៅលើសហគមន៍កសិកម្មអូរសារាយ ខេត្តតាកែវ
- ពានរង្វាន់ស្រូវអ៊ីអែររបស់កម្ពុជា បានទៅលើសហគមន៍កសិករប្រើប្រាស់ទឹកពីងពង់ ខេត្តបន្ទាយមានជ័យ

**ជ័យលាភីស្រូវល្អបំផុតប្រចាំប្រទេសកម្ពុជាលើកទី១ ប្រចាំឆ្នាំ២០១៦**
- ពានរង្វាន់ស្រូវល្អបំផុតផ្ការំដួលរបស់កម្ពុជា បានទៅលើសហគមន៍សង្ការផល ខេត្តបាត់ដំបង





រង្វាន់ Eli Seeders សម្រាប់សហគមន៍កសិកម្ម
ដែលបានទទួលជ័យលាភីស្រូវល្អបំផុត កាលពីខែកុម្ភៈ ឆ្នាំ២០១៩

## 2.3.3 ជំរុញការអនុវត្តកិច្ចសន្យាកសិកម្មរវាងរោងម៉ាស៊ីនឬក្រុមហ៊ុននាំចេញជាមួយសហគមន៍កសិកម្ម

ផលិតកម្មកសិកម្មតាមកិច្ចសន្យា គឺជាយន្តការមួយក្នុងការអភិវឌ្ឍវិស័យកសិកម្មដែលអាចជួយឱ្យកសិករទទួលបានស្ថេរភាពចំណូល បច្ចេកទេសផលិត បង្កើនបរិមាណ និងគុណភាព ជួយដល់កសិករឲ្យមានជម្រើសសម្រាប់លក់ផលិតផល កាត់បន្ថយហានិភ័យផ្នែកទីផ្សារ អាចប៉ាន់ស្មានពីចំណូលនិងផែនការចំណាយ ព្រមទាំងអាចទទួលបាននូវប្រាក់កម្ចីដើម្បីបម្រើការផលិតផងដែរ ទន្ទឹមនេះផលិតកម្មកសិកម្មតាមកិច្ចសន្យាក៏អាចធានាបាននូវបរិមាណនិងគុណភាពនៃផលិតផលតាមតម្រូវការរបស់ឈ្មួញទិញស្រូវ រោងម៉ាស៊ីនកិនកែច្នៃ ឬអ្នកនាំចេញ ព្រមទាំងអាចកាត់បន្ថយបញ្ហាកង្វះខាតវត្ថុធាតុដើម កាត់បន្ថយការខាតបង់ក្នុងចង្វាក់ផលិតកម្ម និងកាត់បន្ថយថ្លៃដើមក្នុងការផលិតទៀតផង រីឯអ្នកប្រើប្រាស់វិញក៏ទទួលអត្ថប្រយោជន៍ក្នុងការទទួលបានផលិតផលដែលមានគុណភាពល្អ និងសុវត្ថិភាព។

ដោយយល់ឃើញពីសារៈសំខាន់និងភាពចាំបាច់នៃផលិតកម្មកសិកម្មតាមកិច្ចសន្យា សហព័ន្ធស្រូវអង្ករបានដាក់បញ្ចូលគម្រោងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ២០១៧-២០២១ ព្រមទាំង ជំរុញដល់សមាជិករបស់ខ្លួនដែលជាក្រុមហ៊ុននាំចេញ រោងម៉ាស៊ីនកិនស្រូវ និងសហគមន៍កសិកម្មធ្វើកិច្ចសន្យាកសិកម្មនឹងគ្នា។ ជាមួយគ្នានេះកាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨ គណៈកម្មាធិការផ្នែកពូជនិងផលិតកម្មស្រូវបានប្រជុំពិភាក្សាដើម្បីរៀបចំសេចក្តីព្រាងផែនការអនុវត្តគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យានេះ។

## 2.3.4 កម្មវិធីពង្រឹងសហគមន៍៖ គម្រោងវេទិកាគ្រាប់ពូជជាមួយគម្រោង JICA និងសិក្ខាសាលាជាមួយ GIZ កសាងសមត្ថភាព

ការយល់ដឹងអំពីពូជស្រូវនិងការប្រើប្រាស់គ្រាប់ស្រូវពូជរបស់កសិករនិងសហគមន៍កសិករនៅតែជាបញ្ហាប្រឈមធំមួយក្នុងវិស័យស្រូវអង្ករកម្ពុជា ដើម្បីលើកកម្ពស់ការយល់ដឹងដល់ប្រជាកសិករអំពីសារៈសំខាន់នៃពូជស្រូវ កសាងសមត្ថភាពនិងការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវក៏ដូចជាធានានូវនិរន្តរភាពនៃការផ្គត់ផ្គង់គ្រាប់ពូជស្រូវ សហព័ន្ធស្រូវអង្ករកម្ពុជានិងគម្រោងជំរុញផលិតកម្មនិងការប្រើប្រាស់គ្រាប់ពូជស្រូវនៃអង្គការ JICA បានសហការគ្នាបានរៀបចំវេទិកាស្តីពីគ្រាប់ពូជស្រូវនៅតាមខេត្តគោលដៅចំនួន៤ រួមមានខេត្តបាត់ដំបង កំពង់ឆ្នាំង ព្រៃវែង និងខេត្តតាកែវ។ ការរៀបចំវេទិកាស្តីពីគ្រាប់ពូជស្រូវលើកទី១ បានរៀបចំនៅខេត្តព្រៃវែងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ លើកទី២នៅខេត្តបាត់ដំបងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ លើកទី៣នៅខេត្តតាកែវថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩ និងបន្តធ្វើលើកទី៤ខេត្តកំពង់ឆ្នាំងនាពេលខាងមុខ។តាមរយៈបុគ្គលិកសម្របសម្រួលការងារប្រចាំតំបន់នៃលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា បានសហការនៅមូលដ្ឋានជាមួយដៃគូអភិវឌ្ឍន៍មកពីស្ថានប័នជាតិ និងអន្តរជាតិ រួមមាន ទីភ្នាក់ងារកិច្ចសហប្រត្តិបត្តិការអាល្លឺម៉ង់(GIZ) ទីភ្នាក់ងារកិច្ចសហប្រត្តិបត្តិការជប៉ុន(JICA) អង្គការអាដារីដា អង្គការកែប្រែសហគមន៍កសិកម្ម(CTO) អង្គការស្បៀងអាហារពិភពលោក(World Food Program) វិទ្យាស្ថានអភិវឌ្ឍន៍ដំណាំស្រូវកម្ពុជា(IRRI) និងCAVAC ព្រមទាំងអង្គការស្ថានប័នមួយចំនួនផ្សេងទៀត។ដោយឡែកកន្លងមកហូតដល់បច្ចុប្បន្ននេះ ទីភ្នាក់ងារកិច្ចសហប្រត្តិបត្តិការអាល្លឺម៉ង់(GIZ)បានសហការជាមួយសហព័ន្ធស្រូវអង្ករ និងមន្ទីរពាក់ព័ន្ធរៀបចំប្រជុំនិងសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករ ក្នុងនោះមានសហគមន៍កសិកម្ម ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម។



វេទិកាស្តីពីគ្រាប់ពូជស្រូវលើកទី១ បានរៀបចំនៅខេត្តព្រៃវែងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩

កម្មវិធីប្រជុំនិងសិក្ខាសាលាពិគ្រោះយោបល់សំខាន់ដូចមានរៀបរាប់ខាងក្រោម៖
- សិក្ខាសាលា អ្នកពាក់ព័ន្ធដើម្បីកែលម្អការភ្ជាប់ទៅដំណាំស្រូវ នៅខេត្តឧត្តរមានជ័យ
- សិក្ខាសាលា ស្តីពីលក្ខខណ្ឌតម្រូវរបស់រោងម៉ាស៊ីនកិនស្រូវ (ស្តង់ដារគុណភាពស្រូវទៅតាមលក្ខខណ្ឌបច្ចេកទេស)នៅពេលទិញពីកសិករនៅខេត្តឧត្តរមានជ័យ
- សិក្ខាសាលា ស្តីពីការឆ្លុះបញ្ចាំងផលិតផលកសិកម្មដំណាំស្រូវនៅខេត្តឧត្តរមានជ័យ
- សិក្ខាសាលាស្តីពីកិច្ចសន្យាកសិកម្មនៅខេត្តសៀមរាប
- សិក្ខាសាលាស្តីពី បណ្តាញសហគមន៍កសិកម្មផលិតស្រូវពូជខេត្តឧត្តរមានជ័យ។ល។

គោលបំណងកម្មវិធីប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់ខាងលើនេះគឺទទួលបានចំណេះនិងបទពិសោធន៍ព្រមទាំងការកសាងនិងពង្រឹងសមត្ថភាពសហគមន៍កសិកម្មនិងភាគីពាក់ព័ន្ធនៃវិស័យស្រូវអង្ករដែលបានចូលរួមទាំងអស់គ្នា។

### 2.3.5 ផ្សព្វផ្សាយការហាមឃាត់ការប្រើប្រាស់ថ្នាំកសិកម្មដែលមានផ្ទុកសារធាតុគីមី Tricyclazole



បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងរបស់សហភាពអឺរ៉ុប(EU) ស្តីពីការហាមឃាត់អង្ករដែលមានកម្រិតផ្ទុកសារធាតុ Tricyclazole លើសពី 0.0១mg/kg រួចមក សហព័ន្ធស្រូវអង្ករកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់លើបញ្ហានេះ ព្រោះខ្លាចប៉ះពាល់ដល់ការនាំចេញអង្ករទៅទីផ្សារសហគមន៍អឺរ៉ុបនាពេលខាងមុខ។ សហព័ន្ធបានធ្វើការផ្សព្វផ្សាយបញ្ហានេះទៅកាន់គ្រប់មជ្ឈដ្ឋាន ព្រមទាំងបានស្នើដល់រាជរដ្ឋាភិបាលជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជួយផ្សព្វផ្សាយឲ្យកាន់តែទូលំទូលាយ និងរកវិធានការដោះស្រាយជាបន្ទាន់ផងដែរ។

ដើម្បីឲ្យការផ្សព្វផ្សាយពីបម្រាមរបស់សហភាពអឺរ៉ុបបានជ្រាបដល់កសិករ គណៈកម្មាធិការផលិតកម្មនិងពូជស្រូវ បានដាក់ទិសដៅការងារបន្ទាន់ដល់មន្ត្រីសម្របសម្រួលតាមតំបន់ទាំង៥ របស់សហព័ន្ធស្រូវអង្ករកម្ពុជាចុះផ្សព្វផ្សាយដល់សហគមន៍កសិកម្ម និងកសិករនៅតាមមូលដ្ឋានផ្ទាល់តែម្តង។

## 2.4 គណៈកម្មាធិការផ្នែកឥណទាននិងធនាគារ

( Executive Committee of  Finance and Banking )



ឧកញ៉ា ហ៊ុន ឡាក់

នៅក្នុងអាណត្តិទី២នេះ គណៈកម្មាធិការទទួលបន្ទុកដំណោះស្រាយហិរញ្ញវត្ថុ ត្រូវបានកែសម្រួលសមាសភាពក្រោមសេចក្តីប្រកាសលេខ១៥៨/១៦ ស.អ.ក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៦។ គណៈកម្មាធិការនេះ មានសមាសភាពចំនួន១០រូប ដែលជាតំណាងចូលរួមមកពីរោងម៉ាស៊ីន អ្នកនាំចេញ និងតំណាងធនាគារពាណិជ្ជ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ។ គណៈកម្មាធិការនេះ មានតួនាទីជួសមុខអោយក្រុមប្រឹក្សាភិបាល ក្នុងការចរចាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិ ធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុ ក្នុងការសម្រួលឥណទានដល់វិស័យស្រូវអង្ករ ស្វែងរកឥណទានមានការប្រាក់ទាប យុទ្ធសាស្ត្រហិរញ្ញវត្ថុ និងគំរូឥណទានដែលសម្រួលដល់ការទទួលឥណទាន។



## សមិទ្ធផលដែលគណៈកម្មាធិការសម្រេចបាន ៖

### 2.4.1 ការប្រែក្លាយធនាគារអភិវឌ្ឍន៍ជនបទទៅជាធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម

នៅក្នុងវេទិការាជរដ្ឋាភិបាល-វិស័យឯកជន កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសជាផ្លូវការប្រែក្លាយធនាគារអភិវឌ្ឍន៍ ទៅជាធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងបានទម្លាក់ទុនបន្ថែម ដើម្បីជួយសម្រួលឱ្យមានការផ្ដល់ឥណទានដល់វិស័យកសិកម្មកម្ពុជាកាន់តែមានភាពងាយស្រួលជាមួយអត្រាការប្រាក់សមរម្យ ដោយយោងតាមសំណើពីវិស័យឯកជន។

### 2.4.2 ឱកាសទទួលបានទុនបង្វិល និងពង្រីកការវិនិយោគ

ដើម្បីស្វែងយល់ពីបច្ចុប្បន្នភាពនៃតម្រូវការឥណទានជាក់ស្ដែងរបស់សមាជិកសហព័ន្ធស្រូវអង្ករ យើងបានសម្របសម្រួលក្នុងការជួបប្រជុំពិភាក្សាជាមួយធនាគារអភិវឌ្ឍន៍ជនបទនៅតាមបណ្ដាខេត្តនានា។ ក្រោយពីកិច្ចពិភាក្សានេះ រាជរដ្ឋាភិបាលបានទម្លាក់កញ្ចប់ថវិកាពិសេសដើម្បីសម្រួលដល់វិស័យស្រូវអង្ករលើកទី១ប្រមាណ២៧លានដុល្លារ និងលើកទី២ ប្រមាណ៣០លានដុល្លារ។ កញ្ចប់ថវិការនេះ ត្រូវបានគ្រប់គ្រងចាត់ចែងក្នុងការផ្ដល់កម្ចីដោយធនាគារអភិវឌ្ឍន៍ជនបទតាមរយៈបញ្ចាំស្តុក។ ប៉ុន្តែដោយសារការទទួលឥណទាននេះសមាជិកសមាជិកាបានត្អូញត្អែរថាមានការលំបាកនឹងទទួលបានណាស់ ទើបសហព័ន្ធស្រូវអង្ករកម្ពុជា បានជួបពិភាក្សានិងផ្ញើលិខិតទៅក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការត្រួតពិនិត្យសម្រួលដល់ការងារនេះ ដើម្បីធ្វើយ៉ាងណាឲ្យការទទួលឥណទាននេះ មានការងាយស្រួល និងផ្ដល់ដល់សមាជិកឲ្យបានច្រើន។ ជាមួយគ្នានេះ សហព័ន្ធស្រូវអង្ករកម្ពុជា ក៏បានស្នើសុំបង្កើតគណៈកម្មការឥណទាន (Rice Credit Committee) ដើម្បីធានាការចូលរួមផ្ដល់ព័ត៌មាននិងតាមដានត្រួតពិនិត្យនៃការផ្ដល់ឥណទានក្នុងវិស័យស្រូវអង្ករ ដោយមានការចូលរួមពីធនាគារពាណិជ្ជ ធនាគារអភិវឌ្ឍន៍ជនបទ សហព័ន្ធស្រូវអង្ករកម្ពុជា និងភាគីពាក់ព័ន្ធចូលរួម។

គំនិតត្រូវបានយកទៅពិចារណា និងត្រូវបានដាក់ក្នុងពង្រាងនៃគោលនយោបាយស្រូវអង្ករថ្មីផងដែរ។ វិស័យឯកជនសង្ឃឹមថាថ្នាក់ដឹកនាំធនាគារនឹងពិនិត្យឡើងវិញលើដំណើរការរបស់ខ្លួនក្នុងការផ្ដល់កម្ចីដល់វិស័យឯកជន ពិសេសដល់សហគមន៍កសិកម្ម និងរោងម៉ាស៊ីនកិនកែច្នៃឱ្យមានតម្លាភាព និងបានទូលំទូលាយជាងនេះ។

### 2.4.3. បង្កើន Credit Line ជាមួយនឹងអត្រាការប្រាក់សមរម្យ

ការចរចាជាមួយធនាគារពាណិជ្ជក្នុងការទទួលឥណទាន ស្របនឹងការពង្រីកទីផ្សារនៅបរទេស ដូចជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាមានិតបង់ក្លាដេស សហព័ន្ធស្រូវអង្ករកម្ពុជា បានជួបពិភាក្សាជាមួយធនាគារពាណិជ្ជធំៗ ដើម្បីស្វែងរកកិច្ចសហការសម្រួលដល់ការផ្ដល់ឥណទាន នៅពេលយើងមានទីផ្សារនៅបរទេសច្បាស់លាស់។ សម្រាប់ការសហការនេះ ត្រូវបានស្វាគមន៍ និងយល់ស្របដោយធនាគារពាណិជ្ជ នៅខែសីហា ឆ្នាំ២០១៧។

តាមរយៈការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល បានចេញសេចក្ដីសម្រេចមួយរវាងធនាគារជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការកំណត់អត្រាការប្រាក់របស់មីក្រូហិរញ្ញវត្ថុមិនឲ្យលើសពី១៨% កាលពីឆ្នាំ២០១៨កន្លងទៅនេះ។

### 2.4.4. ការបណ្ដុះបណ្ដាល៖



កត្តាមួយដែលតម្រូវដោយធនាគារ ដើម្បីទទួលបានឥណទាន គឺការមានបញ្ជីគណនេយ្យច្បាស់លាស់។ សហព័ន្ធស្រូវអង្ករកម្ពុជាបានសម្របសម្រួលជាមួយសមាជិករោងម៉ាស៊ីនក្នុងការចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការកត់បញ្ជីគណនេយ្យ ដែលបានរៀបចំនៅខេត្តបាត់ដំបងថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ដោយមានការគាំទ្រឧបត្ថមពី Acca Cambodia Dewey International Co., Ltd និង PCG & Partners។ អត្ថប្រយោជន៍នៃការបណ្ដុះបណ្ដាលនេះគឺដើម្បីឲ្យសមាជិករបស់សហព័ន្ធបានស្វែងយល់ពីមធ្យោបាយនៃការចុះបញ្ជីតាមប្រព័ន្ធគណនេយ្យដែលអាចរៀបចំចុះបញ្ជីជាភាសាខ្មែរ។ នាពេលថ្មីៗនេះ ប្រព័ន្ធចុះបញ្ជីនេះ ត្រូវបានសមាជិកមួយចំនួនបានអនុវត្តរួចហើយ។ជាមួយប្រព័ន្ធចុះបញ្ជីច្បាស់លាស់ ការទទួលឥណទានរបស់សមាជិកយើង ត្រូវបានរំពឹងថានឹងកាន់តែប្រសើរឡើងបន្ថែមទៀត។

### 2.4.5. ការស្រាវជ្រាវ

ដើម្បីស្វែងយល់ពីបញ្ហាប្រឈមផ្នែកឥណទានដែលសមាជិករបស់ខ្លួនកំពុងជួបប្រទះ សហព័ន្ធស្រូវអង្ករកម្ពុជាបានសហការជាមួយធនាគារជាតិនៃកម្ពុជា ស្រាវជ្រាវលើកសិករ រោងម៉ាស៊ីន អ្នកនាំចេញ ធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុ នៅក្នុង៨រាជធានីខេត្ត ដើម្បីស្វែងយល់ពីបច្ចុប្បន្នភាពនៃការទទួលឥណទាន និងងាយស្រួលស្វែងរកការជួយគាំទ្រពីរាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នហិរញ្ញវត្ថុ ក្នុងការជួយឧបត្ថម្ភទុន ឲ្យបានសមរម្យគ្រប់គ្រាន់ តាមតម្រូវការជាក់ស្ដែងក្នុងវិស័យស្រូវអង្ករ។លទ្ធផលនៃការស្រាវជ្រាវនេះ ក៏ត្រូវបានធ្វើបទបង្ហាញ និងផ្សព្វផ្សាយក្នុងគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា និងសហព័ន្ធស្រូវអង្ករកម្ពុជា ផងដែរ។

### 2.4.6. គម្រោងឃ្លាំង និងគំរូនៃការទទួលឥណទានតាមរយៈបញ្ចាំស្តុក

គម្រោងឃ្លាំង និងគំនិតនៃការបញ្ចាំស្តុកដើម្បីទទួលឥណទានត្រូវបានលើកឡើងដោយដៃគូអភិវឌ្ឍន៍ អ្នកសិក្សាស្រាវជ្រាវ ជាច្រើនឆ្នាំមកហើយ តែមិនទាន់មានរូបរាងនៅឡើយ។ សម្រាប់ការងារនេះ សហព័ន្ធស្រូវអង្ករកម្ពុជា បានធ្វើការជាមួយក្រុមហ៊ុនខេត្តជីលីន និងក្រុមហ៊ុនសោម៉ាគ្រុប ក្នុងការធ្វើគម្រោងឃ្លាំងសាកល្បង ដោយបានចុះអនុស្សរណៈយោគយល់គ្នាក្នុងខែមិថុនា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ។

## 2.5. គណៈកម្មាធិការកាត់បន្ថយថ្លៃដើម

Executive Committee of Cost of Competiveness



ឧកញ៉ា វង្ស ប៊ុនហេង

គណៈកម្មាធិការទទួលបន្ទុកលើការកែទម្រង់ថ្លៃដើម អាណត្តិទី២ មានសមាជិកចំនួន០៩រូបដែលមានសមាសភាពមកពីតំណាងរោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនអ្នកនាំចេញ ក្រុមហ៊ុន Logistic និងកសិករ ដោយមានឧកញ៉ា វង្ស ប៊ុនហេង អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងជាប្រធានគណៈកម្មាធិការនេះ។

ភារកិច្ចសំខាន់ៗរបស់គណៈកម្មាធិការទទួលបន្ទុកលើការកែទម្រង់ថ្លៃដើម រួមមាន៖

- សិក្សាលើថ្លៃដើមនៃការដាំដុះ ការកិនកែច្នៃ ការវេចខ្ចប់ ការដឹកជញ្ជូន ការធ្វើឯកសារនាំចេញអង្ករកម្ពុជា រួចរកដំណោះស្រាយរួមជាមួយរាជរដ្ឋាភិបាល សេវាករ វិស័យឯកជន ក្នុងការជំរុញឲ្យមានការកាត់បន្ថយថ្លៃដើមផលិតកម្ម ការកែច្នៃនិងការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។
- ចរចាស្វែងរកដំណោះស្រាយជាមួយក្រសួង អាជ្ញាធរ អង្គភាពស្វយ័តរបស់រដ្ឋនិងបណ្តាក្រុមហ៊ុនផ្តល់សេវានានា ដែលពាក់ព័ន្ធដល់ដំណើរការផលិតកម្ម ការកិនកែច្នៃ និងការនាំចេញអង្កររបស់កម្ពុជា។
- ចរចាជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍នានា ដើម្បីស្វែងរកនូវកិច្ចសហប្រតិបត្តិការ កៀគររកជំនួយសម្រាប់ជួយដល់ការធ្វើសកម្មភាពការជំរុញឲ្យមានការវិនិយោគជួយឧបត្ថម្ភដល់វិស័យស្រូវអង្ករកម្ពុជា។

យោងតាមភារកិច្ចខាងលើ គណៈកម្មាធិការទទួលបន្ទុកលើការកែទម្រង់ថ្លៃដើម អាណត្តិទី២ បានរៀបចំកិច្ចប្រជុំលើកដំបូងកាលពីថ្ងៃទី១០ ខែវិច្ឆិកាឆ្នាំ២០១៦ និងបានដាក់ចេញទិសដៅការងារក្នុងអាណត្តិនេះ ដោយផ្តោតសំខាន់ទៅលើការងារបីគឺ ទី១-បន្តស្នើសុំបញ្ចុះតម្លៃអគ្គិសនីបន្ថែមទៀតទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងរ៉ែនិងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា (EDC) ទី២-ស្នើសុំបញ្ចុះតម្លៃ Terminal Handling Charge (THC) ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងសាធារណការនិងដឹកជញ្ជូននិង ទី៣-ជំរុញការអនុវត្តប្រកាសស្តីពី នីតិវិធីនៃការនាំចូលអង្ករពីបរទេសឲ្យបានខ្ជាប់ខ្ជួននិងមានប្រសិទ្ធិភាព ដើម្បីទប់ស្កាត់ការនាំចូលដោយខុសច្បាប់និងការក្លែងបន្លំអង្ករ។

តាមរយៈការកំណត់ទិសដៅការងាររបស់ខ្លួនខាងលើនិងដើម្បីឲ្យការនាំចេញអង្កររបស់កម្ពុជាកាន់តែមានភាពប្រកួតប្រជែងជាមួយបណ្តាប្រទេសនាំចេញអង្ករក្នុងពិភពលោកជាពិសេសប្រទេសជិតខាង គណៈកម្មាធិការកែទម្រង់ថ្លៃដើមបានធ្វើលិខិតនិងលើកសំណើក្នុងកិច្ចប្រជុំនិងជំនួបផ្សេងៗទៅ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ឲ្យជួយពិនិត្យនិងពិចារណាលើការកែសម្រួលកម្រៃសេវាផ្សេងៗ ដែលកំណត់ដោយ ក្រសួង ស្ថាប័ន ព្រមទាំងវិស័យឯកជនផងដែរ។

### សមិទ្ធផលដែលគណៈកម្មាធិការសម្រេចបាន ៖

### 2.5.1 កាត់បន្ថយចំណាយលើអគ្គិសនីទទួលបានជាបន្តបន្ទាប់

រយៈពេល៥ឆ្នាំមកនេះ សហព័ន្ធស្រូវអង្ករកម្ពុជាតែងបានលើកឡើងអំពីបញ្ហាថ្លៃអគ្គិសនីមានតម្លៃខ្ពស់ជាច្រើនលើកច្រើនសារដែលជាកត្តាមួយប៉ះពាល់ដល់ភាពប្រកួតប្រជែងការនាំចេញជាមួយនឹងប្រទេសជិតខាង។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ថ្លៃអគ្គិសនីនៅកម្ពុជាខ្ពស់ជាងប្រទេសជិតខាង។ ក្នុងបំណងកាត់បន្ថយជាបណ្តើរៗនូវថ្លៃអគ្គិសនីនៅកម្ពុជាឱ្យមានកម្រិតប្រហាក់ប្រហែលនឹងប្រទេសជិតខាង រាជរដ្ឋាភិបាលបានធ្វើការវិនិយោគលើវិស័យនេះយ៉ាងច្រើនសន្ធឹកសន្ធាប់ទាំងលើរោងចក្រផលិតនិងបណ្តាញខ្សែបញ្ជូនចរន្តអគ្គិសនី។ លើមូលដ្ឋាននេះតម្លៃប្រើប្រាស់អគ្គិសនីនឹងមានតម្លៃកាន់តែធូរថ្លៃពីមួយឆ្នាំទៅមួយឆ្នាំ ជាក់ស្តែងឆ្នាំ២០១៩នេះរាជរដ្ឋាភិបាលបានកាត់បន្ថយថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ រួមទាំងការកាត់បន្ថយថ្លៃអគ្គិសនីចំនួន ២សេនដុល្លារក្នុង ១គីឡូវ៉ាត់ម៉ោងសម្រាប់អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម ដែលទិញតាមខ្សែបញ្ជូនរង និងខ្សែតង់ស្យុងមធ្យមនៅតំបន់ចែកចាយផង។





ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអគ្គិសនីកម្ពុជា

សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

[illegible]

## 2.5.2. កាត់បន្ថយថ្លៃលើកដាក់ ( LoLo Fee ) ថ្លៃត្រួតពិនិត្យ ថ្លៃស្កេនកុងទីន័រអង្ករ ដោយបានសហការជាមួយកំពង់ផែក្រុងព្រះសីហនុ និងកំពង់ផែភ្នំពេញ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
អគ្គនាយកដ្ឋានដឹកជញ្ជូន

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៧

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ:** របាយការណ៍កិច្ចប្រជុំ ស្តីពី សេវាក្រៅផ្លូវការ លើការងារដឹកជញ្ជូន ។

ខ្ញុំបាទសូមគោរពរាយការណ៍ជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបថា នាព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ក្រសួងសាធារណការ និងដឹកជញ្ជូន បានរៀបចំកិច្ចប្រជុំមួយដើម្បីស្វែងរកដំណោះស្រាយលើការចំណាយក្រៅផ្លូវការលើការងារដឹកជញ្ជូន ក្រោមអធិបតីភាព **ឯកឧត្តម តូច ចាន់កុសល** រដ្ឋលេខាធិការ និងមានការអញ្ជើញចូលរួមពីក្រសួង/ស្ថាប័នពាក់ព័ន្ធ ជាមួយនឹងវិស័យឯកជនផងដែរ។ បញ្ជីអ្នកចូលរួមមានជូនភ្ជាប់ជាមួយ។

ឯកឧត្តមរដ្ឋលេខាធិការ បានជម្រាបជូនអង្គប្រជុំថា តាមរបាយការណ៍ដែលវិស័យឯកជន បានរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺតម្លៃក្រៅផ្លូវការលើការងារដឹកជញ្ជូន មានរហូតដល់ ៤៨% ដែលធ្វើឱ្យតម្លៃដឹកជញ្ជូនរបស់កម្ពុជាខ្ពស់ជាងប្រទេសជិតខាង បង្កឱ្យបាត់បង់ការប្រកួតប្រជែងក្នុងតំបន់ដែលយើងទាំងអស់គ្នាត្រូវរួមគ្នាដោះស្រាយ។ តាមការសិក្សាកន្លងមក តម្លៃដឹកជញ្ជូនពិតប្រាកដនៅកម្ពុជា មិនថ្លៃជាងប្រទេសជិតខាងទេ ក៏ប៉ុន្តែរួមកម្រៃសេវាផ្សេងៗជាច្រើនមុខ មានជាអាទិ៍ គយ កំពង់ផែ កាំសាប អន្តោប្រវេសន៍ កាំកុងត្រូល និងសន្តិសុខ ដែលសរុបទៅធ្វើឱ្យតម្លៃភស្តុភាកម្មទាំងមូល ខ្ពស់។

ឯកឧត្តមប្រធានអង្គប្រជុំ បានបើកវេទិកា ឱ្យគ្រប់ភាគីពាក់ព័ន្ធចូលរួមយោបល់ ត្រង់ត្រង់តាមការជួបប្រទះជាក់ស្តែង៖

**១. មតិតំណាងសហព័ន្ធស្រូវអង្ករកម្ពុជា**

- ស្នើរាជរដ្ឋាភិបាលធ្វើច្បាប់ ដើម្បីគ្រប់គ្រងការផ្តល់សេវាកម្មរបស់ក្រុមហ៊ុនឯកជនផង ព្រោះថាក្រុមហ៊ុនឯកជនក៏មានចំណែកក្នុងការយកកម្រៃក្រៅផ្លូវការដែរ មិនមែនតែស្ថាប័នរដ្ឋទេ។ ហើយពួកគេតម្លើងថ្លៃតាមអំពើចិត្ត ដូចជាថ្លៃ Seal ១០$/កុងតេន័រ។
- ចំពោះស្ថាប័នរដ្ឋបច្ចុប្បន្ន ហាក់មិនមានការយកកម្រៃក្រៅផ្លូវការទេក៏ប៉ុន្តែតម្លៃផ្លូវការនៅខ្ពស់ពេក ដូចជា ថ្លៃនៅកំពង់ផែ ថ្លៃប្រតិវេទន៍គយ ថ្លៃ Scan ។ល។
- ស្នើអគ្គនាយកដ្ឋានគយ លុបចោលថ្លៃប្រតិវេទន៍ ១៥០០០៛ និងបញ្ចុះថ្លៃ Scan (បច្ចុប្បន្ន 20$ សម្រាប់ 20fts និង 32$ សម្រាប់ 40fts) ឬអាចលប់ចោលកាត់ព្វកិច្ច Scan តែម្តង ព្រោះអ្នករកស៊ីអង្ករ គេមិនដាក់អ្វីក្រៅពីអង្ករ នាំខូចឈ្មោះនោះទេ។

**២. មតិប្រធានសមាគមភ្នាក់ងារបញ្ជូនទំនិញកម្ពុជា (CAMFFA)**

- អាជីវកម្មស្រូវអង្ករទទួលបានការអនុគ្រោះច្រើន សូមឱ្យមានការអនុគ្រោះដល់មុខទំនិញផ្សេងៗផង។
- កាន់តែមានចំណុចប្រសើរច្រើនហើយ ក្រោយពីមានអន្តរាគមន៍ពីរាជរដ្ឋាភិបាល ដូចជា៖
  - កាំសាប បានចុះតម្លៃ ១០% ហើយ។

នាកិច្ចប្រជុំស្តីពីសេវាក្រៅផ្លូវការលើការងារដឹកជញ្ជូន ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១០ មករា ២០១៧ ដឹកនាំប្រជុំដោយ ឯកឧត្តម តូច ចាន់កុសល រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងកិច្ចប្រជុំនោះគណៈកម្មាធិការទទួលបន្ទុកលើការកែទម្រង់ថ្លៃដើមបានលើកបញ្ហាការយកកម្រៃសេវា Terminal Handling Charge (THC) ក្នុងតម្លៃខ្ពស់ហើយមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ គណៈកម្មាធិការបានស្នើសុំដល់ក្រសួងសាធារណការនិងដឹកជញ្ជូនជួយពិនិត្យឡើងវិញលើការយកកម្រៃសេវាលើតម្លៃ THC និងសេវាផ្សេងៗ របស់ក្រុមហ៊ុនឯកជនដែលមានតម្លៃខ្ពស់និងចេះតែកើនឡើងនេះ។

សហព័ន្ធស្រូវអង្ករកម្ពុជាបានពិនិត្យឃើញថា ថ្លៃឡូជីស្ទីកនៅក្នុងប្រទេសកម្ពុជាមានតម្លៃខ្ពស់បើធៀបជាមួយប្រទេសជិតខាង។ ស.អ.ក បានលើកពីបញ្ហានេះនិងសំណូមពរទៅក្រសួង ស្ថាប័នពាក់ព័ន្ធជាពិសេស ក្រសួងសាធាណការ និងដឹកជញ្ជូន និងតាមរយៈក្រុមការងារទី៩ផងដែរ ហើយទទួលបានលទ្ធផលបញ្ចុះថ្លៃដូចខាងក្រោម៖

- ការបញ្ចុះថ្លៃលើកដាក់ (LOLO Fee)៖ ទទួលបានការបញ្ចុះថ្លៃពី ៤៤ដុល្លារមកនៅត្រឹម ២២ដុល្លារសម្រាប់កំពង់ផែព្រះសីហនុ និងពី៤៨ដុល្លារ មកនៅត្រឹម៣៦ដុល្លារ សម្រាប់កំពង់ផែភ្នំពេញ។ ការបញ្ចុះថ្លៃនេះសម្រាប់តែសមាជិក សមាជិកនៃសហព័ន្ធស្រូវអង្ករកម្ពុជាតែប៉ុណ្ណោះ។
- ការបញ្ចុះថ្លៃស្កេនលើមុខទំនិញអង្ករនាំចេញដឹកជញ្ជូនក្នុងកុងតេន័រ៖ តាមរយៈការស្នើសុំរបស់ ស.អ.ក ថ្លៃស្កេនកុងតេន័រលើមុខទំនិញអង្ករនាំចេញទទួលបានការកាត់បន្ថយថ្លៃពាក់កណ្តាលពី២០ដុល្លារ មកនៅត្រឹម ១០ដុល្លារ សម្រាប់កុងតេន័រដែលមានទំហំក្រោម៤០ហ្វីត និងពី ៣២ដុល្លារ មកនៅត្រឹម១៦ដុល្លារ សម្រាប់កុងតេន័រដែលមានទំហំចាប់ពី៤០ហ្វីតឡើង តាំងពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ យោងតាមលិខិតលេខ ៨៤៨៩ សហវ. ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លើសពីនេះដើម្បីកាត់បន្ថយការកកស្ទះដោយសារការស្កេនកុងតេន័រនៅកំពង់ផែ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៣២៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលគោលការណ៍ និងនីតិវិធី នៃការកំណត់មុខសញ្ញានាំចេញ-នាំចូល ផ្ទុកក្នុងកុងតេន័រ ដែលត្រូវឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន។ ដោយអនុវត្តតាមគោលការណ៍ចំនួន ៣ គឺ៖ ទី ១- ស្កេនកុងតេន័រនាំចូលតាមប្រព័ន្ធគ្រប់គ្រងហានិភ័យ ទី២- កុងតេន័ររបស់ក្រុមហ៊ុនដែលមានអនុលោមភាពល្អ (Best Trader) មិនចាំបាច់តម្រូវឲ្យស្កេនគ្រប់ពេលវេលានោះទេ ដើម្បីជាការលើកទឹកចិត្ត និង ទី៣- ចំពោះអ្នកត្រូវការបញ្ចេញទំនិញនៅផែស្ងួត គឺត្រូវស្កេននៅទីនោះ ដោយមិនចាំបាច់ស្កេននៅកំពង់ផែនោះទេ។ ប្រកាសនេះបានចូលជាធរមាននៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩។
- ថ្លៃលើកដាក់នៅចំណត (Terminal Handling charge-THC)៖ ក្រុមហ៊ុននាវាមួយចំនួន បានយល់ព្រមបញ្ចុះថ្លៃសេវារបស់ខ្លួនពី៥ ដុល្លារ/TEU លើសេវាលើកដាក់កុងតឺន័រលើចំណត។ ចំពោះថ្លៃនេះ ក្រុមហ៊ុនបានអះអាងថា នឹងមានការបញ្ចុះបន្ថែមទៀត ប្រសិនបើកំពង់ផែមានការបញ្ចុះថ្លៃ។
- ការលើកលែងកម្រៃសេវាត្រួតពិនិត្យការនាំចេញទំនិញអង្ករ៖ ការនាំចេញទំនិញអង្ករបានទទួលការលើកលែងការយកកម្រៃសេវាត្រួតពិនិត្យការនាំចេញអង្ករចំនួន ២៥០០០រក្នុង 1 shipment តាមរយៈប្រកាសរួមលេខ ១៥០៥ សហវ.ប្រ.ក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងពាណិជ្ជកម្ម។
- ថ្លៃដឹកជញ្ជូនតាមផ្លូវសមុទ្រ (Ocean Freight Charge-OFC)៖ ក្រុមហ៊ុន SITC Logistics Cambodia បានយល់ព្រមបញ្ចុះ៥០% នៃថ្លៃសម្រាប់ការដឹកជញ្ជូន ពាក់ព័ន្ធនឹងការនាំចេញអង្ករទៅប្រទេសចិន ក្រុមហ៊ុននេះ ក៏អនុញ្ញាតផងដែរឲ្យក្រុមហ៊ុនដទៃទៀត អាចប្រើប្រាស់កុងតេន័ររបស់ខ្លួនគឺ SITC Logistics Cambodia ដើម្បីដឹកអង្ករទៅប្រទេសចិនដោយឥតគិតថ្លៃ។

## 2.5.3 លើកលែងពន្ធអាករបន្ថែម VAT លើកលែងពន្ធដែលមិនបានបង់មុនឆ្នាំអនុគ្រោះ និងលើកលែងពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំសម្រាប់ការនាំចេញអង្ករ

តាមរយៈយន្តការភាពជាដៃគូអគ្គនាយកដ្ឋានពន្ធដារ-ផ្នែកឯកជន ក្រុមការងារបច្ចេកទេសទី៣ ស្តីពីពន្ធដារ-ស្រូវអង្ករ និងសហគ្រិនវ័យក្មេង គណៈកម្មាធិការទទួលបន្ទុកលើការកែសម្រួលថ្លៃដើមរបស់សហព័ន្ធស្រូវអង្ករកម្ពុជា បានស្នើសុំអគ្គនាយកពន្ធដារពិនិត្យនិងលើកលែងប្រាក់ពន្ធលើតម្លៃបន្ថែម (VAT) និងប្រាក់ពិន័យលើឆ្នាំចាស់ៗ (មុនឆ្នាំ២០១៦) មុនពេលប្រកាសលើកលែង VAT ព្រោះរោងម៉ាស៊ីនកិនស្រូវស្ទើរតែ១០០% មិនបានបូកអាករនេះចូលទៅក្នុងតម្លៃអង្ករទេ។

ជាលទ្ធផលអគ្គនាយកដ្ឋានពន្ធដារកម្ពុជាទទួលស្គាល់បញ្ហាដែលបានលើកឡើងដោយផ្នែកឯកជន និងជួយសម្របសម្រួលបញ្ហាទាំងនេះឲ្យផ្នែកឯកជន៖

- ទី១-បើរោងម៉ាស៊ីនកិនស្រូវពុំធ្លាប់បានបូក VAT លើតម្លៃអង្ករពេលលក់ចេញនោះទេ អគ្គនាយកដ្ឋានពន្ធដារកម្ពុជាស្នើដល់ផ្នែកឯកជនដាក់ពាក្យស្នើសុំការលើកលែង VAT មកអគ្គនាយកដ្ឋានពន្ធដារកម្ពុជាដោយផ្ទាល់ រួមជាមួយឯកសារជាសារវន្តដែលបញ្ជាក់ថាផ្នែកឯកជនពុំធ្លាប់បានបូក VAT លើតម្លៃអង្ករពេលលក់ចេញនោះពិតប្រាកដមែន។
- ទី២-បើឯកសារជាសារវន្តបញ្ជាក់ថា រោងម៉ាស៊ីនកិនស្រូវបានបូក VAT លើតម្លៃអង្ករពេលលក់ចេញនោះតម្រូវឲ្យផ្នែកឯកជនទូទាត់ VAT មកឲ្យអគ្គនាយកដ្ឋានពន្ធដារ។

គណៈកម្មាធិការកាត់បន្ថយថ្លៃដើមនៃសហព័ន្ធស្រូវអង្ករកម្ពុជាបានស្នើសុំយ៉ាងទទូចដល់អគ្គនាយកពន្ធដារដើម្បីអនុគ្រោះការបង់ពន្ធរហូតទទួលបានការលើកលែងការបង់ពន្ធជាច្រើនដូចជា៖

- ការលើកលែងអាករលើតម្លៃបន្ថែម (VAT) ដែលអនុវត្តចំពោះសហគ្រាសផលិតនិងផ្គត់ផ្គង់ស្រូវ អង្ករ អង្កាម កន្ទក់ កម្ទេចចុងអង្ករ។
- ការលើកលែងពន្ធអប្បរមា ១% លើផលរបរប្រចាំឆ្នាំចំពោះសហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ។
- ទទួលការលើកលែងបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ១% លើផលរបរប្រចាំខែក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញជាអតិបរមាដែលក្នុងនោះមានរយៈពេលគន្លឹះ បូកនឹងរយៈពេល៣ឆ្នាំ បូកនឹងរយៈពេលអាទិភាព៣ឆ្នាំទៀត។

### 2.5.4 ការសម្រួលកម្រៃស្កេនរបស់ស្ថាប័នគយ

តាមរយៈលិខិតលេខ ៨៤៨៩ សហវ. ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចកែសម្រួលជាបណ្តោះអាសន្ននូវកម្រៃត្រួតពិនិត្យតាមប្រព័ន្ធម៉ាស៊ីនស្កេនលើមុខទំនិញអង្ករនាំចេញដឹកជញ្ជូនកុងតេន័រដូចខាងក្រោម៖

- **១៦ ដុល្លារអាមេរិក សម្រាប់កុងតេន័រដែលមានទំហំចាប់ពី៤០ហ្វីតឡើង**
- **១០ ដុល្លារអាមេរិក សម្រាប់កុងតេន័រដែលមានទំហំក្រោម ៤០ហ្វីត។**

ការកែសម្រួលនេះនឹងមានសុពលភាពដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយនៅពេលផុតសុពលភាពនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើកែសម្រួលជាថ្មីនូវកម្រៃត្រួតពិនិត្យតាមប្រព័ន្ធម៉ាស៊ីនស្កេនលើមុខទំនិញអង្ករ។

### 2.5.5 លុបចោលរបាំងពាណិជ្ជកម្មនានា និងកាំសាប ជាដើម



នៅក្នុងវេទិការាជរដ្ឋាភិបាល-វិស័យឯកជន កាលពីថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១៩ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសជាផ្លូវការប្រែក្លាយធនាគារអភិវឌ្ឍន៍ទៅជាធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងបានទម្លាក់ទុនបន្ថែម ដើម្បីជួយសម្រួលឱ្យមានការផ្តល់ឥណទានដល់វិស័យកសិកម្មកម្ពុជាកាន់តែមានភាពងាយស្រួលជាមួយអត្រាការប្រាក់សមរម្យ ដោយយោងតាមសំណើពីវិស័យឯកជន។

ការដកចេញស្ថាប័នមួយចំនួនពីមាត់ច្រកព្រំដែន និងការលុបចោលកាំសាប គឺជាការកែទម្រង់ជារចនាសម្ព័ន្ធដ៏មុតស្រួចមួយ ដែលរាជរដ្ឋាភិបាលបានដាក់ចេញក្នុងបំណងកាត់បន្ថយបន្ទុកចំណាយ និងបន្ទុករត់ការឯកសារជួយឱ្យចំណេញពេលវេលា និងការសម្រួលឲ្យបានជាអតិបរមាក្នុងការធ្វើពាណិជ្ជកម្ម។

## 2.6 គណៈកម្មាធិការក្រមសីលធម៌និងវិន័យ

Executive of Committee of Code of Conduct and Ethic



**លោក ហេង ផេង**

- គណៈកម្មាធិការក្រមសីលធម៌ និងវិន័យសហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) ត្រូវបានបង្កើតឡើងតាមសេចក្តីប្រកាសលេខ១៩៩/១៦ស.អ.ក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦។ បច្ចុប្បន្នគណៈកម្មាធិការក្រមសីលធម៌ និងវិន័យ មានសមាជិកសរុបចំនួន១០រូប ដែលមានសមាសភាពមកពីបណ្តាលរោងម៉ាស៊ីនកិនកែច្នៃ និងអ្នកនាំចេញអង្ករ។ គណៈកម្មាធិការនេះជាផ្នែកមួយដ៏សំខាន់ក្នុងការលើកស្ទួយការប្រតិបត្តិប្រកបដោយសុចរិតភាព សេចក្តីថ្លៃថ្នូរ ការគោរព និងការទទួលស្គាល់ នៅកម្រិតជាតិ និងអន្តរជាតិ ។
- គណៈកម្មាធិការក្រមសីលធម៌ និងវិន័យ មានគោលបំណងច្បាស់លាស់គឺដើម្បីទប់ស្កាត់ការនាំអង្ករពីប្រទេសជិតខាងដែលមិនត្រឹមត្រូវតាមច្បាប់ និងការពារផលប្រយោជន៍វិស័យស្រូវអង្ករកម្ពុជា ក៏ដូចជាការជួយដល់សមាជិករបស់ខ្លួនដែលកំពុងប្រឈមនឹងបញ្ហា ដែលបណ្តាលមកពីការនាំចូលអង្កររួចនាំចេញបន្តពីកម្ពុជា ក្រោមស្លាកឈ្មោះអង្ករកម្ពុជា ព្រមទាំងការប្រកួតប្រជែងតម្លៃទីផ្សារក្នុងស្រុក និងក្រៅប្រទេសផងដែរ។ លើសពីនេះ គណៈកម្មាធិការមានភារកិច្ចអនុវត្តការងារនៅក្នុងក្របខណ្ឌដែលមានចែងនៅក្នុងផែនការសកម្មភាព ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជាអាណត្តិទី២ ក្នុងគោលដៅជំរុញការងារឲ្យមានប្រសិទ្ធភាព។

### សមិទ្ធផលដែលគណៈកម្មាធិការសម្រេចបាន ៖

### 2.6.1 ទប់ស្កាត់និងប្រឆាំងអង្ករក្លែងក្លាយ

គណៈកម្មាធិការវិន័យ និងក្រមសីលធម៌ មានគោលបំណងច្បាស់លាស់គឺដើម្បីទប់ស្កាត់ការនាំអង្ករពីប្រទេសជិតខាងដែលមិនត្រឹមត្រូវតាមច្បាប់ និងការពារផលប្រយោជន៍ពីវិស័យស្រូវអង្ករនៅកម្ពុជា ក៏ដូចជាការជួយដល់សមាជិករបស់ខ្លួន ដែលកំពុងប្រឈមនឹងបញ្ហា ដែលបណ្តាលមកពីការនាំចូលអង្ករពីប្រភពផ្សេងរួចនាំចេញតាមច្រកកម្ពុជា ព្រមទាំងការប្រកួតប្រជែងតម្លៃទីផ្សារក្នុងស្រុក និងក្រៅប្រទេសផងដែរ។ ជាងនេះទៅទៀតគណៈកម្មាធិការនេះបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់របស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការលើកកម្ពស់ការអនុវត្តការងារប្រកបដោយតម្លាភាព និងភាពស៊ីចង្វាក់គ្នារវាងសមាជិករោងម៉ាស៊ីនកិនស្រូវ អ្នកកែច្នៃ និងក្រុមហ៊ុននាំចេញទាំងអស់ ដោយការពារឲ្យបាននូវការនាំអង្ករពីបរទេសចូលមកកម្ពុជា រួចនាំចេញបន្តដោយប្រើប្រាស់ក្រោមស្លាកឈ្មោះអង្ករកម្ពុជា។

ទន្ទឹមវិស័យស្រូវអង្ករកំពុងអភិវឌ្ឍន៍រីកចម្រើន ព័ត៌មានស្តីពីការលួចបន្លំម៉ាក សំបកបាវ ការលាយអង្ករ និងព័ត៌មានអង្ករប្លាស្ទិចជាដើមបានកើតមានឡើងដែលមានចេតនាបង្ខូចកិត្តិស័ព្ទអង្ករកម្ពុជា។ គណៈកម្មាធិការប្រតិបត្តិផ្នែកក្រមសីលធម៌និងវិន័យបានសម្របសម្រួលការងារជាមួយស្ថាប័នពាក់ព័ន្ធដើម្បីស្រាវជ្រាវរកការពិត ដោយធ្វើការងារជាអគ្គនាយកដ្ឋានកាំកុងត្រូល  អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអាជ្ញាធរខេត្តជាច្រើនទៀតដើម្បីការពារអង្ករកម្ពុជាទាំងនៅថ្នាក់ជាតិនិងអន្តរជាតិ។ ក្នុងគោលបំណងលើកស្ទួយសុចរិតភាពក្នុងការនាំចេញទៅកាន់ទីផ្សារអន្តរជាតិប្រកបដោយកិត្យានុភាព ថ្នាក់ដឹកនាំសហព័ន្ធក៏បានធ្វើការងារជាមួយស្ថាប័នជំនាញ និងមានសមត្ថកិច្ចក្នុងការធ្វើវិសោធនកម្មក្រមសីលធម៌ ដើម្បីបន្សុីនឹងស្ថានភាពបច្ចុប្បន្នថែមទៀតផង។

## 2.6.2 សហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការស្រាវជ្រាវ និងបង្ក្រាបបទល្មើសអង្ករ

គណៈកម្មាធិការវិន័យ និងក្រុមសីលធម៌បានរៀបចំកិច្ចប្រជុំនៅអាណត្តិទី២ ចំនួន២លើក ដើម្បីរៀបចំយុទ្ធសាស្ត្រអនុវត្តការងារឲ្យមានប្រសិទ្ធភាព និងបានធ្វើការសហការជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក្នុងការចុះត្រួតពិនិត្យអង្ករ ដែលមានសារធាតុគីមី(ប្លាស្ទិច) នៅតាមដេប៉ូលក់អង្ករផង និងបានរៀបចំវេទិកាសាធារណៈដែលដឹកនាំដោយ ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធ ព្រមទាំងមន្ត្រីជំនាញមកពីក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយ និងរដ្ឋាករ កាំកុងត្រូល និងជាមួយម្ចាស់ដេប៉ូធំៗនៅរាជធានីភ្នំពេញ ស្តីពីការធ្វើតេស្តអង្កររកសារធាតុគីមី និងការណែនាំឲ្យប្រើប្រាស់តែមសំគាល់ផលិតផលអង្កររបស់ខ្មែរសុទ្ធ១០០%។

ស្នើសុំការសហការនិងផ្តល់ព័ត៌មានពីអគ្គនាយកដ្ឋានកាំងកុងត្រូល អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងស្ថាប័នពាក់ព័ន្ធអំពីភាពមិនប្រក្រតីក្នុងការនាំចេញ-ចូលអង្ករ។ ក្នុងនោះផងដែរបានកែសម្រួលអនុស្សារណៈយោគយល់គ្នារវាងក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជាក្នុងការនាំអង្ករទៅកាន់ទីផ្សារអន្តរជាតិ ដោយគ្រោងស្នើឲ្យមានការចុះហត្ថលេខាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធចំនួន៤ ៖ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអង្គភាពប្រឆាំងអំពើពុករលួយ។



## 2.7 លេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា

ទស្សនវិស័យដ៏វែងឆ្ងាយរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា ជាពិសេសឯកឧត្តម **សុខ ពុទ្ធិវុធ** ដើម្បីឲ្យសហព័ន្ធស្រូវអង្ករកម្ពុជាកាន់តែមានភាពជោគជ័យនិងមានដំណើរការប្រកបដោយនិរន្តរភាព គឺទាមទារឱ្យមានការចូលរួមគាំទ្រយ៉ាងពេញទំហឹងពីសមាជិកសមាជិកាទាំងស្មារតី សកម្មភាព និងធនធាននានា ដោយសហព័ន្ធស្រូវអង្ករកម្ពុជាបានបង្កើតនិងពង្រឹងនូវលេខាធិការដ្ឋានដែលមានបុគ្គលិកបំពេញការងារតាំងពីថ្នាក់កណ្តាលរហូតដល់ថ្នាក់តំបន់ដែលអាចធ្វើការងារបាន និងមានការទទួលស្គាល់ពីថ្នាក់ជាតិនិងអន្តរជាតិ។ បច្ចុប្បន្ននេះ លេខាធិការដ្ឋាន ស.អ.ក ដឹកនាំដោយឯកឧត្តម **មូល សារិទ្ធិ** អគ្គលេខាធិការ និងបុគ្គលិកបំពេញការងារតាមផ្នែកនីមួយក្នុងលេខាធិការដ្ឋានបានរួមចំណែកបង្កើតសមិទ្ធផលសំខាន់ៗខាងលើ និងទទួលខុសត្រូវលើការងារប្រចាំថ្ងៃ រួមមាន៖

- អនុវត្តរាល់សេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាល
- សម្របសម្រួលរាល់កិច្ចការរបស់គណៈកម្មាធិការប្រតិបត្តិទាំង៦
- សម្របសម្រួលដោះស្រាយបញ្ហានិងសំណូមពរនានារបស់សមាជិកសមាជិកាឱ្យបានទាន់ពេលវេលា
- សម្របសម្រួល និងទំនាក់ទំនងជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា
- សម្របសម្រួលជួយដល់ប្រតិបត្តិការក្រុមការងារប្រចាំតំបន់និងខេត្ត
- ប្រមូល រៀបចំ និងផ្សព្វផ្សាយពីតម្លៃស្រូវអង្ករប្រចាំសប្តាហ៍
- រៀបចំផ្សព្វផ្សាយព្រឹត្តិបត្រពីសកម្មភាព ប្រចាំសប្តាហ៍ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ផ្សព្វផ្សាយព័ត៌មានទាក់ទងវិស័យស្រូវអង្ករជាប្រចាំតាមហ្វេសប៊ុក និងគេហទំព័រ
- រៀបចំធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពសហព័ន្ធ
- ការងារផ្សេងៗទៀតដែលបានប្រគល់ដោយថ្នាក់ដឹកនាំនិងជួយសម្រួលដល់សមាជិកទាន់ពេលវេលា ។ល។







## 2.8 ក្រុមការងារសម្របសម្រួលនៅថ្នាក់តំបន់ និងខេត្តៈ

តាំងពីក្នុងអាណត្តិទី១នៃក្រុមប្រឹក្សាភិបាលនៃសហព័ន្ធស្រូវអង្ករកម្ពុជាមកម្ល៉េះ ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានមើលឃើញនូវភាពប្រឈមមួយចំនួនដែលត្រូវដោះស្រាយ មិនត្រឹមតែថ្នាក់ជាតិប៉ុណ្ណោះទេ ប៉ុន្តែត្រូវរុលទៅដល់ថ្នាក់មូលដ្ឋាន។ ឯកឧត្តមប្រធាន ក៏បានផ្តួចផ្តើមឲ្យមានការបង្កើតតំណាងតាមតំបន់ ដើម្បីបំពេញតួនាទីនៅចំណុចចន្លោះប្រហោងទាំងនេះ។

រហូតដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ គឺ១០ថ្ងៃក្រោយការបោះឆ្នោតក្រុមប្រឹក្សាភិបាលសហព័ន្ធអាណត្តិទី២ ក្រុមប្រឹក្សាភិបាលបានសម្រេចយល់ព្រមដោយការលើកដៃចំពោះសំណើរបស់ឯកឧត្តមប្រធានសហព័ន្ធ ក្នុងការរៀបចំឲ្យមានតំណាងប្រចាំតំបន់ ដើម្បីធ្វើការងារនៅក្នុងតំបន់ប្រកបដោយប្រសិទ្ធិភាព ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសមាជិកនិងស្ថាប័នពាក់ព័ន្ធ ព្រមទាំងផ្សព្វផ្សាយព័ត៌មានឲ្យបានរហ័ស។ បន្ទាប់ពីទទួលការគាំទ្រផ្ទៃក្នុង ឯកឧត្តម ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានលើកសំណើនេះទៅកាន់ស្ថាប័នពាក់ព័ន្ធនានាឲ្យគាំទ្រការបែងចែកតំបន់សម្រាប់ជំរុញផលិតកម្មស្រូវនិងប្រសិទ្ធភាពទំនាក់ទំនង។

ក្រោយការយល់ព្រមក្នុងកិច្ចប្រជុំក្រុមការងារផ្នែកស្រូវ-អង្ករ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន កាលពីថ្ងៃទី១៦ខែសីហាឆ្នាំ២០១៦ និង ការសម្រេចយល់ព្រមរបស់ទីស្តីគណៈរដ្ឋមន្ត្រីចុះថ្ងៃទី០៧ខែកញ្ញាឆ្នាំ២០១៦ ស្របតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី០២ខែកញ្ញាឆ្នាំ២០១៦ ដែលអនុញ្ញាតឲ្យបង្កើតក្រុមការងារសម្របសម្រួលថ្នាក់តំបន់និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនិងការងារស្រូវអង្ករនៅមូលដ្ឋាន សហព័ន្ធស្រូវអង្ករកម្ពុជាបានដំណើរការជ្រើសរើសអ្នកសម្របសម្រួលថ្នាក់តំបន់បានចំនួន៣ ក្នុងចំណោមតំបន់ទាំង៥ដែលគ្រោងបង្កើតឡើង ហើយ សហព័ន្ធកំពុងពិនិត្យអ្នកមានសក្តានុពល មានបទពិសោធន៍ និង មានឆន្ទៈខ្ពស់ក្នុងការងារស្រូវអង្ករសម្រាប់បំពេញការងារនៅតំបន់ទាំងពីរផ្សេងទៀតដែលនៅសេសសល់។




## គោលបំណងនិងប្រសិទ្ធភាពនៃការបង្កើតរចនាសម្ព័ន្ធតាមតំបន់

ការបែងចែកនេះមានគោលបំណងដើម្បីបង្កើនភាពងាយស្រួលក្នុងការសម្របសម្រួលគ្រប់ដំណើរការនានាក្នុងខ្សែចង្វាក់ផលិតកម្មស្រូវដែលកើតមានឡើងនៅក្នុងតំបន់ ដើម្បីធានានិរន្តរភាព និងបង្កើនប្រសិទ្ធភាពការងារនិងឆ្លើយតបនូវសេចក្តីត្រូវការនានារបស់សមាជិកសហព័ន្ធស្រូវអង្ករកម្ពុជាបានទាន់ពេលវេលា។ បន្ថែមលើនេះ ការបង្កើតតំបន់នឹងជំរុញផ្សព្វផ្សាយគោលនយោបាល ផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាព របស់សហព័ន្ធស្រូវអង្ករកម្ពុជា ឲ្យបានទូលំទូលាយ ដល់គ្រប់ភាគីពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន។

## ភាពចាំបាច់នៅមូលដ្ឋានដែលតម្រូវសហព័ន្ធស្រូវអង្ករកម្ពុជាយកចិត្តទុកដាក់លើការបង្កើតតំបន់



សហព័ន្ធស្រូវអង្ករកម្ពុជា បច្ចុប្បន្នមានសមាជិកចំនួនជាង៣១៣រូប ដែលតំណាងឲ្យសហព័ន្ធនាំចេញអង្ករ សហព័ន្ធកសិករ សមាគមន៍រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុននាំចេញអង្ករ ក្រុមហ៊ុនដឹកជញ្ជូន និងធនាគារ ជាដើម។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់សហព័ន្ធស្រូវអង្ករកម្ពុជាជាដៃគូតែមួយគត់សម្រាប់ការពិភាក្សាគោលនយោបាយ និងជាអ្នកតំណាងវិស័យស្រូវអង្ករក្នុងឆាកជាតិនិងអន្តរជាតិ។ សហព័ន្ធស្រូវអង្ករកម្ពុជាមានតួនាទីដ៏សំខាន់គឺផ្តល់ការគាំទ្រគ្រប់ទិដ្ឋភាពទាំងអស់ ដោយរួមបញ្ចូលទាំងគោលនយោបាយ ច្បាប់ និងការអនុវត្តដល់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងខ្សែចង្វាក់ស្រូវដើម្បីបង្កើននូវភាពប្រកួតប្រជែងរបស់ខ្លួនក្នុងការផលិត និងផ្គត់ផ្គង់អង្ករទៅកាន់ទីផ្សារក្នុងស្រុក និងអន្តរជាតិ។ដោយសារតែសមាជិកនៅរាយប៉ាយទូទាំងប្រទេស និងបញ្ហាប្រឈមផ្សេងៗគ្នានៅតាមកន្លែងមូលដ្ឋាន ស.អ.ក យល់ឃើញថាការបង្កើតសាខានៅតាមតំបន់គឺជាភាពចាំបាច់បំផុត។

## រចនាសម្ព័ន្ធថ្នាក់តំបន់

នាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ សហព័ន្ធស្រូវអង្ករកម្ពុជា បានរៀបចំដំណើរការកិច្ចប្រជុំដឹកនាំដោយប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា។ កិច្ចប្រជុំបានផ្តោតការពិភាក្សាអំពីការបែងចែកតំបន់ការងារ និងការទទួលខុសត្រូវរបស់ថ្នាក់តំបន់។ សហព័ន្ធស្រូវអង្ករកម្ពុជា បានកំណត់បែងចែកតំបន់គោលដៅការងារជា៥តំបន់ដោយផ្អែកទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលភាពនៅក្នុងវិស័យស្រូវអង្ករៈ

- **តំបន់១៖ មានខេត្តគោលដៅចំនួន៦ខេត្ត តាកែវ កំពត កំពង់ស្ពឺ កែប ព្រះសីហនុ និងកោះកុង**
- **តំបន់២៖ មានខេត្តគោលដៅចំនួន៥ខេត្ត កណ្តាល កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង និងស្វាយរៀង**
- **តំបន់៣៖ មានខេត្តគោលដៅចំនួន៤ខេត្ត ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី**
- **តំបន់៤៖ មានខេត្តគោលដៅចំនួន៤ខេត្ត កំពង់ធំ សៀមរាប ឧត្តមានជ័យ និងព្រះវិហារ**
- **តំបន់៥៖ មានខេត្តគោលដៅចំនួន៥ខេត្ត កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន**

## តួនាទីភារកិច្ចរបស់បុគ្គលិកប្រចាំតំបន់នីមួយៗ៖

- ជាតំណាងសហព័ន្ធស្រូវអង្ករកម្ពុជា និងជាអ្នកសម្របសម្រួល និងធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញថ្នាក់ខេត្ត ដៃគូអភិវឌ្ឍ សហគមន៍កសិករ អ្នកផ្គត់ផ្គង់សម្ភារកសិកម្ម អ្នកប្រមូលទិញ រោងម៉ាស៊ីនកិនស្រូវ និង អ្នកនាំចេញអង្ករ ។
- ប្រមូលព័ត៌មានអំពីសក្តានុពល ផ្ទៃដីផលិត និងពូជស្រូវ ដែលកសិករប្រើប្រាស់ក្នុងផលិតកម្មស្រូវវស្សា និងប្រាំង ដោយរួមបញ្ចូលទាំងការប្រមូលទិន្នន័យការផលិត និងទីផ្សារស្រូវអង្ករ ។
- សម្របសម្រួល ការជ្រើសរើសសហគមន៍កសិករ និងផ្សាភ្ជាប់រវាងសហគមន៍កសិករ និងម៉ាស៊ីនកិនស្រូវ ព្រមទាំងការរៀបចំឲ្យមានការចុះកិច្ចសន្យាផលិតស្រូវ (Contract Farming)។
- រៀបចំបណ្តាញ ផ្សាភ្ជាប់តួអង្គសំខាន់ៗក្នុងខ្សែចង្វាក់ផលិតកម្មស្រូវ សហគមន៍ផលិតគ្រាប់ពូជស្រូវ ក្រុមហ៊ុនផលិតគ្រាប់ពូជស្រូវ សហគមន៍កសិករ អ្នកផ្គត់ផ្គង់សម្ភារកសិកម្មអ្នកប្រមូលទិញ រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករ។
- ចុះតាមដានសកម្មភាពនានាក្នុងមូលដ្ឋានដើម្បីដឹងការវិវត្ត និងភាពប្រឈម។
- សម្របសម្រួលកិច្ចប្រជុំកសិករ ទិវាស្រែកសិករ និងព្រឹត្តិការណ៍នានាដែលកើតមានឡើងក្នុងតំបន់ គោលបំណងដើម្បីចែករំលែកព័ត៌មាន និងជំរុញការផ្សព្វផ្សាយស្រូវអង្ករ ។
- ស្វែងរកការគាំទ្រពីរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍ សំដៅគាំទ្រសហគមន៍កសិករក្នុងការបង្កើនសមត្ថភាពផលិតស្រូវ និងការអភិវឌ្ឍសមត្ថភាពរបស់សហគមន៍ ។
- តាមដាន និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ អំពីស្ថិតិ រោងម៉ាស៊ីនកិនស្រូវ និងសហគមន៍កសិករ
- កសាងទំនាក់ទំនងល្អ ជាមួយស្ថាប័នពាក់ព័ន្ធ ដូចជា មន្ទីរជំនាញថ្នាក់ខេត្ត វិស័យឯកជន ដៃគូអភិវឌ្ឍ និងសហគមន៍កសិករ។
- រៀបចំរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ ផ្ញើជូនសហព័ន្ធស្រូវអង្ករកម្ពុជា



## អ្នកសម្របសម្រួលប្រចាំតំបន់ដែលបានជ្រើសរើសរួច បានបំពេញការងារយ៉ាងច្រើនប្រចាំតំបន់ ដូចខាងក្រោម៖

### 2.8.1 ក្រុមការងារតំបន់ទី ១&២

#### សកម្មភាពការងារនិងលទ្ធផលសម្រេចបានកន្លងមក៖

ចាប់តាំងពីបានបែងចែកតំបន់ការងារ និងការទទួលខុសត្រូវរបស់ថ្នាក់តំបន់ទាំង៥រួចមក មន្ត្រីសម្របសម្រួលការងារនៅតំបន់ ១ និង ២ បានអនុវត្តសកម្មភាពការងារដូចខាងក្រោម៖

- បានជ្រើសរើសរោងម៉ាស៊ីនឱ្យចូលជាសមាជិករបស់សហព័ន្ធនៅតាមខេត្ត
- បានជ្រើសរើសសហគមន៍កសិកម្មឱ្យចូលជាសមាជិករបស់សហព័ន្ធនៅតាមខេត្ត
- បានចុះប្រមូលព័ត៌មានទាក់ទងនឹងទិន្នន័យ កាលបរិច្ឆេទនៃការដាំដុះ និងទិន្នផលស្រូវរបស់សហគមន៍កសិកម្មប្រចាំឆ្នាំតាមខេត្តគោលដៅក្នុងតំបន់ និងបានធ្វើជារបាយការណ៍ផ្ទៃដីដាំដុះស្រូវ
- បានសម្របសម្រួលលើការងារជ្រើសរើសសមាជិក ជាតំណាងខេត្តនីមួយៗរបស់ ស.អ.ក បញ្ចូលជាមួយក្រុមការងារថ្នាក់ខេត្ត ដើម្បីសម្របសម្រួលដោះស្រាយបញ្ហាផ្នែកស្រូវអង្ករ
- បានប្រមូលព័ត៌មាន និងសរសេរជារបាយការណ៍ពីពូជស្រូវរំដួលអឹម ៤៥០០
- បានជ្រើសរើសសមាជិកសកម្មប្រចាំខេត្តដែលកើតចេញពីសហគមន៍កសិកម្ម និងម្ចាស់រោងម៉ាស៊ីន
- បានចុះសម្របសម្រួលការងារក្រុមហ៊ុនចុះយកសំណាកដីស្រែតាមប្រព័ន្ធ GPS នៅសហគមន៍កសិកម្មស្រុកត្រាំកក់ ខេត្តតាកែវ
- បានប្រមូលព័ត៌មានតម្លៃស្រូវសើម តាមបណ្តាខេត្តសក្តានុពលមួយចំនួនក្នុងតំបន់ពីឆ្នាំ២០១៧មក
- បានចុះយកព័ត៌មានពីការទិញ-លក់ស្រូវរវាងកសិករ និងឈ្មួញកណ្តាលតាមច្រករបៀងព្រំដែនខ្មែរ-វៀតណាម
- បានប្រមូលព័ត៌មាន និងធ្វើជារបាយការណ៍សង្ខេបទាក់ទងនឹងការពិសោធន៍បន្សាំបឋមស្រទ្បាយស្រូវ សែនក្រអូបលើដីស្រែកសិករនៅរដូវវស្សាឆ្នាំ២០១៨
- បានចូលរួមកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងវិស័យស្រូវអង្ករដូចជាក្រុមការងារបច្ចេកទេសទី២នៃសភាពាណិជ្ជកម្មកម្ពុជា រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនជប៉ុន ពិធីចុះអនុស្សរណៈយោគយល់របស់ក្រុមហ៊ុននាំចេញ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈប្រតិភូនៃក្រសួងកសិកម្មប្រទេសថៃ
- បានចូលរួមជាគណៈកម្មការរៀបចំវេទិកាប្រកួតស្រូវល្អបំផុតប្រចាំប្រទេសកម្ពុជាលើកទី៣ និងកម្មវិធីអបអរសាទរកម្ពុជាទទួលបានពានរង្វាន់អង្ករល្អបំផុតលើពិភពលោកលើកទី៤ ឆ្នាំ២០១៨ ដែលទទួលបន្ទុកទាក់ទង និងជូនដំណឹងដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវជាសមាជិក ស.អ.ក ពីការអញ្ជើញចូលរួមនិងការបង់ប្រាក់សមាជិកភាព ហើយនឹងបានសរសេររបាយការណ៍កម្មវិធី
- បានប្រមូលព័ត៌មាន និងធ្វើសេចក្តីរាយការណ៍ស្តីពីស្ថានភាពគ្រោះមហន្តរាយធម្មជាតិ ដូចជា គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត តាមបណ្តាខេត្តជុំវិញបឹងទន្លេសាប និងខេត្តផ្សេងទៀត (ស្ទឹងត្រែង ក្រចេះ ព្រៃវែងជាដើម) ដែលរងគ្រោះ នៅខែសីហា ឆ្នាំ២០១៨
- រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញ ជាសមាជិក ស.អ.ក ក្នុងតំបន់ ១ និង ២ មានសរុបចំនួន ៣១ ក្នុងនោះនៅតំបន់ ១ មានខេត្តតាកែវចំនួន១ និងខេត្តកំពង់ស្ពឺចំនួន៣។ រីឯនៅតំបន់២វិញ មានខេត្តកណ្តាលចំនួន៧ ខេត្តព្រៃវែងចំនួន១០ និងខេត្តត្បូងឃ្មុំចំនួន១០
- សហគមន៍កសិកម្មនៅក្នុងតំបន់ ១ និង ២ មានសរុបចំនួន ៣៣៦ ក្នុងនោះនៅតំបន់ ១ មានខេត្តតាកែវចំនួន ៩០ ខេត្តកំពង់ស្ពឺចំនួន ៣៨ ខេត្តកំពតចំនួន ៤៥ ខេត្តកែបចំនួន ២ ខេត្តព្រះសីហនុចំនួន ៩ និងខេត្តកោះកុងចំនួន ៧។ ចំណែកឯនៅតំបន់ ២ វិញ មានខេត្តកណ្តាលចំនួន ២៦ ខេត្តព្រៃវែងចំនួន ៥៣ ខេត្តស្វាយរៀងចំនួន ៤៤ និងខេត្តត្បូងឃ្មុំចំនួន ២១
- សមាជិកជាតំណាងខេត្តនីមួយៗរបស់ ស.អ.ក ត្រូវបានបញ្ចូលជាមួយក្រុមការងារថ្នាក់ខេត្តមានតួនាទីជាអនុប្រធាន និងលេខាធិការនៅក្នុងសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសម្របសម្រួល ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវ-អង្ករនៅមូលដ្ឋានតាមខេត្តមួយចំនួនដូចជា ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តកណ្តាល និងខេត្តស្វាយរៀង
- ក្រុមហ៊ុនបានចុះសិក្សាសំណាកដីស្រែរបស់សហគមន៍កសិកម្ម តាមប្រព័ន្ធGPS និងបានទទួលលទ្ធផលមួយចំនួនពីការប្រមូលព័ត៌មានលើដីស្រែពីសហគមន៍កសិកម្ម ដើម្បីផ្ទៀងផ្ទាត់នឹងទិន្នន័យពី ផ្កាយរណប
- ការពិសោធន៍បន្សាំបឋមស្រទ្បាយស្រូវសែនក្រអូបលើដីស្រែកសិករនៅរដូវវស្សាឆ្នាំ២០១៨ បានទទួលបានទិន្នផលពីសហគមន៍កសិកម្មចំនួន៣ ក្នុងនោះមានស្រែពិសោធន៍ចំនួន២សហគមន៍កសិកម្មបានខូចខាតដោយសារសត្វស្លាប សត្វចង្រៃ និងសត្វល្អិតចុះបំផ្លាញ ហើយស្រែខ្លះទៀតទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដូចជា មានភ្លៀងធ្លាក់ពេលស្រូវកំពុងចេញផ្កាជាដើម
- សហគមន៍កសិកម្មចំនួនបីមកពីខេត្តផ្សេងគ្នាបានឈ្នះជ័យលាភីស្រូវល្អបំផុតប្រចាំប្រទេសកម្ពុជាលើកទី៣ លើប្រភេទស្រូវផ្ការំដួល សែនក្រអូប និងអ៊ីអែរ
- ដំណើរការវេទិកាប្រកួតស្រូវ និងកម្មវិធីអបអរសាទរទទួលបានជោគជ័យ និងលទ្ធផលសម្រេចបានតាមការរំពឹងទុក
- ស.អ.ក បានចុះសួរសុខទុក្ខ និងពាំនាំនូវអំណោយដែលទទួលបានពីការឧបត្ថម្ភរបស់សមាជិក ចែកជូនដល់ប្រជាជនរងគ្រោះ និងសហគមន៍កសិកម្មរងគ្រោះនៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ និងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ បន្ទាប់ពីទទួលបានព័ត៌មានពីស្ថានភាពគ្រោះមហន្តរាយធម្មជាតិ (គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត) នៅខែសីហា ឆ្នាំ២០១៩
- ក្រោមកិច្ចសហការរវាង ស.អ.ក និង JICA គម្រោង ជំរុញផលិតកម្ម និងការប្រើប្រាស់គ្រាប់ពូជស្រូវ បានដំណើរការសកម្មភាពគម្រោងដូចជា ការបណ្តុះបណ្តាលបច្ចេកទេសដល់សហគមន៍កសិកម្ម គោលដៅនៃគម្រោងបានចំនួន៣លើកក្នុងមួយសហគមន៍ និងបានរៀបចំជាវេទិកាគ្រាប់ពូជស្រូវនៅខេត្តព្រៃវែង ខេត្តបាត់ដំបង និងខេត្តតាកែវ។

## 2.8.2 ក្រុមការងារតំបន់ទី៤&៥

តំបន់៤និងតំបន់៥ ជាតំបន់ដែលមានសក្តានុពលក្នុងវិស័យស្រូវអង្ករជាពិសេសតំបន់ជុំវិញបឹងទន្លេសាបដែលមានផ្ទៃដីស្រែវស្សានិងផ្ទៃដីស្រែប្រាំងជាច្រើននិងមានរោងម៉ាស៊ីនកិនស្រូវនិងក្រុមហ៊ុនកែច្នៃអង្ករក៏ច្រើនផងដែរដូចជានៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យនិងខេត្តកំពង់ធំនិងខេត្តកំពង់ចាម។ ចំណែកខេត្តព្រះវិហារជាខេត្តដែលមានសក្តានុពល ស្រូវសេរីរាង្គដែលមានក្រុមហ៊ុនកែច្នៃអង្ករធំជាច្រើនបានមកធ្វើកិច្ចសន្យាផលិតផលកសិកម្ម(Contract Farming)ជាមួយសហភាពសហគមន៍កសិកម្មនៅខេត្តព្រះវិហារ។

តំបន់៤មានខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តព្រះវិហារនិងខេត្តឧត្តរមានជ័យមានសហគមន៍កសិកម្មសរុប១៨៨។ តំបន់៥ មានខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តពោធិ៍សាត់និងខេត្តកំពង់ឆ្នាំងមានសហគមន៍កសិកម្មសរុប២៤៤។សរុបទាំង២តំបន់មានសហគមន៍កសិកម្មមាន៤៣២(ទិន្នន័យឆ្នាំ២០១៧)។ សកម្មភាពការងារសំខាន់ៗនិងសមិទ្ធផល ដែលបានអនុវត្តកន្លងមកៈ

- អនុវត្តនិងប្រតិបត្តិការងារដែលលេខាធិការដ្ឋានប្រគល់ជូន
- បានផ្សព្វផ្សាយនៅតាមសហគមន៍កសិកម្មនិងរោងម៉ាស៊ីនមួយចំនួននិងធ្វើបទបង្ហាញជាមួយដៃគូទីភ្នាក់ងារកិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ នៅក្នុងសិក្ខាសាលាដើម្បីឲ្យគេស្គាល់កាន់តែច្បាស់សហពន្ធ័ស្រូវអង្ករកម្ពុជាព្រមទាំងដាក់ពាក្យចូលជាសមាជិកសហពន្ធ័ស្រូវអង្ករផងដែរហើយក៏បានធ្វើបទបង្ហាញស្តីពីស្តង់ដារគុណភាពស្រូវតាមលក្ខណ:បច្ចេកទេសនៅ ខេត្តសៀមរាបខេត្តបន្ទាយមានជ័យនិងឧត្តរមានជ័យដើម្បីជាចំណេះដឹងបន្ថែមទៀតជូនដល់សហគមន៍កសិករ។
- បានចុះទៅពិនិត្យមើលជាមួយអាជ្ញាធរមានសម្ថកិច្ច កន្លែងលក់មួយចំនួនដែលគេបានផ្សព្វផ្សាយថាជាអង្ករផ្លាស់ស្ទិចនិងបានយកទៅពិសោធន៏មើលគឺមិនដែលមានទេ។
- បានចុះផ្សព្វផ្សាយមិនឲ្យប្រើប្រាស់ថ្នាំគីមីមាន សារធាតុទ្រីក្លាហ្សូលជាមួយអង្គការដៃគូមួយចំនួនក្នុងកិច្ចប្រជុំ និងតាមការផ្តល់ព័ត៌មានតាមទូរស័ព្ទដោយសហភាពអឺរ៉ុបហាម ដាច់ខាត ។
- ស្រង់ទិន្នន័យនិងការបរិច្ឆេទនៃការដាំដុះដំណាំស្រូវរបស់សហគមន៍កសិកម្មតំបន់៤និងតំបន់៥តាមសៀវភៅធំរបស់សហពន្ធ័ស្រូវអង្ករឆ្នាំ២០១៧។ទិន្នន័យបានបែងចែកលំអិតផ្ទៃដីដាំស្រូវប្រភេទស្រូវកាលបរិច្ឆេទនៃការដាំដុះកាលបរិច្ឆេទនៃការប្រមូលផលនិងពត៍មានសំខាន់មួយចំនួនទៀត។
- ស្រង់ទិន្នន័យតម្លៃស្រូវរដូវវស្សានិងរដូវប្រាំងតាមខេត្តនីមួយក្នុងតំបន់៤និងតំបន់៥ដើម្បីផ្សព្វផ្សាយជាពត៍មានសម្រាប់អ្នកពាក់ពន្ធ័នៃវិស័យស្រូវអង្ករនិងសម្រាប់សាធារណ:។
- ចូលរួមប្រជុំសិក្ខាសាលាពិគ្រោះយោបល់ជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរពាក់ពន្ធ័និងដៃគូអភិវឌ្ឍនមួយចំនួនក្នុងនោះមានទីភ្នាក់ងារកិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់(GIZ)ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការ ជប៉ុន(JICA) ព្រមទាំងអង្គការមួយចំនួនទៀតដែលគាំទ្រសហគមន៍កសិកម្មដូចជា អង្គការអាដា រីដា(ADA,RIDA) អង្គការកែប្រែសហគមន៍កសិកម្ម(CTO)
- ចូលរួមមហាសន្និបាតបូកសរុបការងារប្រចាំឆ្នាំសហគមន៍កសិកម្មនៅក្នុងខេត្តសៀមរាបនិងខេត្តផ្សេងទៀត
- សម្របសម្រួលនិងទំនាក់ទំនងការងារជាប្រចាំជាមួយប្រធាន អនុប្រធាន និងសមាជិក ក្រុមការងារសកម្មរបស់សហព័ន្ធស្រូវអង្ករនៅតាមខេត្តនីមួយក្នុងតំបន់៤និង៥ដើម្បីតាមដានពីបញ្ហាស្រូវអង្ករនៅមូលដ្ឋានខេត្តនីមួយៗក្នុងឆ្នាំកន្លងមកនៅខេត្តសៀមរាប ខេត្តឧត្តរមានជ័យនិងខេត្តបន្ទាយមានជ័យ ក្រុមការងារដោះស្រាយបញ្ហាស្រូវអង្ករនៅមូលដ្ឋានថ្នាក់ខេត្តបានរៀបចំកិច្ចប្រជុំដោះស្រាយបញ្ហាប្រឈមពាក់ពន្ធ័បញ្ហាស្រូវអង្ករ។ក្រៅពីនេះក៏បានសម្របសម្រួលជាមួយមន្ត្រីអគ្គិសនីដោះស្រាយបញ្ហាភ្លើងដាច់និងជាមួយមន្ត្រីពន្ធដារខេត្តសៀមរាបជូនដល់រោងម៉ាស៊ីនកិនស្រូវ ញឹក សារឹទ្ធ ព្រោះរោងម៉ាស៊ីនកិនស្រូវលោកមន្ត្រីពន្ធដារខេត្តអញ្ជើញឲ្យចូលមកបង់ពន្ធតាមរបបពិតកន្លងមករហូតដល់ពេលនេះគាត់បង់ពន្ធតាមរបបម៉ៅការ។
- តាមការបញ្ជាក់ពីក្រុមការងារតំណាងរោងម៉ាស៊ីនកិនស្រូវនៅតាមខេត្តមួយចំនួននៅក្នុងតំបន់៤និងតំបន់៥គឺមានភាពខុសគ្នា។លោក ញឹក សារឹទ្ធ តំណាងរោងម៉ាស៊ីនកិនស្រូវនៅខេត្តសៀមរាបនិងលោក រស់ សុផារិទ្ធ តំណាងរោងម៉ាស៊ីននៅខេត្តកំពង់ធំបានបញ្ជាក់ដូចគ្នាថា រោងម៉ាស៊ីនកិនស្រូវនៅក្នុងខេត្តភាគច្រើនជារោងម៉ាស៊ីនកិនស្រូវ ធន់តូចនិងមធ្យមហើយរហូតដល់ពេលនេះនៅបង់ពន្ធតាមរបបម៉ៅការនៅឡើយ។
- លោក ហេង ផេង អនុប្រធានសហពន្ធ័ស្រូវអង្ករកម្ពុជានិងតំណាងរោងម៉ាស៊ីន កិនស្រូវខេត្តបាត់ដំបង បានបញ្ជាក់ថា រោងម៉ាស៊ីនកិនស្រូវស្ទើរតែទាំងអស់នៅខេត្តបាត់ដំបងបានបង់ពន្ធតាមរបបពិត ។

បានចូលរួមកិច្ចប្រជុំនិងសិក្ខាសាលាជាមួយគម្រោងជំរុញផលិតស្បៀងនៅខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តបាត់ដំបង។

- បានទៅចូលរួមទស្សនកិច្ចសិក្សាជាមួយក្រុមការងារមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងពាណិជ្ជកម្មនៅសាធារណរដ្ឋប្រជាមានិតចិនរយ:ពេល១សប្តាហ៍តាមរយ:កម្មវីធីស្បៀងអាហារពិភពលោក(World Food Program)។ បានទទួលចំណេះដឹងនិងបទពិសោធន៍ថ្មីបន្ថែមទៀត។
- បានរៀបចំបន្សុទ្ធស្រូវស្រទ្បាយសែនក្រអូបនៅលើដីកសិករចំនួន២លើក លើកទី១ចំនួន១០កន្លែង ឆ្នាំ២០១៧ នៅរដូវប្រាំងនិងលើកទី២ចំនួន២០ កន្លែងនៅរដូវវស្សាឆ្នាំ២០១៨(ដោយសហការជាមួយCARDI និង CAVAC)។

# 3 កិច្ចសហការជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា

បន្ទាប់ពីការបោះឆ្នោតសម្រាប់អាណត្តិទី២ ដែលបានប្រព្រឹត្តិទៅកាលពីខែកក្កដា ឆ្នាំ២០១៦ សហព័ន្ធស្រូវអង្ករកម្ពុជា បានស្នើសុំប្រជុំជាមួយបណ្តាញក្រសួង-ស្ថាប័នពាក់ព័ន្ធជាច្រើន ដើម្បីជួយសម្រួលការងាររបស់សហព័ន្ធឲ្យស្របទៅតាមគោលដៅផែនការដែលបានដាក់ចេញក្នុងការជួយឲ្យវិស័យកសិកម្មផ្នែកស្រូវអង្ករមានការប្រកួតប្រជែងជាមួយបណ្តាលប្រទេសនៅលើពិភពលោកផងដែរ។

តាមរយៈសកម្មភាពនិងសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការក្នុងពេលកន្លងមកនេះ សហព័ន្ធស្រូវអង្ករកម្ពុជាបានបំពេញការងារយ៉ាងជិតស្និទ្ធជាមួយក្រសួងនិងស្ថាប័នជាច្រើនដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងបរិស្ថាន អគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានពន្ធដារ សភាពាណិជ្ជកម្មកម្ពុជា ព្រមទាំងមានកិច្ចសហការជាមួយស្ថាប័នដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិមួយចំនួនទៀត។

## 3.1 កិច្ចសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការដោះស្រាយបញ្ហា

### 3.1.1 តាមរយៈវេទិការាជរដ្ឋាភិបាល-វិស័យឯកជន ផ្នែកស្រូវអង្ករ ( ក្រុមការងារទី៩ )

តាមរយៈសេចក្តីសម្រេចលេខ៣០.សសរ ស្តីពី ការទទួលស្គាល់ជាផ្លូវការនូវការកែសម្រួលក្រុមការងារផ្នែកស្រូវ-អង្ករផ្នែកឯកជននៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ និងសេចក្តីសម្រេចលេខ៤៥សសរ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ដែលមានសហប្រធានក្រុមការងារ ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រជុំជាច្រើនលើកនិងសម្រេចបានលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- វិធានការទប់ស្កាត់លើបញ្ហាការនាំចូលអង្ករខុសច្បាប់ពីប្រទេសជិតខាង (Rice Import Illegal Protection )
- ការលើកលែងពន្ធអាករលើតំលៃបន្ថែម១០%(VAT)និងពន្ធលើប្រាក់ចំណេញ&ពន្ធអប្បបរមា (Taxation exemption)
- ការបញ្ចុះថ្លៃដើមក្នុងខ្សែចង្វាក់ផលិតកម្ម (Reduction  production costs)
- រៀបចំនិងបានបង្កើតក្រុមការងារថ្នាក់ខេត្តដើម្បីដោះស្រាយបញ្ហាវិស័យស្រូវអង្ករនៅមូលដ្ឋាន (Provincial qworking groups)
- ជំរុញការស្រាវជ្រាវ ការបន្សុទ្ធពូជ និងចុះបញ្ជីពូជស្រូវចំតម្រូវការទីផ្សារនាំចេញ (Seeds purification and registration)
- ជំរុញការពន្លឿនឯកសារវិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ (Certification of Phyto and Sanitary Phyto)
- ចាប់ផ្តើមផ្សព្វផ្សាយនិងអនុវត្តការធ្វើកសិកម្មតាមកិច្ចសន្យា(Contract Farming)
- ជំរុញការសិក្សាអំពីគុណភាពនៃប្រភេទដីផ្សេងៗនៅតាមតំបន់នានា (Land Suitability Study)
- ឯកភាពបង្កើតម៉ាកវិញ្ញាតកម្មអង្ករជាតិ «ម្លិះអង្គរ (Malys Angkor)»



## បញ្ហាប្រឈមដែលបាននិងកំពុងបន្តដោះស្រាយ៖

វិធានការ ឬការដាក់ពន្ធលើការនាំចូលអង្ករពីកម្ពុជាចូលទៅ EU៖ នាពេលកន្លងមកសហព័ន្ធស្រូវអង្ករកម្ពុជា និងក្រសួងស្ថាប័នពាក់ព័ន្ធបានរួមគ្នាក្នុងការតវ៉ានិងបានរៀបចំឯកសារស្តីពីគោលជំហររបស់វិស័យស្រូវអង្ករកម្ពុជា ព្រមទាំងបានទៅទស្សនកិច្ចនៅទីក្រុងBrussel ដើម្បីតវ៉ាផ្ទាល់ជាមួយសហភាពអឺរ៉ុបដោយបានជួលមេធាវីអន្តរជាតិជួយសម្រួលលើការងារនេះ ប៉ុន្តែជាលទ្ធផលEUនៅតែដាក់ពន្ធលើការនាំចូលអង្ករពីកម្ពុជា ដូចនេះសហព័ន្ធស្រូវអង្ករកម្ពុជា សម្រេចប្តឹងករណីនេះទៅកាន់តុលាការសហភាពអឺរ៉ុប ដោយបានទទួលការឯកភាពពីកិច្ចប្រជុំក្រុមការងារទី៩ ផ្នែកឯកជនផងដែរ។

o ស្នើសុំក្រសួងក្រសួងពាណិជ្ជកម្មលើកយកបញ្ហាការដាក់ពន្ធលើអង្ករកម្ពុជាទៅកាន់WTO ដើម្បីប្រជុំពិភាក្សាពិគ្រោះយោបល់។

រៀបចំគោលនយោបាយអភិវឌ្ឍន៍តំបន់ជុំវិញបឹងទន្លេសាបជាតំបន់ដាំដុះស្រូវអង្ករសរីរាង្គ និងរៀបចំធ្វើស្រែបង្ហាញគំរូ៖ ដើម្បីឱ្យការនាំចេញអង្ករកម្ពុជាសម្រេចបានតាមគោលនយោបាយ មានភាពប្រកួតប្រជែង មាននិរន្តរភាពទាំងបរិមាណនិងគុណភាព យើងត្រូវកំណត់៖ (១)ទីតាំងច្បាស់លាស់សម្រាប់ដាំស្រូវតម្រូវដី និងមូលដ្ឋានច្បាស់លាស់សម្រាប់ទីផ្សារនាំចេញ (២)ទីតាំងច្បាស់លាស់សម្រាប់ធ្វើទំនើបកម្មនៃស្រែ (៣)ទីតាំងច្បាស់លាស់សម្រាប់សន្តិសុខស្បៀង ជាដើម។

o ស្នើសុំរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ រៀបចំគោលនយោបាយអភិវឌ្ឍន៍តំបន់ជុំវិញបឹងទន្លេសាបជាតំបន់ដាំដុះស្រូវអង្ករសរីរាង្គ និងរៀបចំធ្វើស្រែបង្ហាញគំរូ។

ប្រព័ន្ធច្រកចេញចូលតែមួយសម្រាប់អង្ករ ដោយប្រើICT៖ ការរៀបចំបង្កើតឱ្យមានប្រព័ន្ធច្រកចេញចូលតែមួយសម្រាប់តែស្រូវអង្ករ ដោយប្រើប្រព័ន្ធបច្ចេកវិទ្យាទំនើប ដើម្បីផ្តល់សេវាកម្មបានរហ័ស និងមានតួលេខស្រូវអង្កររួមដូចគ្នា ព្រមទាំងអាចឆ្លើយតបទៅកាន់សហគមន៍អឺរ៉ុប ឬក្រសួងស្ថាប័នពាក់ព័ន្ធនានាឱ្យបានទាន់ពេលវេលា មានទិន្នន័យគ្រប់គ្រាន់សម្រាប់ឆ្លើយតប និងអាចទទួលយកបានពីគ្រប់ភាគីទាំងស្ថាប័នជាតិនិងអន្តរជាតិ។

o ស្នើសុំរដ្ឋាភិបាល ឬក្រសួងពាក់ព័ន្ធជួយជំរុញឱ្យមានការរៀបចំប្រព័ន្ធច្រកចេញចូលតែមួយសម្រាប់តែស្រូវអង្ករ ដោយប្រើប្រព័ន្ធបច្ចេកវិទ្យាទំនើប។

បច្ចុប្បន្នភាព ស្តីពីគម្រោងទុន ឃ្លាំងនិងឡសម្ងួត៖ តាមរយៈការស្នើសុំពីវិស័យឯកជននិងការប្រជុំពិភាក្សារបស់ក្រុមការងារទី៩ឃើញថា ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍដល់វិស័យស្រូវអង្ករកម្ពុជា និងជំរុញឱ្យគោលនយោបាយ ជំរុញការផលិតស្រូវនិងបង្កើនការនាំចេញអង្កររបស់រាជរដ្ឋាភិបាលសម្រេចបានតាមផែនការ ជាការចាំបាច់ណាស់យើងត្រូវមានឃ្លាំងនិងឡសម្ងួតដើម្បីប្រមូលស្តុកស្រូវឱ្យបានគ្រប់គ្រាន់នៅរដូវប្រមូលផល និងមានទុនដែលមានអត្រាការប្រាក់សមរម្យសម្រាប់ជួយដល់រោងម៉ាស៊ីននិងសហគមន៍កសិកម្ម។ នាពេលកន្លងមកតាមរយៈសំណើរបស់វិស័យឯកជន រដ្ឋាភិបាលបានសម្រេចទម្លាក់កញ្ចប់ថវិកាប្រមាណ៥០លានដុល្លារដើម្បីផ្តល់កម្ចី និងវិនិយោគ៣០០លានដុល្លារលើឃ្លាំងនិងឡសម្ងួតនៅតាមបណ្តាខេត្តនានា ដោយធនាគារអភិវឌ្ឍន៍ជនបទជាអ្នកទទួលបន្ទុកអនុវត្តការងារនេះ។

o ស្នើសុំឱ្យខាងធនាគារអភិវឌ្ឍន៍ជនបទរាយការណ៍ពីបច្ចុប្បន្នភាពលើកញ្ចប់ថវិកាកម្ចីដែលរដ្ឋាភិបាលបានផ្តល់ឱ្យ និងគម្រោងឃ្លាំងនិងឡសម្ងួតក្រោមកម្ចីសម្បទានពីចិន និងពិនិត្យលទ្ធភាពផ្តល់ទុនដែលមានអត្រាការប្រាក់សម្បទានដល់វិស័យកសិកម្ម។

គោលនយោបាយស្រូវអង្ករកម្ពុជា៖ គោលនយោបាយស្រូវអង្ករកម្ពុជាចាស់បានបញ្ចប់កាលពីឆ្នាំ២០១៥ ដោយយើងគួរពិនិត្យមើលឡើងវិញលើគោលនយោបាយស្រូវអង្ករចាស់និងរៀបចំធ្វើគោលនយោបាយស្រូវអង្ករថ្មីឲ្យបានសមស្របទៅនឹងការអភិវឌ្ឍនិងបច្ចុប្បន្នភាព នៃវិស័យស្រូវអង្ករកម្ពុជា ព្រមទាំងមានផែនការសកម្មភាពនិងការអនុវត្តឱ្យបានលម្អិត និងមានក្រសួង-ស្ថាប័នទាំងរដ្ឋនិងឯកជនចូលរួមទទួលខុសត្រូវឱ្យបានច្បាស់លាស់ និងមានគណៈកម្មាធិការតាមដានត្រួតពិនិត្យនិងវាយតំលៃលើការអនុវត្ត។

o ស្នើសុំជំរុញដល់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ច និងក្រសួង-ស្ថាប័នទទួលខុសត្រូវរៀបចំ និងដាក់ចេញនូវគោលនយោបាយស្រូវអង្ករថ្មីឱ្យបានលឿន។

ប្រសិទ្ធភាពនៃយន្តការក្រុមការងារទី៩៖ តាមរយៈលទ្ធផលនៃកិច្ចប្រជុំក្រុមការងារវេទិការាជរដ្ឋាភិបាល-វិស័យឯកជន ផ្នែកស្រូវអង្ករ(ក្រុមឈ ឬក្រុមការងារទី៩) អង្គប្រជុំបានសម្រេចនិងបានផ្ញើជូននូវរបាយការណ៍លទ្ធផល និងគោរពស្នើសុំមតិយោបល់ពីគណៈកម្មាធិការគោលនយោបាយស្រូវអង្ករ ប៉ុន្តែនាពេលកន្លងមកមិនទាន់បានទទួលការឆ្លើយតប ដូចនេះហើយខាងក្រុមការងារទី៩ មានការពិបាកក្នុងការបន្តធ្វើកិច្ចការនេះទៅមុខទៀត។

o ស្នើសុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជួយឆ្លើយតបនូវសំណើមួយចំនួនដែលជាលទ្ធផលនៃអង្គប្រជុំក្រុមការងារទី៩ ផ្នែកស្រូវអង្ករដែលធ្លាប់បានដាក់សំណើស្នើសុំមតិយោបល់ ឬជាដំណោះស្រាយចំពោះចំណុចមួយចំនួនដែលមិនអាចដោះស្រាយបានក្នុងកម្រិតក្រុមការងារទី៩។

ការជួយសម្រួលដល់ពាណិជ្ជកម្ម និងការកាត់បន្ថយថ្លៃដើមក្នុងខ្សែចង្វាក់ផលិតកម្ម៖ ដើម្បីចូលរួមជួយសម្រួលដល់ពាណិជ្ជកម្ម ការកាត់បន្ថយថ្លៃដើមក្នុងខ្សែចង្វាក់ផលិតកម្ម និងសហគមន៍កសិកម្មអាចធ្វើការដាំដុះបានច្រើនលើកក្នុងមួយឆ្នាំៗព្រមទាំងទទួលបានទិន្នផលខ្ពស់ ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់គួរពិនិត្យលទ្ធភាពបន្ថយបញ្ចុះតម្លៃអគ្គិសនី និងបញ្ចុះតម្លៃសេវាដឹកជញ្ជូនឱ្យប្រហែលនឹងប្រទេសជិតខាង ព្រមទាំងជួយជំរុញការអភិវឌ្ឍន៍ប្រព័ន្ធដឹកជញ្ជូននៅតាមផ្លូវទឹក ផ្លូវគោក ផ្លូវដែក និងមានរថភ្លើងគ្រប់គ្រាន់ និងមានប្រព័ន្ធធារាសាស្ត្រដើម្បីស្រោចស្រពនៅទូទាំងប្រទេស។

o ស្នើសុំក្រសួង-ស្ថាប័នពាក់ព័ន្ធពិនិត្យលទ្ធភាពបន្តជួយ៖

- បញ្ចុះតម្លៃអគ្គិសនី និងបញ្ចុះតម្លៃសេវាដឹកជញ្ជូនឱ្យប្រហែលនឹងប្រទេសជិតខាង
- ជំរុញការអភិវឌ្ឍន៍ប្រព័ន្ធដឹកជញ្ជូននៅតាមផ្លូវទឹក ផ្លូវគោក ផ្លូវដែក និងមានរថភ្លើងគ្រប់គ្រាន់
- ជំរុញការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដើម្បីស្រោចស្រពនៅទូទាំងប្រទេស។

យន្តការជម្រុញការអនុវត្តការធ្វើកសិកម្មតាមកិច្ចសន្យា(Contract Farming)៖ ដើម្បីធានាតម្លៃស្រូវសមរម្យសម្រាប់កសិករ និងការផលិតស្រូវចំតម្រូវការទីផ្សារសម្រាប់រោងម៉ាស៊ីននិងក្រុមហ៊ុននាំចេញ នាពេលការកន្លងមកការអនុវត្តនៅមានកម្រិត និងមិនទាន់មានការលើកទឹកចិត្តនៅឡើងនៅពេលភាគីទាំងពីរជួបនូវបញ្ហាលើការអនុវត្តការធ្វើកសិកម្មតាមកិច្ចសន្យានេះ(Contract Farming)។

o ស្នើរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ បន្តជំរុញអនុវត្តការធ្វើកសិកម្មតាមកិច្ចសន្យា(Contract Farming)។

ម៉ាកវិញ្ញាតកម្មអង្ករជាតិ«ម្លិះអង្គរ(Malys Angkor)»៖ ដោយសហព័ន្ធស្រូវអង្ករកម្ពុជា គឺជាតំណាងវិស័យឯកជនផ្នែកស្រូវអង្ករកម្ពុជា បានពិនិត្យឃើញថា ដោយមានភាពចាំបាច់នៅលើទីផ្សារ ដើម្បីបង្កើនទំនុកចិត្តពីអ្នកប្រើប្រាស់ ធានាតម្លៃ និងសុវត្ថិភាព ក៏ដូចជាការជំរុញផ្សព្វផ្សាយអង្ករកម្ពុជា ឲ្យកាន់តែទូលំទូលាយ និងមានទីផ្សារកាន់តែធំជាងមុននោះ ចាំបាច់យើងត្រូវរៀបចំឲ្យមានម៉ាកវិញ្ញាតកម្មអង្ករជាតិ «ម្លិះអង្គរ (Malys Angkor)» ដោយបានការសហការជាមួយក្រសួងពាណិជ្ជកម្ម ក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ហើយបច្ចុប្បន្ននេះបន្ទាប់ពីបានចុះបញ្ជីក្នុងប្រទេស សហព័ន្ធបាននិងកំពុងចុះបញ្ជីនៅលើទីផ្សារអន្តរជាតិប្រមាណជាង៥០ប្រទេស។

o ស្នើសុំរាជរដ្ឋាភិបាលក៏ដូចជាក្រសួងស្ថាប័នពាក់ព័ន្ធ គួរបញ្ចូលក្នុងគោលនយោបាយស្រូវអង្ករ ដើម្បីជម្រុញឱ្យភាគីពាក់ព័ន្ធជួយគាំទ្រធនធាន និងផ្សព្វផ្សាយម៉ាកវិញ្ញាតកម្មអង្ករជាតិ«ម្លិះអង្គរ (Malys Angkor)»។

### 3.1.2 កិច្ចសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម៖

**កិច្ចប្រជុំពិភាក្សាពីបញ្ហានៃការនាំចេញអង្ករកម្ពុជាទៅកាន់ប្រទេសចិន លើកទី២**

នៅព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ លោក **មូល សារិទ្ធី** អគ្គលេខាធិការនិងជាតំណាងឯកឧត្តមប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងសមាជិករោងម៉ាស៊ីនចំនួន៤០ ដែលបានចុះឈ្មោះនិងបានផ្ញើបញ្ជីឈ្មោះទៅកាន់ក្រុមអធិការកិច្ចចិនជាលើកទី២ បានចូលរួមប្រជុំពិភាក្សាពីបញ្ហានៃការនាំចេញអង្ករកម្ពុជាទៅកាន់ប្រទេសចិន ក្រោមអធិបតីភាពឯកឧត្តម **ងិន ឆាយ** អគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម ដោយមានការចូលរួមពីតំណាងក្រសួងពាណិជ្ជកម្ម។

ឯកឧត្តម ងិន ឆាយ បានលើកឡើងថា៖



កាលពីខែមីនា ឆ្នាំ២០១៩ បានទទួលលិខិតពីភាគីចិន បានស្នើឱ្យយើងធ្វើការវាយតម្លៃឡើងវិញឱ្យបានហ្មត់ចត់លើរោងម៉ាស៊ីនទាំង៤០ដែលមានក្នុងបញ្ជីខាងចិនគេកំពុងរៀបចំផ្ទេរពីAQSIQ ចូលទៅ GACC អគ្គនាយករដ្ឋបាលគយនៃប្រទេសចិនអគ្គនាយកដ្ឋានកសិកម្ម បាននិងកំពុងធ្វើការទំនាក់ទំនងជំរុញលើការងារនេះ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។ បន្ទាប់ពីស្តាប់បទបង្ហាញស្តីពីការវិវត្តនៃការងារពាក់ព័ន្ធនឹងការនាំចេញ និងវិធានការអនាម័យនិងភូតគាមអនាម័យ អង្គប្រជុំបានពិភាក្សាយ៉ាងផុសផុល និងជាលទ្ធផលមានដូចខាងក្រោម៖

- អគ្គនាយកដ្ឋានកសិកម្មនឹងចុះវាយតម្លៃរោងម៉ាស៊ីនដែលមានក្នុងបញ្ជីចំនួន៤០ ក្នុងពេលឆាប់ៗខាងមុខ រួចនឹងធ្វើលិខិតនិងបញ្ជីឈ្មោះរោងម៉ាស៊ីនដែលវាយតម្លៃជាប់ មានគ្រប់លក្ខខណ្ឌតម្រូវដើម្បីបញ្ជូនទៅកាន់ភាគីចិនឱ្យបានឆាប់។
- អគ្គនាយកដ្ឋានកសិកម្ម ពិតជារីករាយនិងទទួលកិច្ចសហការតាមសំណើរបស់សហព័ន្ធស្រូវអង្ករកម្ពុជាក្នុងការចូលរួមសម្របសម្រួលនិងអង្កេតការណ៍សម្រាប់ការចុះវាយតម្លៃនេះ។
- អគ្គនាយកដ្ឋានកសិកម្ម នឹងបើកវគ្គបណ្តុះបណ្តាលនាពេលឆាប់ៗ មុនពេលចុះវាយតម្លៃដើម្បីឱ្យយើងបានត្រៀមខ្លួននិងរៀបចំឱ្យបានគ្រប់តាមលក្ខខណ្ឌ។
- អគ្គនាយកដ្ឋានកសិកម្ម នឹងបន្តផ្តល់សេវាកម្មរបស់ខ្លួន ពិសេសបញ្ហាការវាយតម្លៃនិងចេញនូវវិញ្ញាបនបត្រអនាម័យនិងភូតគាមអនាម័យឱ្យបានកាន់តែល្អ និងរហ័ស។
- អគ្គនាយកដ្ឋានកសិកម្ម សំណូមពរដល់សមាជិកក្រុមហ៊ុននាំចេញ ប្រសិនបើក្នុងករណីមានការយកលុយក្រៅផ្លូវការ ឬមានការបង្អាក់ការចេញវិញ្ញាបនបត្រ សូមរាយការណ៍មកអគ្គនាយកដ្ឋានផ្ទាល់ ឬសហព័ន្ធស្រូវអង្ករកម្ពុជាដើម្បីដោះស្រាយជូន។

ក្នុងនោះដែរអង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១២:០០នាទីរសៀល និងថតរូបទុកជាអនុស្សាវរីយ៍ ប្រកបដោយភាពស្និទ្ធស្នាល និងលទ្ធផលល្អ។

**កិច្ចប្រជុំពិភាក្សាស្វែងរកដំណោះស្រាយ និងចាត់វិធានការក្នុងករណីការនាំចូលនិងប្រើប្រាស់ពូជស្រូវ OM**



នៅព្រឹកថ្ងៃពុធ ២រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ លោក **ស៊ី វ៉ានី** អនុប្រធានសហព័ន្ធនិងជាតំណាង ឯកឧត្តម សុខ ពុទ្ធិវុធ ប្រធានសហព័ន្ធស្រូវអង្ករ ព្រមទាំងមានការសម្របសម្រួលពីលោក **មូល សារិទ្ធី** អគ្គលេខាធិការ និងសមាជិកសមាជិកា បានចូលរួម «កិច្ចប្រជុំពិភាក្សាស្វែងរកដំណោះស្រាយ និងចាត់វិធានការក្នុងករណីចាំបាច់ចំពោះការនាំចូលនិងប្រើប្រាស់ពូជស្រូវOM» ដែលកិច្ចប្រជុំនេះបានប្រព្រឹត្តទៅនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រោមអធិបតីភាព ឯកឧត្តម ម៉ម អំណត់ រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ព្រមទាំងមានការចូលរួមពីឯកឧត្តម ងិន ឆាយ ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម និងលោកលោកស្រីប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមកពីបណ្តារខេត្តនានា។

ក្រោយពីបានពិភាក្សាគ្នាយ៉ាងផុសផុលរួចមក ឯកឧត្តមប្រធានអង្គប្រជុំបានបញ្ជាក់ពីជំហរគាំទ្រឱ្យមានការដោះស្រាយ និងជួយសម្រួលនូវសំណើផ្សេងៗរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ហើយឯកឧត្តមក៏បានបញ្ជាក់ទៅកាន់អគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្មគ្រប់ខេត្តក្រុងទាំងអស់ ត្រូវបំពេញកាតព្វកិច្ចឲ្យបានល្អនិងចូលរួមសហការជាមួយសហព័ន្ធស្រូវអង្ករឲ្យកាន់តែស្អិតរមួតថែមទៀត។ ជាលទ្ធផលនៃកិច្ចប្រជុំ មានដូចខាងក្រោម៖

- ក្រសួងបានបញ្ជាក់ថា ពុំទាន់មានក្រុមហ៊ុនណាមួយដែលបានចុះបញ្ជីនាំចូលពូជស្រូវOM ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទនោះទេ ដោយការហូរចូលនោះមានលក្ខណៈក្រៅផ្លូវការតាមរយៈឈ្មួញកណ្តាលណាមួយលួចនាំចូលទៅកាន់កសិករ ហើយបន្តចែកចាយពីកសិករមួយទៅកសិករមួយទៀត ដែលដំណើរការនេះវាបានរីកសាយភាយលឿនដោយសារពួកគាត់ទទួលបានទីផ្សារទិញស្រូវយកទៅវិញ។ ចំណុចនេះ ក្រសួងបានបញ្ជាក់ថានឹងយកចិត្តទុកដាក់លើបញ្ហានេះឱ្យបានស៊ីជម្រៅ រួចនឹងមានវិធានការណាមួយនាពេលខាងមុខ។



- ក្រសួងបានស្នើឱ្យអគ្គនាយកដ្ឋានកសិកម្មពិនិត្យផ្លូវច្បាប់ឡើងវិញ និងផ្សព្វផ្សាយច្បាប់ស្តីពីពូជដំណាំនេះឱ្យបានទូលំទូលាយដើម្បីចៀសវាងការប្រើប្រាស់ពូជស្រូវមិនបានត្រឹមត្រូវនិងមិនមានគុណភាពល្អគ្រប់គ្រាន់ ដោយក្រសួងនឹងបង្កើតឱ្យមាននាយកដ្ឋានពូជដំណាំ និងគណៈកម្មាធិការបញ្ចេញពូជដំណាំមួយ ដើម្បីធ្វើការងារបច្ចេកទេសនិងចុះវាយតំលៃដល់ទីតាំងផលិតពូជនានាមុននឹងអនុញ្ញាតឲ្យបញ្ចេញពូជដំណាំចែកចាយ។

- ក្រសួងគាំទ្រលើផលិតកម្មពូជស្រូវ ដោយចាត់ឱ្យអគ្គនាយកដ្ឋានកសិកម្មនិងមន្ទីរកសិកម្មទាំងអស់ ចូលរួមសហការ និងជួយផ្សព្វផ្សាយពីក្រុមហ៊ុនឬសហគមន៍នានាដែលបានផលិតពូជស្រូវ ដើម្បីយើងជំរុញឱ្យបង្កើនការប្រើប្រាស់ពូជស្រូវក្នុងស្រុកដែលយើងមានស្រាប់។

- ក្រសួងនឹងគាំទ្រ ទាំងផ្នែកបច្ចេកទេស ការសម្របសម្រួល និងរៀបចំបទដ្ឋានគតិយុត្តិនានា ដើម្បីគាំទ្រលើវិស័យនេះ។

- ស្នើសុំឱ្យខាងIRRI ជួយជំរុញការបញ្ចេញពូជ IR មួយប្រភេទទៀតដែលមានគុណសម្បត្តិស្រដៀងគ្នានឹងពូជOM ដើម្បីចុះបញ្ជីជាពូជជាតិ និងដាក់ផ្សព្វផ្សាយឱ្យប្រើប្រាស់ នោះអាចជួយកាត់បន្ថយការប្រើប្រាស់ពូជនាំចូលបានមួយផ្នែក។

- ស្នើឱ្យវិស័យឯកជន ពិសេសសមាជិកក្រុមហ៊ុននាំចេញនិងរោងម៉ាស៊ីននៃសហព័ន្ធស្រូវអង្ករកម្ពុជា ជួយគាំទ្រនិងអនុវត្តលើកិច្ចសន្យាកសិកម្ម(Contract Farming) ដើម្បីជួយធានាទៅវិញទៅមករវាងអ្នកផលិតនិងអ្នកទិញនូវការជាជុះស្រូវចំតម្រូវការទីផ្សារ ទទួលបានតម្លៃសមរម្យ និងមានគុណភាពល្អ ហើយអាចជួយកាត់បន្ថយបាន-នូវការប្រើប្រាស់ពូជនាំចូលបានមួយផ្នែក។ ទន្ទឹមនឹងនេះដែរក្រសួង បាននិងកំពុងរៀបចំច្បាប់ស្តីពីកិច្ចសន្យាកសិកម្មនេះ ពិសេសនឹងរៀបចំឱ្យមានយន្តការមួយក្នុងការសម្របសម្រួលរវាងអ្នកផលិតស្រូវនិងអ្នកទិញ ពិសេសនៅពេលមានជម្លោះត្រូវដោះស្រាយរបៀបណា ដែលនេះក៏ចំនឹងអ្វីដែលសហព័ន្ធស្រូវអង្ករកម្ពុជាបានស្នើឡើងផងដែរ។

- ក្នុងករណីមានបញ្ហាផ្សេងៗពេលខាងមុខ ក្រសួងនឹងជួយសម្រួលដោះស្រាយបញ្ហាជូនតាមរយៈអគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្មតាមបណ្តាខេត្តក្រុងទាំងអស់ ឬលើកសំណើមកខាងលើប្រសិនបើមិនអាចដោះស្រាយនៅថ្នាក់មូលដ្ឋានបាន។

## ចូលរួមសិក្ខាសាលា ស្តីពីរបាយការណ៍បញ្ហាប្រឈម និងទិសដៅបន្តក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

នៅព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ លោក **មូល សារិទ្ធិ** អគ្គលេខាធិការនិងជាតំណាងឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករ ព្រមទាំងសមាជិកសមាជិកា បានចូលរួមកម្មវិធីសិក្ខាសាលា ស្តីពីរបាយការណ៍ បញ្ហាប្រឈម និងទិសដៅបន្តក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ក្រោមអធិបតីភាព ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

នៅក្នុងឱកាសនៃមតិបើកកម្មវិធី **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** បានលើកពីបញ្ហាប្រឈមមួយចំនួននៅក្នុងវិស័យកសិកម្ម ដើម្បីដាក់ជូនអង្គសិក្ខាសាលាពិភាក្សានិងផ្តល់ធាតុចូលជាដំណោះស្រាយ ដូចជា៖

1. ខាងមន្ត្រីជំនាញក៏នៅមានកម្រិតដែរ
2. ជំរុញការផលិតអោយបានខ្ពស់ ពិសេសការផលិតពូជស្រូវ ពូជដំណាំ ដើម្បីយើងទទួលបាននូវផលិតផលដែលមានគុណភាពល្អ ដោយខាងក្រសួងកសិកម្ម នឹងជួយបញ្ជូនមន្ត្រីជំនាញទៅជួយដល់កសិករ




3. ទាំងរដ្ឋនិងវិស័យឯកជននៅមានការខ្វះទុន
4. ធនាគារមានអត្រាការប្រាក់ខ្ពស់សម្រាប់វិស័យកសិកម្ម
5. ខាងធនាគារនិយាយថាអត់ឃើញវិស័យឯកជនមកខ្ចីលុយទៅវិញ
6. គួរមានធនាគារ Agriculture Bankដែលមានអត្រាការប្រាក់ទាប
7. អគ្គិសនីយើងនៅមានតំលៃខ្ពស់
8. ប្រព័ន្ធស្រោចស្រពយើងនៅមានកំរិត ជាដើម។
9. ការអនុវត្តកិច្ចសន្យាកសិកម្ម នៅមានកំរិតដោយសារខាងអ្នកផលិត និងអ្នកទិញនៅមិនទាន់មានទំនុកចិត្តគ្នាខ្ពស់នៅពេលមានភាគីណាមួយមិនគោរពកិច្ចសន្យាកន្លងមកយើងបាននៅមិនទាន់មានក្រុមណាមួយទទួលខុសត្រូវសម្របសម្រួលនិងដោះស្រាយជូនពួកគាត់។ ហេតុដូចនេះហើយ បានជាក្រសួងកសិកម្ម កំពុងរៀបចំពង្រាងនិងដាក់ប្រជុំពិភាក្សាដើម្បីប្រមូលធាតុចូល និងមតិយោបល់នាថ្ងៃនេះ។

ក្នុងឱកាសនោះ លោក មូល សារិទ្ធិ បានបញ្ជាក់ពីជំហរចូលរួមសហការ និងស្នើអង្គប្រជុំបញ្ចូលសហព័ន្ធស្រូវអង្ករកម្ពុជាចូលរួមក្រុមការងារបច្ចេកទេសដើម្បីសម្របសម្រួលនិងដោះស្រាយបញ្ហាលើកិច្ចសន្យាកសិកម្ម ហើយថែមទាំងបានចែករំលែកពីធាតុចូលក្នុងការចូលរួមដោះស្រាយពីភាពមិនទុកចិត្តគ្នារវាងសហគមន៍កសិករជាមួយអ្នកទិញ ឬរោងម៉ាស៊ីន ក្នុងការជម្រុញអោយភាគីទាំងពីរធ្វើកិច្ចសន្យាកសិកម្ម។

ជាលទ្ធផល បន្ទាប់ពីបានពិភាក្សាយ៉ាងផុសផុលរួចមក ដើម្បីជាដំណោះស្រាយបញ្ហាប្រឈមទាំងឡាយ និងជម្រុញកិច្ចសន្យាកសិកម្មនេះ ឯកឧត្តមរដ្ឋមន្ត្រីប្រធានអង្គប្រជុំ បានសម្រេចអោយរៀបចំបង្កើតក្រុមការងារបច្ចេកទេសមួយដែលមានតំណាងក្រសួងស្ថាប័ន និងវិស័យឯកជនចូលរួម។

## គម្រោងផលិតកម្មស្បៀង មានទឹកប្រាក់២០លានដុល្លារ របស់រាជរដ្ឋាភិបាលកម្ពុជា

នាថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ នៅអគ្គនាយកដ្ឋានកសិកម្មមានកិច្ចប្រជុំនៃគណៈកម្មាធិការតម្រង់ទិស សម្រាប់គម្រោងផលិតកម្មស្បៀងប្រព្រឹត្តឡើងក្រោមអធិបតីភាព ឯកឧត្តម **ទី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការតម្រង់ទិសនៃគម្រោង។ កិច្ចប្រជុំនេះមានសមាសភាពចូលរួមពីតំណាងក្រសួងកសិកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជាដែលដឹកនាំដោយ ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ក៏ជាសមាជិកម្នាក់នៃគណៈកម្មាធិការតម្រង់ទិសនេះដែរ។ គម្រោងជំរុញផលិតកម្មស្បៀង ជាគម្រោងដែលឧបត្ថម្ភថវិកាដោយរាជរដ្ឋាភិបាលកម្ពុជាផ្ទាល់ ចំនួន ២០លានដុល្លារអាមេរិក លើគម្រោងបង្កើនផលិតកម្មស្រូវក្រអូប និងផលិតកម្មបន្លែ។ គម្រោងមានរយៈពេល៣ឆ្នាំគឺ២០១៦-២០១៨សំដៅបង្កើនពូជស្រូវក្រអូបសរុបអោយបាន ១៥,០០០ តោន នៅក្នុងរយៈពេលសាកល្បងនៅខេត្តចំនួន៣ និងបង្កើនការផលិតបន្លែសរុបអោយបាន៦ម៉ឺនតោនក្នុងមួយឆ្នាំ នៅខេត្ត ចំនួន៨ ដើម្បីជម្រុញផលិតកម្មស្បៀង ឆ្លើយតបតម្រូវការស្បៀងនៅក្នុងទីផ្សារ។

## កិច្ចប្រជុំរវាងអគ្គនាយកដ្ឋានកសិកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជាលើបញ្ហាសហគមន៍អឺរ៉ុបហាមឃាត់ការនាំចូលអង្ករដែលមានសារធាតុទ្រីស៊ីក្លាហ្សូល ( Tricyclazole ) លើស0,0១មីលីក្រាមក្នុងមួយគីឡូក្រាមអង្ករ

នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧ ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា និងសមាជិករបស់ខ្លួន បានជួបប្រជុំពិសេសជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកសិកម្ម ដើម្បីពិភាក្សាការងារសំខាន់ៗ ដែលកំពុងប្រឈមនាពេលបច្ចុប្បន្ន។



កិច្ចប្រជុំនេះក្រោមអធិបតីភាព ឯកឧត្តម **ហ៊ាន វណ្ណហាន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម និង ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា ដែលដឹកនាំដោយអនុប្រធាន រួមមាន ឧកញ៉ា **ហ៊ុន ឡាក់** និង លោក **នេង វាសនា** និង មានការចូលរួមពីលោក **ចាន់ សុខនី** សមាជិកក្រុមប្រឹក្សាភិបាល ព្រមទាំងតំណាងរោងម៉ាស៊ីន និងក្រុមហ៊ុននាំចេញមួយចំនួនទៀត។ អង្គប្រជុំបានលើកនូវសំណើមួយចំនួនពាក់ព័ន្ធដល់ការនាំចេញទៅកាន់ទីផ្សារប្រទេសចិន និងទីផ្សារសហភាពអឺរ៉ុប ដើម្បីសម្រួលដល់ការនាំចេញឲ្យបានប្រសើរ និងមានភាពរលូន និងការជជែកពីវិធានការរបស់សហភាពអឺរ៉ុបចំពោះការហាមឃាត់ការនាំចូលអង្ករដែលមានសារធាតុទ្រីហ្ស៊ីក្លាហ្សូល Tricyclazole លើសពី0,0១មីលីក្រាមក្នុងមួយគីឡូក្រាមអង្ករ។

ជាលទ្ធផលនៃកិច្ចប្រជុំ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្មបានយល់ព្រមលើចំណុច ដូចខាងក្រោម៖

១. អគ្គនាយកដ្ឋានកសិកម្ម ទទួលយកសំណើរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីរៀបចំរបាយការណ៍ដាក់សុំការសម្រេចពី ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវបន្តការចេញ ឬផ្អាក នូវវិញ្ញាបនបត្រអនាម័យនិងភូតគាមអនាម័យ (Sanitary and Phytosanitary) ដល់ក្រុមហ៊ុននាំចេញផ្សេងៗដែលមានកិច្ចសន្យារួចហើយ និង កំពុងអនុវត្តកិច្ចសន្យានាំចេញទៅចិន ក្រៅពីក្រុមហ៊ុនដែលមានក្នុងបញ្ជីរបស់ AQSIQ (General Administration of Quality Supervision, Inspection and Quarantine) ក្រោយពិនិត្យនិងវាយតម្លៃកាលពីចុងឆ្នាំ២០១៦។

២. អគ្គនាយកដ្ឋានកសិកម្មត្រូវរៀបចំសិក្ខាសាលាមួយ ដើម្បីអញ្ជើញក្រុមហ៊ុននាំចេញនិងរោងម៉ាស៊ីនទាំង៥៥ ដើម្បីស្នើឲ្យមន្ត្រី AQSIQ ចុះមកពិនិត្យនិងវាយតម្លៃជាលើកទី២ ដើម្បីទទួលបានការអនុញ្ញាតក្នុងការកិនកែច្នៃ និងវេចខ្ចប់នាំចេញទៅកាន់ទីផ្សារចិនបាន។
សម្រាប់នីតិវិធី ខាងអគ្គនាយកដ្ឋានកសិកម្ម នឹងចុះទៅត្រួតពិនិត្យនិងវាយតំលៃជាបឋមសិន មុននឹងបញ្ជូនបញ្ជីឈ្មោះរោងម៉ាស៊ីនជាប់ទៅកាន់ភាគីចិនដើម្បីស្នើសុំអោយមន្ត្រីរបស់ AQSIQ ចុះមកវាយតម្លៃជាលើកទី២។

៣. អគ្គនាយកដ្ឋានកសិកម្មនឹងសហការជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា រៀបចំកិច្ចប្រជុំ ឬសិក្ខាសាលាថ្នាក់ជាតិដោយមានអញ្ជើញអ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យស្រូវអង្កររួមមានមន្ទីរកសិកម្ម សមាជិកសហព័ន្ធ សហគមន៍កសិករ ដៃគូអភិវឌ្ឍន៍នានា ពាណិជ្ជករលក់ថ្នាំនិងចែកចាយថ្នាំកសិកម្ម ដើម្បីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពីការប្រើប្រាស់ និងផល ប៉ះពាល់ព្រមទាំងការចូលរួមទប់ស្កាត់ការប្រើប្រាស់ថ្នាំទ្រីហ្ស៊ីក្លាហ្សូល (Tricyclazole) នៅក្នុងផលិតកម្មដំណាំស្រូវ។





**កិច្ចប្រជុំរវាងអគ្គនាយកដ្ឋានកសិកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា កាលពីខែមេសា ឆ្នាំ២០១៧**

## **កិច្ចប្រជុំរវាងអគ្គនាយកដ្ឋានកសិកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជាលើការផ្ទៀងផ្ទាត់ឈ្មោះរោងម៉ាស៊ីនឲ្យបានត្រឹមត្រូវដែលបានជាប់ក្នុងការវាយតម្លៃរបស់ AQSIQ លើកទី១ ដើម្បីបញ្ជូនទៅប្រទេសចិន**

ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧ មានកិច្ចប្រជុំមួយនៅអគ្គនាយកដ្ឋានកសិកម្ម ជាមួយសមាជិករោងម៉ាស៊ីនចំនួន២៦ក្រុមហ៊ុនដែលបានជាប់ការវាយតំលៃលើកទី១របស់ AQSIQ ដោយមានតំណាងសហព័ន្ធស្រូវអង្ករកម្ពុជា លោក **នង វាសនា** និងមន្ត្រីលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជាចូលរួមផងដែរ។



កិច្ចប្រជុំនេះមានគោលបំណងដើម្បីផ្ទៀងផ្ទាត់ឈ្មោះឡើងវិញឲ្យបានត្រឹមត្រូវដើម្បីបញ្ជូនឈ្មោះទៅប្រទេសចិនក្នុងពេលឆាប់ៗ។ ក្នុងនោះដែរអគ្គនាយកដ្ឋានកសិកម្មសំណូមពរឲ្យសមាជិកទាំងអស់បំពេញឈ្មោះនិងអាសយដ្ឋានឲ្យបានត្រឹមត្រូវនៅចំពោះមុខអង្គប្រជុំតែម្តងនិងចុះហត្ថលេខាទទួលស្គាល់ផងដែរ។ សម្រាប់រោងម៉ាស៊ីនដែលដាក់ពាក្យលើកទី២ អគ្គនាយដ្ឋានកសិកម្ម នឹងចុះត្រួតពិនិត្យដូចគ្នានឹងរោងម៉ាស៊ីនដែលបានជាប់លើកទី១ផងដែរ។ ជាងនេះទៅទៀតអគ្គនាយកដ្ឋានកសិកម្មស្នើសុំឲ្យសមាជិករោងម៉ាស៊ីនត្រៀមរៀបចំនូវឯកសាររដ្ឋបាលឲ្យបានគ្រប់គ្រាន់ និងត្រូវសម្អាតរោងម៉ាស៊ីនឲ្យមានអនាម័យល្អរួមទាំងបរិស្ថានជុំវិញផងដែរ។

## **ចូលរួមបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៧-២០១៨ និងលើកទិសដៅឆ្នាំ២០១៨-២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

តំណាងសហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមកម្មវិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៧-២០១៨ និងលើកទិសដៅឆ្នាំ២០១៨-២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃពុធ ៣រោច ខែពិសាខ ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

តាមរយៈសុន្ទរកថារបស់ ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានជម្រាបជូនសម្តេចតេជោនាយករដ្ឋមន្ត្រី និងអង្គពិធីទាំងមូលថា វិស័យកសិកម្មកម្ពុជានៅមានបញ្ហាប្រឈមជាច្រើនដែលបាននិងកំពុងជួបប្រទះ និងត្រូវដោះស្រាយ។

ទន្ទឹមនឹងនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ កំពុងរៀបចំផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០។ ក្រសួងកសិកម្មបានប្រកាសដាក់អោយប្រើពូជស្រូវថ្មីមួយទៀតដែលឈ្មោះ«ផ្កាមាលតី» ដែលជាពូជស្រូវក្រអូបប្រណីត ប្រកាន់រដូវ តែធននឹងការប្រែប្រួលអាកាសធាតុ។



## 3.2 កិច្ចសហការជាមួយក្រសួងពាណិជ្ជកម្ម

សហព័ន្ធស្រូវអង្ករកម្ពុជា បានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយក្រសួងពាណិជ្ជកម្ម ហើយតាមរយៈកិច្ចប្រជុំជាច្រើនលើក ភាគីទាំងពីរបានសម្រេចនូវការងារចំបងៗជាច្រើន ដូចជា៖

### ការបង្កើតក្រុមការងាររួមជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យស្រូវអង្ករ

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានដឹកនាំក្រុមប្រឹក្សាភិបាលនិងក្រុមការងារលេខាធិការដ្ឋាន ចូលជួបសំដែងការគួរសមជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលអាណត្តិទី២រួច អង្គប្រជុំបានសម្រេច៖



- បង្កើតក្រុមការងាររួមរវាងក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីដោះស្រាយបញ្ហានានាដែលបានស្នើដោយសហព័ន្ធស្រូវអង្ករកម្ពុជា
- ក្រសួងបានសន្យាថា ជួយពន្លឿនការចុះបញ្ជីម៉ាកអង្ករជាតិ "ម្លិះអង្គរ (Malys Angkor)"
- ក្រសួងបានចេញនូវបទបញ្ញត្តិមួយដែលចែងថា រាល់ការអនុញ្ញាតឲ្យនាំចូលអង្ករនិងការដាក់លក់លើទីផ្សារ ត្រូវមានព័ត៌មានអំពី អាសយដ្ឋាន ម៉ាកយីហោ និងប្រភពច្បាស់លាស់។ ពិសេសបានអនុញ្ញាតអោយសហព័ន្ធស្រូវអង្ករកម្ពុជា ចូលរួមអង្កេតការណ៍តាមការចាំបាច់ក្នុងករណីមានការនាំអង្ករចូលណាដែលសង្ស័យ




- ក្រសួងបានយល់ព្រមក្នុងការបង្កើនកូតានាំចូលទៅប្រទេសចិន និងបានអនុញ្ញាតឲ្យសហព័ន្ធចូលរួមជាអ្នកសម្របសម្រួលក្នុង MoU ជាមួយCOFCO
- ក្រសួងយល់ព្រមជម្រុញគម្រោងវិនិយោគក្រោមហិរញ្ញប្បទានពីប្រទេសចិនដើម្បីជម្រុញផលិតកម្មស្រូវនិងបង្កើនការនាំចេញអង្ករ តាមរយៈការវិនិយោគឃ្លាំងស្តុក និងឡសម្ងួត
- បញ្ហាផ្សេងពីវិស័យស្រូវអង្ករ ដូចជា ការពិភាក្សាស្តីពីការជម្រុញការចុះបញ្ជីម៉ាកសំគាល់ភូមិសាស្ត្រអង្ករកម្ពុជា GI ជាដើម នៅមិនទាន់បានចាប់ផ្តើមសិក្សានៅឡើយ។

### ការគាំទ្រឲ្យមានទីតាំងបង្ហាញផលិតផលដើម្បីលើកកម្ពស់ការទទួលស្គាល់អង្ករកម្ពុជាកាន់តែប្រសើរ

ក្នុងកិច្ចប្រជុំកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ សុភ័ក្រ្ត** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ព្រមទាំងមានវត្តមាន លោក **មូល សារិទ្ធី** អគ្គលេខាធិការ និងជាតំណាងសហព័ន្ធស្រូវអង្ករកម្ពុជា សម្ព័ន្ធសមាគមឧស្សាហកម្មធុនតូច និងមធ្យមកម្ពុជា សហគ្រិនវ័យក្មេងកម្ពុជា សមាគមសហគ្រិនស្ត្រីកម្ពុជា សហព័ន្ធអ្នកជំនួញកម្ពុជា សមាគមពាណិជ្ជកម្មកម្ពុជា អ្នកចូលរួមបានបង្ហាញពីនិន្នាការប្រើប្រាស់ផលិតផលខ្មែរក្រោយយុទ្ធនាការទិញផលិតផលខ្មែរ ដែលរៀបចំឡើងដោយក្រសួងពាណិជ្ជកម្ម។ ដើម្បីផ្សព្វផ្សាយផលិតផលខ្មែរឲ្យកាន់តែទូលំទូលាយនិងលើកកម្ពស់ការទទួលស្គាល់ក្នុងចំណោមជនបរទេស អ្នកចូលរួមបានស្នើឲ្យក្រសួងពាណិជ្ជកម្មសម្របសម្រួលជាមួយម្ចាស់សណ្ឋាគារ ហាងលក់ទំនិញ រៀបចំដាក់តាំងផលិតផលខ្មែរបានច្បាស់លាស់ ងាយស្រួលដល់ការ ទស្សនាដល់ភ្ញៀវបរទេស។



### ចូលរួមមហាសន្និបាតរបស់ក្រសួងពាណិជ្ជកម្ម

- មហាសន្និបាតឆ្នាំ២០១៧៖ ថ្ងៃទី២៦-២៧ ខែធ្នូ ឆ្នាំ២០១៦ តំណាងសហព័ន្ធស្រូវអង្ករកម្ពុជា លោក **មូល សារិទ្ធី** អគ្គលេខាធិការ សហព័ន្ធបានចូលរួមមហាសន្និបាតបូកសរុបការងារឆ្នាំ២០១៦ និងលើកទិសដៅឆ្នាំ២០១៧ របស់ក្រសួងពាណិជ្ជកម្ម ក្រោមអធិបតីភាព ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនេះ សហព័ន្ធស្រូវអង្ករកម្ពុជា បានស្នើឡើងពីបញ្ហាកង្វល់ផ្សេងៗរបស់សមាជិកសម្រាប់វិស័យស្រូវអង្ករកម្ពុជាទាំងមូល លើការងារសម្រួលពាណិជ្ជកម្ម និងការស្វែងរកទីផ្សារអង្ករកម្ពុជា ដើម្បីក្រសួងក៏ដូចជារដ្ឋាភិបាលពិនិត្យ និងដោះស្រាយតាមរយៈការបញ្ចូលក្នុងផែនការក្រសួងឆ្នាំ២០១៧ និងឆ្នាំបន្តបន្ទាប់។

- មហាសន្និបាតឆ្នាំ២០១៨៖ ឯកឧត្តម **នង វាសនា** អនុប្រធាន និងជាតំណាងឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា បានអញ្ជើញចូលរួមនិងផ្តល់ចំណាប់អារម្មណ៍ក្នុងកម្មវិធីបើកមហាសន្និបាតនៃក្រសួងពាណិជ្ជកម្ម ក្រោមអធិបតីភាពឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅថ្ងៃចន្ទ ២រោច ខែមិគសិរ ឆ្នាំចសំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨។

ក្នុងឱកាសដ៏មានសារៈសំខាន់នេះ ក្រៅពីការលើកឡើងអំពីសមិទ្ធផលរបស់សហព័ន្ធស្រូវអង្ករកម្ពុជា និងកិច្ចសហការជាមួយក្រសួងពាណិជ្ជកម្ម និងស្ថាប័នពាក់ព័ន្ធ ឯកឧត្តម **នង វាសនា** បានចូលរួមផ្តល់នូវធាតុចូលនានា និងលើកយកនូវចំណុចមួយចំនួនរបស់សហព័ន្ធដើម្បីសុំអោយក្រសួងពាណិជ្ជកម្មនិងក្រសួង-ស្ថាប័នពាក់ព័ន្ធចូលរួមនិងបន្តកិច្ចសហការជាមួយសហព័ន្ធក្នុងការដោះស្រាយបញ្ហានានានិងជំរុញឲ្យវិស័យស្រូវអង្ករកម្ពុជាអាចបន្តសម្រេចបានជោគជ័យថែមទៀតនៅថ្ងៃខាងមុខ។

## កិច្ចប្រជុំការកែសម្រួលខ្លឹមសារក្រមសីលធម៌នៃអ្នកនាំចេញ



នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំរវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងពាណិជ្ជកម្មបានយល់ព្រមតាមសំណើរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលមានបំណងកែសម្រួលលក្ខខណ្ឌខ្លះ និងពង្រីកវិសាលភាពនៃការគ្រប់ដណ្តប់សម្រាប់ទិសដៅនាំចេញ។ ក្នុងកិច្ចប្រជុំនោះ លោក មូល សារិទ្ធី អគ្គលេខាធិការសហព័ន្ធស្រូវអង្ករកម្ពុជា បានលើកឡើងពីលក្ខខណ្ឌនៃក្រមសីលធម៌ដែលបានអនុវត្តកាលពីឆ្នាំ២០១៤ បានផ្តោតសំខាន់តែលើទីផ្សារអឺរ៉ុប ហើយលក្ខខណ្ឌបន្ថែមនឹងត្រូវគ្របដណ្តប់ដល់ទីផ្សារចិន ស្របពេលបច្ចុប្បន្ន ទីផ្សារអង្ករកម្ពុជានាំទៅកាន់ទីផ្សារចិន កាន់តែមានច្រើនឡើងៗជាលំដាប់។

ជាការឆ្លើយតប ឯកឧត្តម **សុខ សុភ័ក្រ** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមនេះ ព្រោះវាចាំបាច់ត្រូវតែកែសម្រួលលក្ខខណ្ឌស្របទៅតាមភាពរីកចម្រើន។ ឯកឧត្តមក៏បានប្រគល់ការងារបច្ចេកទេសនេះទៅខាងនាយកដ្ឋានជំនាញនៃក្រសួងពាណិជ្ជកម្មនិងគណៈកម្មាធិការក្រមសីលធម៌និងវិន័យ នៃសហព័ន្ធស្រូវអង្ករកម្ពុជាធ្វើការសហការគ្នា ហើយក្រសួងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សហព័ន្ធស្រូវអង្ករជជែករឿងលក្ខខណ្ឌដែលត្រូវកែសម្រួល និងលក្ខខណ្ឌត្រូវបំពេញបន្ថែម។

## រៀបចំវេទិកាពិភាក្សាផ្តោតលើការផ្សារភ្ជាប់ផលិតផលនិងទីផ្សារ



ក្រុមប្រឹក្សាភិបាល សមាជិក និងលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជាដែលដឹកនាំដោយ ឯកឧត្តម **សុខ ពុទ្ធិវុធ** បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់រវាងអ្នកផលិត និងអ្នកផ្គត់ផ្គង់ផលិតផលខ្មែរ ជាមួយអ្នកប្រើប្រាស់និងអ្នកចែកចាយបន្ត រៀបចំឡើងដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧។

សិក្ខាសាលានេះ គឺជាលើកទី២ ក្រោយការរៀបចំលើកទី១កាលពីឆ្នាំ២០១៦ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង៤ រួមមានៈ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម, ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, ឯកឧត្តម **ទិត ចន្ថា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ ព្រមទាំងតំណាងវិស័យឯកជនមកពីអ្នកផលិត អ្នកចែកចាយ(ផ្សារទំនើប) និងអ្នកប្រើប្រាស់(សណ្ឋាគារ និងភោជនីយដ្ឋាន ជាដើម)។

## កិច្ចប្រជុំរវាងក្រសួងពាណិជ្ជកម្មនិងសហព័ន្ធស្រូវអង្ករកម្ពុជារកដំណោះស្រាយលើការកំរិតនៃសារធាតុ Tricyclazole

តបតាមសំណើរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងពាណិជ្ជកម្ម ដឹកនាំដោយ ឯកឧត្តម សុខ សុភ័ក្រ អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានទទួលជួបក្រុមការងារចំរុះក្នុងវិស័យស្រូវអង្ករដឹកនាំដោយ ឯកឧត្តម **នង វាសនា** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីពិភាក្សារកដំណោះស្រាយក្នុងវិស័យស្រូវអង្ករ កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧។

## កិច្ចប្រជុំ ស្តីពីបច្ចុប្បន្នភាពនៃសភាពការណ៍ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា ជាមួយដៃគូក្នុងតំបន់និងពិភពលោក



នៅព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ ឯកឧត្តម **សុខ ពុទ្ធិវុធ** បានចាត់ឯកឧត្តម **នង វាសនា** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំសមាជិកក្រុមហ៊ុននាំចេញ ចូលរួម«កិច្ចប្រជុំ ស្តីពីបច្ចុប្បន្នភាពនៃសភាពការណ៍ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា ជាមួយដៃគូក្នុងតំបន់និងពិភពលោក» ក្រោមអធិបតីភាព ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

ជាលទ្ធផល ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានទទួលយកនូវសំណើ និងបញ្ហានានាដែលបានស្នើឡើងពីវិស័យឯកជន ដើម្បីពិនិត្យលទ្ធភាពដោះស្រាយអោយបានសមស្របជូនវិស័យឯកជន ហើយក្រសួងពាណិជ្ជកម្មកំពុងតែទាញយកបច្ចេកវិទ្យាផ្សេងៗមកជួយសម្រួលការងារផងដែរ។

## កិច្ចសហការនិងប្រជុំពិភាក្សាជាច្រើនលើក ដើម្បីរៀបចំឯកសារនិងរៀបចំឯកសារ ដោះស្រាយបញ្ហានានាដែលទាក់ទងនឹងការស៊ើបអង្កេតរបស់សហភាពអឺរ៉ុបលើការនាំចេញអង្ករទៅកាន់ទីផ្សារសហភាពអឺរ៉ុប និងការដាក់ពន្ធរបស់សហភាពអឺរ៉ុបលើអង្ករកម្ពុជា ដូចជាៈ



- ថ្ងៃទី២៧ ខែមីនា២០១៨៖ សហព័ន្ធស្រូវអង្ករកម្ពុជា បានប្រជុំជាមួយក្រសួងពាណិជ្ជកម្ម សមាជិកអ្នកនាំចេញធំៗ និងCAVAC
- សហព័ន្ធស្រូវអង្ករកម្ពុជាដឹកនាំដោយ**ឯកឧត្តមប្រធាន** និងក្រសួងពាណិជ្ជកម្ម បានចូលរួមសាវនាការដើម្បីពន្យល់ដល់គណៈកម្មាធិការអឺរ៉ុបនៅទីក្រុងប្រ៊ុសសែល ប្រទេសប៊ែលសិក កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ជាដើម។

## 3.3 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ** ( The Signing Ceremony of the EPC Contract for the Promotion of Paddy Production and Rice Exports Project )

នៅព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា អញ្ជើញចូលរួមកម្មវិធីចុះហត្ថលេខារវាងកម្ពុជានិងចិនលើកិច្ចសន្យាពាណិជ្ជកម្ម ស្តីពី គម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ក្រោមអធិបតីភាពឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅក្នុងឱកាសនោះដោយមានការអញ្ជើញចូលរួមពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និងឯកអគ្គរដ្ឋទូតនៃប្រទេសចិនប្រចាំនៅកម្ពុជា និងតំណាងក្រសួងពាក់ព័ន្ធមួយចំនួន។



**កិច្ចប្រជុំ ស្តីពីវឌ្ឍនភាពការអនុវត្តវិធានការគោលនយោបាយ ដែលជាសេចក្តីសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល**

លោក មូល សារិទ្ធី អគ្គលេខាធិការ ជាតំណាង ឯកឧត្តមប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពី វឌ្ឍនភាព នៃការអនុវត្តវិធានការគោលនយោបាយ ដែលជាសេចក្តីសម្រេចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧។

កិច្ចប្រជុំនេះ បានផ្តោតលើការត្រួតពិនិត្យនិងតាមដានលើវិធានការនានាដែលបានដាក់ចេញកន្លងមកឲ្យក្រសួងស្ថាប័នពាក់ព័ន្ធយកទៅអនុវត្ត លើសពីនេះអង្គប្រជុំក៏បានដាក់ចេញនូវវិធានការថ្មីបន្ថែមទៀត ដើម្បីសម្រួលដល់វិស័យស្រូវអង្ករកម្ពុជា ទាំងកសិករ រោងម៉ាស៊ីន រហូតដល់បើកទីផ្សារនាំចេញ។ ក្រសួងសេដ្ឋកិច្ចបានដាក់ចេញឱ្យសហព័ន្ធស្រូវអង្ករកម្ពុជាមានតួនាទីចូលរួមលុបបំបាត់ការទារប្រាក់តាមផ្លូវ ដែលបង្កើនចំណាយថ្លៃដើម ធ្វើអោយប៉ះពាល់ដល់ការប្រកួតប្រជែងរបស់អង្ករកម្ពុជា៖ សហព័ន្ធស្រូវអង្ករកម្ពុជា បានចេញប្រកាសស្តីពីការសុំកិច្ចសហការពីសមាជិកទាំងអស់អោយចូលរួមលុបបំបាត់ការទារប្រាក់តាមផ្លូវ។

**កិច្ចប្រជុំ ពិភាក្សាលើសេចក្តីព្រាងបឋមនៃឯកសារពង្រាងគោលនយោបាយស្រូវអង្ករថ្មី**

ថ្ងៃទី២៧ ខែមេសា ២០១៧ តំណាងសហព័ន្ធស្រូវអង្ករកម្ពុជា លោកបណ្ឌិត **ហ៊ីន ឆារ៉ា** បានចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងបឋមនៃឯកសារពង្រាងគោលនយោបាយស្រូវអង្ករថ្មី នៅទីស្តីការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិដែលដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តម **រស់ សីលវ៉ា** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងមានការអញ្ជើញចូលរួមរបស់ ឯកឧត្តម **ហ៊ាន វណ្ណហាន** អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម **ប៉ែន សុវិជាតិ** អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម និងអ្នកពាក់ព័ន្ធមួយចំនួន។



កិច្ចប្រជុំនេះមានគោលបំណងដើម្បីប្រមូលធាតុចូលបន្ថែមសម្រាប់កែលម្អនូវសេចក្តីព្រាងគោលនយោបាយស្រូវអង្ករថ្មីឲ្យកាន់តែប្រសើរឡើង។ សហព័ន្ធស្រូវអង្ករកម្ពុជា បានធ្វើស្នើលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

+**ផ្នែកផលិតកម្ម៖**

- ជាការកត់សម្គាល់កម្លាំងពលកម្មក្នុងវិស័យស្រូវអង្ករកម្ពុជាមានការថយចុះដោយសារកសិកររក   ចំណូលបានតិចជាងមុនធៀបជាមួយនឹងវិស័យផ្សេង
- គាំទ្រមតិរបស់អគ្គនាយកដ្ឋានកសិកម្ម ដែលបានលើកឡើងថាគួរតែបង្កើនផលិតភាពរបស់កសិករ ដើម្បីបង្កើនចំណូលកសិករឲ្យប្រសើរជាងមុន។

ទន្ទឹមនឹងរកចំណូលដល់កសិករ វិធានការគ្រប់គ្រងគុណភាពដីឲ្យមាននិរន្តរភាពនិងប្រព័ន្ធធារាសាស្រ្តគួរត្រូវផ្តោតសំខាន់ក្នុងសេចក្តីព្រាងគោលនយោបាយថ្មីនេះផងដែរ។

- លទ្ធភាពក្នុងការប្រកួតប្រជែងដោយការបង្កើនទិន្នផលស្រូវតាមរយៈប្រើពូជដែលផ្តល់ទិន្នផលខ្ពស់។

- គួរកំណត់តំបន់ដាំដុះ (Zoning) ដើម្បីបញ្ចៀសការលាយឡំពូជគ្នា គួរបែងចែកតំបន់ដាំដុះសម្រាប់ នាំចេញនិងទីផ្សារក្នុងស្រុក។

**+ផ្នែកកែច្នៃ-រោងម៉ាស៊ីន**

- បញ្ហាឡសម្ងួត គួរដាក់ឲ្យបានជិតកសិករដែលជាអ្នកផលិតស្រូវ ព្រោះកសិករអាចសម្ងួតស្រូវលក់ឲ្យរោងម៉ាស៊ីន ប្រសើរជាងការលក់ស្រូវសើមដូចសព្វថ្ងៃដែលកំពុងមានការខាតបង់ដ៏ច្រើន។

- គម្រោងឃ្លាំង ដោយសារសហព័ន្ធស្រូវអង្ករមានសមាជិកជាច្រើនដូចជា អ្នកនាំចេញ រោងម៉ាស៊ីន និងសហគមន៍កសិកម្មជាដើមដែលពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករ ដូចនេះសូមស្នើសុំបញ្ចូលសហព័ន្ធស្រូវកម្ពុជាចូលរួមក្នុងការសិក្សាគម្រោងឃ្លាំងស្តុកស្រូវអង្ករដើម្បីអាចផ្តល់ជាធាតុចូលដល់គម្រោងឃ្លាំង។

- ការផ្តល់ឥណទានដល់រោងម៉ាស៊ីនត្រូវមានយន្តការក្នុងការផ្តល់ឲ្យបានច្បាស់លាស់និងស្របទៅតាមវិស័យស្រូវអង្ករ ចៀសវាងរោងម៉ាស៊ីនយកថវិកាទាំងនោះទៅចំណាយខុសគោលដៅ ហើយមិនគួរពឹងផ្អែកទៅលើតែ ADB តែមួយនោះទេ វិស័យឯកជនក៏មានការរួមចំណែកច្រើនដែរ។

- លើកយន្តការ Credit guarantee scheme ជាយន្តការមួយមានសារៈសំខាន់ដែលផ្តល់នូវទំនុកចិត្តដល់ធនាគារឯកជនដែលអាចផ្តល់ឥណទានឲ្យបានកាន់តែច្រើន ស្នើសុំសហព័ន្ធស្រូវអង្ករមានតួនាទីត្រួតពិនិត្យឥណទានដែលបានផ្តល់ឲ្យរោងម៉ាស៊ីនដើម្បីធានាដល់ការប្រើប្រាស់ឥណទាននោះត្រឹមត្រូវ។

**+ផ្នែកទីផ្សារ**

-ការចុះម៉ាកពាណិជ្ជកម្មសម្គាល់ទីតាំងភូមិសាស្ត្រស្រូវ(GI)នៅក្នុងប្រទេសកម្ពុជាមិនមែនជារឿងងាយស្រួលនិងត្រូវប្រើពេលវេលាច្រើនក្នុងដំណើរការរឿងនេះ។

-ថ្វីត្បិតអង្ករសរីរាង្គមានបរិមាណកើនឡើងក៏ដោយ ប៉ុន្តែទីផ្សារនេះនៅមានកម្រិត គួរផ្តោតទៅលើ Certification mark, Selecting Branch ជាដើម និងគាំទ្រសេចក្តីព្រាងគោលនយោបាយដែលផ្តោតទៅលើទីផ្សារអង្ករក្រអូប។

ជាទីបញ្ចប់អង្គប្រជុំបានទទួលយករាល់ធាតុចូលដែលបានលើកឡើងយកទៅពិនិត្យពិចារណាខ្លឹមសារខ្វះចន្លោះនៅក្នុងសេចក្តីព្រាងគោលនយោបាយឡើងវិញ ដើម្បីកែសម្រួលខ្លឹមសារឲ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយមុននឹងដាក់ចូលក្នុងនីតិវិធីជាបន្តទៀត។

## ម៉ូដែលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ចកម្ពុជា

នៅព្រឹកថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦១ត្រូវនឹងថ្ងៃសុក្រ ទី២៧ ខែមេសា ឆ្នាំ២០១៨ លោក **យ៉ន សុវណ្ណ** អនុប្រធានគណៈកម្មាធិការកាត់បន្ថយថ្លៃដើម និងលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជាបានចូលរួម សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ស្តីពី "ម៉ូដែលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកំណើនសេដ្ឋកិច្ចកម្ពុជា" នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។





## កិច្ចប្រជុំស្តីពីភាគពុកិច្ចពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន

នៅព្រឹកថ្ងៃសុក្រ ១២កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ លោក **មូល សារិទ្ធិ** អគ្គលេខាធិការ និងជាតំណាងឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ព្រមទាំងសមាជិក បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីភាគពុកិច្ចពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ក្រោមអធិបតីភាព ឯកឧត្តម ប៊ូ ថារិន អគ្គលេខាធិការក្រុមប្រឹក្សាជាតិគណនេយ្យ(ក.ជ.គ) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កិច្ចប្រជុំពិភាក្សានេះមានគោលបំណង គោលដៅ និងវិសាលភាព គ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្មប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿជាក់ទុកចិត្តបាននៅព្រះរាជាណាចក្រកម្ពុជា។

**លទ្ធផលនៃកិច្ចប្រជុំ**

- ក្រុមប្រឹក្សាជាតិគណនេយ្យ នឹងរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលនាពេលខាងមុខ ស្តីពី គណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដើម្បីអញ្ជើញនិងពន្យល់ណែនាំលម្អិតបន្ថែមដល់គ្រប់ស្ថាប័ន និងសហគ្រាសសាធារណៈនិងឯកជនទាំងអស់បានយល់ និងចូលរួមអនុវត្តទាំងអស់គ្នា។
- ពាំនាំយកនូវសំណើរបស់សហព័ន្ធ សមាគមន៍ និងវិស័យឯកជន ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។



### សិក្ខាសាលាស្តីពី យន្តការនៃភាពជាដៃគូរវាងវិស័យឯកជន និងរដ្ឋដើម្បីគាំទ្រវិស័យស្រូវអង្ករកម្ពុជា



នាព្រឹកថ្ងៃព្រហស្បតិ៍ ១៣ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ លោក **យ៉ន សុវណ្ណ** អនុប្រធានគណៈកម្មការកាត់បន្ថយថ្លៃដើម នៃសហព័ន្ធស្រូវអង្ករកម្ពុជា រោងម៉ាស៊ីនដែលជាសមាជិក និងលេខាធិការដ្ឋានសហព័ន្ធ បានចូលរួមសិក្ខាសាលាស្តីពី យន្តការនៃភាពជាដៃគូរវាងវិស័យឯកជន និងរដ្ឋដើម្បីគាំទ្រវិស័យស្រូវអង្ករកម្ពុជា ដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយអង្គការ JICA ក្រោមអធិបតេយ្យភាពឯកឧត្តម ជូ វណ្ណៈ អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសណ្ឋាគារ កាំបូឌីយ៉ាណា ។

នាឱកាសនោះ លោក យ៉ន សុវណ្ណ តំណាងសហព័ន្ធស្រូវអង្ករកម្ពុជា បានធ្វើបទបង្ហាញស្តីពីបច្ចុប្បន្នភាពការងាររបស់សហព័ន្ធ និងបញ្ហាប្រឈមក្នុងវិស័យស្រូវអង្ករ ចំនួន ៤ ចំណុចគឺ ទុន ទឹក ទីផ្សារ និងឡូជីស្ទិក។ ជាមួយគ្នានេះ សហព័ន្ធក៏បានលើកសំណូមពរមួយចំនួនដើម្បីស្វែងរកការគាំទ្រពីរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ ក្នុងការជំរុញភាពប្រកួតប្រជែងនៃអង្ករកម្ពុជាលើទីផ្សារអន្តរជាតិ ។

## 3.4 កិច្ចសហការជាមួយអគ្គនាយកដ្ឋានពន្ធដារ

### ជំនួបប្រជុំរវាងអគ្គនាយកដ្ឋានពន្ធដារ និងសហព័ន្ធស្រូវអង្ករកម្ពុជា

នាព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង១០ព្រឹក នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាជំនួបប្រជុំជាលើកទី៣ រវាងអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលដឹកនាំដោយ ឯកឧត្តម វ៉ាន់ ពុទ្ធិពល អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងសហព័ន្ធស្រូវអង្ករកម្ពុជា និងសមាជិកសមាជិកាដើម្បីពិភាក្សា ស្តីពីការស្នើសុំលើកលែងអាករលើតំលៃបន្ថែម (VAT 10%) និងការអនុគ្រោះពន្ធនានាដើម្បីជួយដល់វិស័យស្រូវអង្ករកម្ពុជា ដូចប្រទេសជិតខាងយើងដែរ។ ជាលទ្ធផល៖ ភាគីទាំងពីរទទួលបានលទ្ធផលជាវិជ្ជមាន ដោយឯកឧត្តមអគ្គនាយករងបានមានប្រសាសន៍ថា ដើម្បីជាការលើកទឹកចិត្តដល់ប្រជាកសិករ អ្នកផលិត និងជាពិសេសសម្រាប់រោងម៉ាស៊ីន គួរតែលើកលែងជូន។ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលចងក្រងឯកសារ និងរៀបចំសំណើដាក់ជូនរាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យផ្លូវច្បាប់និងសម្រេចជាផ្លូវការ។

នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧ សហព័ន្ធស្រូវអង្ករកម្ពុជាបានទទួលលិខិតពីអគ្គនាយកដ្ឋានពន្ធដារ ដែលបានផ្តល់ជូននូវការលើកលែងពន្ធនានាជាផ្លូវការ ហើយសហព័ន្ធស្រូវអង្ករកម្ពុជាក៏បានផ្សព្វផ្សាយនិងសម្របសម្រួលដល់សមាជិកសមាជិកាធ្វើយ៉ាងណាឱ្យបំពេញតាមលក្ខខណ្ឌពន្ធដារទើបអាចទទួលបានការអនុគ្រោះនេះ។



## កិច្ចប្រជុំ ស្តីពីយន្តការភាពជាដៃគូអគ្គនាយកដ្ឋានពន្ធដារ-ផ្នែកឯកជន

នៅព្រឹកថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ វេលាម៉ោង ៩:០០ព្រឹក នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំ ស្តីពីយន្តការភាពជាដៃគូអគ្គនាយកដ្ឋានពន្ធដារ-ផ្នែកឯកជនលើកទី២ ក្រោមអធិបតីភាព ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និង អ្នកឧកញ៉ា **គិត ម៉េង** សហប្រធានយន្តការផ្នែកឯកជន នឹងមន្ត្រីជាន់ខ្ពស់អង្គភាពពន្ធដារជាច្រើន ព្រមទាំងលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា និងមានការចូលរួមពីបណ្តាក្រុមហ៊ុន និងសមាគមធុរកិច្ចមួយចំនួនចូលរួមផងដែរ។ ជាកិច្ចចាប់ផ្តើមនៃកិច្ចប្រជុំ ឯកឧត្តមប្រតិភូអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានមានមតិស្វាគមន៍ទៅដល់អ្នកចូលរួមទាំងអស់។

គោលបំណងនៃកិច្ចប្រជុំយន្តការ គឺចាចង់បង្កើនចំណងទំនាក់ទំនងជាលក្ខណៈដៃគូនៃយន្តការ ក្នុងកិច្ចសហការ និងយោគយល់គ្នា រវាងផ្នែកសាធារណៈនិងផ្នែកឯកជន ក្នុងកិច្ចសហប្រតិបត្តិការជាដៃគូយន្តការនេះ ។ ក្នុងកិច្ចប្រជុំនេះគឺសំដៅលើការពិភាក្សានិងសំណេះសំណាល និងដោះស្រាយបញ្ហាដែលនៅមានពីកិច្ចប្រជុំយន្តការរបស់ក្រុមការងារបច្ចេកទេសនីមួយៗដែលដឹកនាំដោយសភាពាណិជ្ជកម្ម និងបានដាក់ជូនអង្គភាពពន្ធដារដើម្បីស្រាយបំភ្លឺ និងពន្យល់ពីនីតិវិធីនៃបញ្ហានីមួយៗ របៀបវារៈសំខាន់មានដូចជា៖

១. ការធ្វើបទបង្ហាញពីវឌ្ឍនភាពការងារ និងកំណែទម្រង់រដ្ឋបាលសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

២. ចំណាប់អារម្មណ៍ និងកិច្ចសំណេះសំណាល

៣. ការពន្យល់ស្រាយបំភ្លឺចំពោះបញ្ហាដែលនៅសេសសល់របស់ផ្នែកឯកជនបានលើកឡើង

៤.សេចក្តីព្រាងប្រកាសថ្មី ស្តីពីការផ្លាស់ប្តូរសមាសភាពថ្មីនៃយន្តការភាពជាដៃគូអគ្គនាយកដ្ឋានពន្ធដារ-ផ្នែកឯកជន។

ស្របពេលជាមួយគ្នានោះដែរ ឯកឧត្តមប្រតិភូ បានបង្ហាញប្រាប់ពីការអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤ ២០១៨ និងត្រូវបញ្ចប់នាពេលឆាប់ៗខាងមុខនេះ និងជាគោលដៅសម្រាប់ការអនុវត្តបន្ត សេចក្តីនៃយុទ្ធសាស្ត្រ កៀរគរចំណូលរយៈពេលមធ្យម ២០១៩ ២០២៣ ត្រូវបានរៀបចំនិងរង់ចាំការឯកភាពពីរាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះ មានគោលបំណងសំខាន់ផ្តោតលើ ទី១.ធានាបាននូវចីរភាពកំណើនចំណូល ទី២. ចីរភាពកំណើនសេដ្ឋកិច្ច ទី៣. ការប្រកួតប្រជែងដោយស្មើភាព និងទី៤.យុត្តិធម៌សង្គម ។

នៅក្នុងកិច្ចប្រជុំនេះ បានពិភាក្សាសម្រេចបានលទ្ធផលមួយចំនួនលើចំណុចសំខាន់ទាំង១១ដែលសភាពាណិជ្ជកម្មបានដាក់ស្នើសុំការអន្តរាគមន៍ពីអគ្គនាយកដ្ឋានពន្ធដាររួមមាន៖

១.ការលក់ និងការកត់ត្រាលក់ប្រចាំខែ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ការប្រកាសពន្ធប្រចាំខែ)

២. ពន្ធលើស្លាកយីហោ និងប៉ាណូ

៣.កម្ចីបុគ្គលិកទាបជាងអត្រាទីផ្សារ

៤.ការវាយតម្លៃលើពន្ធដារលើការប្រាក់ព្យួរបង្គរ សម្រាប់វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ

៥.អាករលើតម្លៃបន្ថែមលើ ការលក់ទ្រព្យសកម្មដែលអស់តម្លៃប្រើ

៦.ពន្ធអាករលើតម្លៃបន្ថែម លើការខ្ចីប្រាក់ក្រៅពីស្ថាប័នហិរញ្ញវត្ថុ ឬធនាគារ

៧.ពន្ធកាត់ទុកលើកំរៃជើងសារភ្នាក់ងារ

៨.ការវាយតម្លៃពន្ធ

៩.វិក័យប័ត្រដែលអាចទទួលយកបាន ស្រមាប់វិស័យធនាគារ

១០.ពន្ធលើសេវាកម្មហិរញ្ញវត្ថុ ហើយបញ្ហាទាំងនេះបានដោះស្រាយចំនួន៨រួចមកហើយ

បន្ថែមពីលើបញ្ហាប្រឈមនានា ដែលត្រូវបានដោះស្រាយនៅកម្រិត នៃយន្តការនៃភាពជាដៃគូ ដោយឡែកបញ្ហាដែលនៅសេសសល់និងបន្តដោះស្រាយ ក្នុងស្មារតីសហការគ្នាទៅវិញទៅមក។



## 3.5 អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា៖

### កិច្ចសហការលើការបង្រ្កាបការលួចនាំចូលអង្ករខុសច្បាប់៖

ធ្វើការទប់ស្កាត់ការនាំចូលអង្ករដែលមិនបានបង់ពន្ធត្រឹមត្រូវដែលបានធ្វើឲ្យប៉ះពាល់ដល់អាជីវករនិងរោងម៉ាស៊ីនក្នុងស្រុក តម្លៃអង្ករមិនអាចប្រកួតប្រជែងបាន និងកែសម្រួលតម្លៃអត្រាគិតពន្ធនាំចូល។

### កិច្ចសហការក្នុងការរៀបចំលេខកូដអង្ករនាំចេញ និងស្នើសុំចុះក្នុងបញ្ជីលេខកូដនៃអាស៊ាន

- នៅរសៀលថ្ងៃសុក្រ ៨កើត ខែអាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៨ នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លោក **នង វាសនា** អនុប្រធានសហព័ន្ធ និងជាតំណាងឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានដឹកនាំតំណាងក្រុមហ៊ុននាំចេញ និងលេខាធិការដ្ឋានសហព័ន្ធ បានជួបប្រជុំពិភាក្សាជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងក្រសួងពាណិជ្ជកម្ម តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភាគីពាក់ព័ន្ធ ដើម្បីពិនិត្យលទ្ធភាពលើការញែកប្រភេទអង្ករ និងការដាក់លេខកូដអង្ករ(HS Code)អោយកាន់តែច្បាស់ សម្រាប់ការនាំចេញទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប និងទីផ្សារប្រទេសដទៃទៀត។



- ពាក់ព័ន្ធការងារខាងលើ នៅរសៀលថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ លោក **មូល សារិទ្ធិ** អគ្គលេខាធិការ និងជាតំណាងសហព័ន្ធស្រូវអង្ករកម្ពុជា និងសមាជិកអ្នកនាំចេញ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការត្រៀមរៀបចំបន្ទាត់ពន្ធអង្ករក្រអូប នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដោយមានការចូលរួមពីតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតំណាងក្រសួងពាណិជ្ជកម្ម។

ជាលទ្ធផល បន្ទាប់ពីបានពិភាក្សាគ្នាយ៉ាងផុសផុលរួចមកអង្គប្រជុំបានឯកភាពនឹងស្នើសុំញែកដាច់ពីគ្នាចំពោះលេខកូដអង្ករស អង្ករក្រអូប និងអង្ករម្លិះអង្គរ(**Malys Angkor**)។ ដោយខាងអគ្គនាយកដ្ឋានគយត្រូវការឯកសារបន្ថែមជាច្រើនដើម្បីជាជំនួយឯកសារសម្រាប់ដាក់ស្នើសុំកែសម្រួលលេខកូដបន្ទាត់ពន្ធអង្ករនៅក្នុងកិច្ចប្រជុំអាស៊ាននាពេលខាងមុខ អង្គប្រជុំបានឯកភាពនឹងជួយផ្តល់ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធមកខាងគយ និងបន្តសហការគ្នាលើការងារនេះរហូតដល់ពេលប្រជុំអាស៊ាននាពេលខាងមុខ។

### ចូលរួមខួប១០ឆ្នាំ នៃការដាក់ឲ្យអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា)

នៅព្រឹកថ្ងៃចន្ទ ៧កើត ខែជេស្ឋ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ លេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមខួប១០ឆ្នាំនៃការដាក់ឲ្យអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ(អាស៊ីគូដា) ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **គុណ ញឹម** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជាដែលប្រព្រឹត្តទៅនៅសណ្ឋាគារ Raffles Hotel Le Royal ។



ឯកឧត្តមបណ្ឌិតបានរាយការណ៍សង្ខេបពីវឌ្ឍនភាពសំខាន់នៃការអនុវត្តគំរោងប្រព័ន្ធអាស៊ីកូដារយៈពេល១០ឆ្នាំចាប់ពីឆ្នាំ២០០៨-២០១៨។ គំរោងអាស៊ីកូដាបានចាប់ផ្តើមតាំងពីខែមេសា ឆ្នាំ២០០៦មកម្លេះ ក្រោមកិច្ចសម្រួលពាណិជ្ជកម្មនិងប្រកួតប្រជែង ដែលបានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុពីសហគមន៍អឺរ៉ុប និងសម្របសម្រួលដោយធនាគារពិភពលោក គំរោងនេះគឺជាគំរោងកំណែទម្រង់ និងទំនើបកម្មដ៏ធំមួយនៅក្នុងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

## 3.6 ក្រសួងសាធារណការ និងដឹកជញ្ជូន

### សិក្ខាសាលា ស្តីពី គោលនយោបាយភស្តុភារកម្ម

នៅថ្ងៃព្រហស្បតិ៍ ២កើត ខែផល្គុន ឆ្នាំច សំរិទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ លោក **យ៉ន សុវណ្ណ** អនុប្រធានគណៈកម្មាធិការកាត់បន្ថយថ្លៃដើមរបស់សហព័ន្ធស្រូវអង្ករកម្ពុជា លេខាធិការដ្ឋានសហព័ន្ធ និងសមាជិកសមាជិកា បានអញ្ជើញចូលរួមសិក្ខាសាលា ស្តីពី គោលនយោបាយភស្តុភារកម្ម នៅក្រសួងសាធារណការ និងដឹកជញ្ជូន ក្រោមអធិបតីភាពឯកឧត្តម **សូរ វិចទ័រ** រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន។

### សិក្ខាសាលាស្តីពី ការអភិវឌ្ឍផែនការមេភស្តុភារកម្មនៅកម្ពុជា

ថ្ងៃទី៥ ខែកុម្ភៈឆ្នាំ ២០១៨ នៅសណ្ឋាគារ RaffleHotel LeRoyal លោក **យ៉ន សុវណ្ណ** អនុប្រធានគណៈកម្មាធិការកាត់បន្ថយថ្លៃដើមរបស់សហព័ន្ធស្រូវអង្ករកម្ពុជា និងមន្ត្រីសម្របសម្រួលរបស់សហព័ន្ធ បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ ស្តីពី ការអភិវឌ្ឍផែនការមេភស្តុភារកម្មនៅកម្ពុជា(Logistics Master Plan Development in Cambodia) ក្រោមអធិបតីភាពឯកឧត្តម**ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន។



គោលបំណងនៃសិក្ខាសាលាគឺ១)បង្ហាញជូននូវពង្រាងរបាយការណ៍ចុងក្រោយ ស្តីពី ការរៀបចំផែនការមេភស្តុភារកម្ម ២)ពិនិត្យពីសុក្រឹតភាពរបស់ធាតុចូលនានាដែលបានមកពីភាគីពាក់ព័ន្ធ។

### មហាសន្និបាតបូកសរុបការងារឆ្នាំ២០១៦ និងលើកទិសដៅឆ្នាំ២០១៧ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន



នៅថ្ងៃទី២៨-២៩ ខែធ្នូ ឆ្នាំ២០១៦ តំណាងសហព័ន្ធស្រូវអង្ករកម្ពុជា លោក បណ្ឌិត **ហ៊ីន ឆាវ៉ា** អគ្គលេខាធិការរង នៃ សហព័ន្ធបានចូលរួមមហាសន្និបាតបូកសរុបការងារឆ្នាំ២០១៦ នឹងលើកទិសដៅឆ្នាំ២០១៧ របស់ក្រសួងសាធារណការនិងដឹកជញ្ជូនក្រោមអធិបតីភាពឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

សហព័ន្ធស្រូវអង្ករកម្ពុជាបានលើកឡើងសំណូមពរមួយចំនួនរបស់សមាជិក អំពីបញ្ហាប្រឈមនៃការប្រកួតប្រជែងក្នុងចង្វាក់ផលិតកម្មស្រូវអង្ករ ដែលក្នុងនោះថ្លៃដឹកជញ្ជូនក៏ជាកត្តាចំបងមួយ ដែលត្រូវដោះស្រាយ ដើម្បីតម្លៃអង្ករកម្ពុជាមានភាពកាន់តែប្រសើរឡើងក្នុងការប្រកួតប្រជែងជាមួយអង្ករដទៃទៀត នៅលើទីផ្សារអន្តរជាតិ។

ជាការឆ្លើយតប ឯកឧត្តមទេសរដ្ឋមន្ត្រី បានទទួលស្គាល់ពីភាពលំបាកក្នុងពេលកន្លងមករបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដោយសារកត្តាតម្លៃខ្ពស់ក្នុងចង្វាក់ផលិតកម្ម ក្នុងនោះក៏មានមធ្យោបាយដឹកជញ្ជូនផងដែរ ដោយឯកឧត្តមទេសរដ្ឋមន្ត្រី បានគូសបញ្ជាក់ថាអង្ករកម្ពុជាមានសក្តានុពលនាំចេញទៅកាន់ទីផ្សារអឺរ៉ុប ដោយសារអង្ករកម្ពុជាទទួលបានការអនុគ្រោះលើកលែងពន្ធតាមរយៈគម្រោងEBA ដែលធ្វើឲ្យអង្ករកម្ពុជាចំណេញរហូតដល់១៧០ដុល្លារក្នុងមួយតោន។ ជាមួយការស្នើឲ្យស្ថាប័នជាច្រើនយល់ពីការលំបាករបស់សហព័ន្ធស្រូវអង្ករកម្ពុជា ឯកឧត្តម ទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងនាមថ្នាក់ដឹកនាំក្រសួងសាធារណការនិងដឹកជញ្ជូន បានសន្យាថានឹងខិតខំកសាងស្ថាបនាមធ្យោបាយដឹកជញ្ជូនថែមទៀត ដើម្បីរួមចំណែកដល់ការកាត់បន្ថយថ្លៃដើមក្នុងវិស័យស្រូវអង្ករនេះ។

## 3.7 កិច្ចសហការជាមួយក្រសួងបរិស្ថាន

### ថ្នាក់ដឹកនាំក្រសួងផ្តួចផ្តើមឲ្យមានកិច្ចសហប្រតិបត្តិការទូលំទូលាយជាមួយវិស័យស្រូវអង្ករ

នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា រួមជាមួយថ្នាក់ដឹកនាំសហព័ន្ធបានចូលជួបសម្តែងការគួរសមជាលើកដំបូងជាមួយឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមមាន៖ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន គោលការណ៍ណែនាំ និងស្តង់ដារបច្ចេកទេសបរិស្ថានជាដើម។

នៅក្នុងជំនួបលើកដំបូងនេះ ឯកឧត្តមប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រី អំពីវត្ថុបំណងសំខាន់ៗ ដែលសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជាបានស្នើមកកាន់សហព័ន្ធ ដើម្បីជួយដោះស្រាយដូចជា៖

១-ការគាំទ្រក្នុងការកែច្នៃអង្កាមមកជាអគ្គិសនី

២-ការគាំទ្រក្នុងការបង្កើតក្រុមការងារវាយតម្លៃមួយដែលមានលក្ខណៈសមស្របនឹងវិស័យស្រូវអង្ករ ស្រដៀងគ្នានឹងអ្វីដែលក្រសួងធ្វើជាមួយ GMAC

៣-ការធ្វើ Eco Label សម្រាប់បង្កើនតម្លៃដល់ផលិតផលដែលមានស្តង់ដារស្របតាមគោលការណ៍បរិស្ថាន។

នៅក្នុងឱកាសនោះដែរ ឯកឧត្តមរដ្ឋមន្ត្រី ក៏បានផ្តួចផ្តើមឲ្យមានកិច្ចសហប្រតិបត្តិការឲ្យកាន់តែទូលំទូលាយរវាងក្រសួងបរិស្ថាន និង សហព័ន្ធស្រូវអង្ករកម្ពុជា ដោយស្នើឲ្យមានការចុះអនុស្សរណៈយោគយល់គ្នា ដើម្បីបើកផ្លូវសម្រាប់បង្កើតក្រុមការងារធ្វើការងារជាមួយគ្នាទៅក្នុងថ្ងៃអនាគត។

លើសពីនេះទៀត ឯកឧត្តម រដ្ឋមន្ត្រី ក៏បានគាំទ្រវាល់សកម្មភាពកែច្នៃអង្ករ ជាពិសេស ការប្រើប្រាស់អង្កាមសម្រាប់បង្កើតថាមពល ដើម្បីបម្រើឲ្យសកម្មភាពក្នុងរោងម៉ាស៊ីនផងនិងសល់ត្រូវលក់ឲ្យអគ្គិសនីកម្ពុជាវិញ។ ឯកឧត្តម សន្យាជួយចរចារជាមួយស្ថាប័នពាក់ព័ន្ធក្នុងការធ្វើការងារទាក់ទិននឹងបម្រែបម្រួលអាកាសធាតុ។

ក្រសួងបរិស្ថាននឹងគាំទ្រដល់ដំណើរការរោងម៉ាស៊ីនកិនស្រូវដែលគិតគូរដល់បរិស្ថាន ហើយ ក្រសួង នឹងគាំទ្រដាក់ស្លាកសញ្ញាណាមួយដែលបញ្ជាក់ថា ផលិតផលដែលចេញពីសមាជិករបស់សហព័ន្ធស្រូវអង្ករ ។



**ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់រវាងក្រសួងបរិស្ថាន និងសហព័ន្ធស្រូវអង្ករកម្ពុជា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅទីស្តីការក្រសួងបរិស្ថាន**






ថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៦ នៅទីស្តីការក្រសួងបរិស្ថានបានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់រវាងក្រសួងបរិស្ថាន និងសហព័ន្ធស្រូវអង្ករកម្ពុជា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រោមអធិបតីភាព ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា។ នៅក្នុងនោះដែរឯកឧត្តមរដ្ឋមន្ត្រីបានថ្លែងកោតសរសើរដល់ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជាដែលបានស្ម័គ្រចិត្តចូលរួមសកម្មភាពការពារបរិស្ថាន។ ឯកឧត្តមរដ្ឋមន្ត្រី បានពន្យល់បន្ថែមទៀតថា នៅក្នុងអាណត្តិនេះ ក្រសួងបរិស្ថានមានភាពមមាញឹកខ្លាំងក្នុងការចុះវាយតម្លៃពីហេតុប៉ះពាល់បរិស្ថាន ហើយ ក៏ថ្លែងអំណរគុណដល់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលបានចូលរួមដោយស្ម័គ្រចិត្តសហការជាមួយក្រសួងបរិស្ថានសម្រាប់ជំរុញការងារនេះ។ តាមរយៈការគិតគូបរិស្ថានជាចំបងនេះ ឯកឧត្តមរដ្ឋមន្ត្រី រំពឹងថាផលិតផលអង្ករកម្ពុជានឹងទទួលបានការសាទរ ការជឿទុកចិត្តពីសំណាក់អ្នកប្រើប្រាស់ និងជួយលើកកម្ពស់ផលិតផលអង្ករទាំងក្នុងកម្រិតជាតិនិងអន្តរជាតិ។

ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានថ្លែងថាអនុស្សរណៈថ្មីនេះយើងជឿជាក់ថាវានឹងជួយសម្រួលដល់រោងម៉ាស៊ីនបានមួយកម្រិតទៀត ទាក់ទងថ្លៃដើមរបស់យើងតាមរយៈការកាត់បន្ថយពេលវេលា ការកាត់បន្ថយចំណាយថវិកា ការទទួលប្រឹក្សាបច្ចេកទេសចំពោះការរៀបចំនិងគ្រប់គ្រងបរិស្ថានជាដើម។

បន្ថែមទៀតវាក៏អាចជំរុញផងដែរដល់ការចូលរួមការពារបរិស្ថានប្រកបដោយនិរន្តរភាពតាមរយៈការរៀបចំកិច្ចសន្យា ការពារបរិស្ថាន ភ្ជាប់ជាមួយផែនការគ្រប់គ្រងបរិស្ថានឲ្យបានច្បាស់លាស់សម្រាប់គម្រោងនានាក្នុងការកែច្នៃអង្ករនៅកម្ពុជា។

## 3.8 កិច្ចសហការជាមួយសភាពាណិជ្ជកម្មកម្ពុជា

**សហព័ន្ធស្រូវអង្ករកម្ពុជា និងសមាជិកក្រុមហ៊ុននាំចេញតែងតែចូលរួមកម្មវិធីចាប់ដៃគូពាណិជ្ជកម្ម មកពីបណ្តាប្រទេសនានា ដូចជា ចិន កូរ៉េ ឥណ្ឌា ថៃ ជាដើម**

**សហព័ន្ធស្រូវអង្ករកម្ពុជានិងក្រុមការងារវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ផ្នែកស្រូវអង្ករ(ក្រុមការងារទី៩)** បានចូលរួមវេទិកានិងកិច្ចប្រជុំត្រៀមនិងរៀបចំឯកសារសម្រាប់កម្មវិធីវេទិការដ្ឋាភិបាល-វិស័យឯកជនលើកទី១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ នៅវិមានសន្តិភាព ដែលបានសម្របសម្រួលដោយសភាពាណិជ្ជកម្មកម្ពុជា។

**កិច្ចប្រជុំផ្ទៃក្នុង នៃសហប្រធានក្រុមការងារផ្នែកឯកជនទាំង១០**

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ អគ្គនាយកដ្ឋានសភាពាណិជ្ជកម្មកម្ពុជា មានការរៀបចំប្រជុំផ្ទៃក្នុង នៃសហប្រធានក្រុមការងារផ្នែកឯកជន ក្រោមអធិបតីភាព អ្នកឧកញ៉ា **គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា ដែលក្នុងនោះក៏មានការចូលរួមពីសហព័ន្ធស្រូវអង្ករកម្ពុជានិងក្រុមការងារទី៩ លោក **មូល សារិទ្ធី** អគ្គលេខាធិការ និងជាតំណាងឱ្យឯកឧត្តមសហប្រធាន។




កិច្ចប្រជុំនោះមានគោលបំណងដើម្បីស្តាប់នូវរបាយការណ៍វឌ្ឍនភាពការងារ និងដោះស្រាយនូវបញ្ហាប្រឈមនានាដែលក្រុមការងារនីមួយៗបាននិងកំពុងជួបប្រទះទាក់ទងទៅនឹងការអនុវត្តការងារជាក់ស្តែងរបស់វិស័យឯកជន។

**កិច្ចប្រជុំ ក្រុមការងារបច្ចេកទេសទី២ គយ-ឧស្សាហកម្មបម្រើការនាំចេញមិនមែនវិស័យកាត់ដេរ**

កាលពីរសៀលថ្ងៃទី១៧ សីហា ២០១៧ វេលាម៉ោង១៤:៣០នាទី នៅអគ្គនាយកដ្ឋានសភាពាណិជ្ជកម្មកម្ពុជា លោក **យ៉ន សុវណ្ណ** អនុប្រធានគណៈកម្មាធិការទទួលបន្ទុកកែសម្រួលថ្លៃដើម និងជាតំណាងឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសទី២ "គយ-ឧស្សាហកម្មបម្រើការនាំចេញមិនមែនវិស័យកាត់ដេរ" ក្រោមអធិបតីភាព បណ្ឌិត **តាន់ មុនីវណ្ណ** សហប្រធានផ្នែកឯកជន ក្រុមការងារបច្ចេកទេសទី២ ដោយមានការអញ្ជើញចូលរួមពីតំណាងក្រុមហ៊ុនដែលជាសមាជិកនៃក្រុមការងារនេះជាច្រើនរូបផងដែរ។

គោលបំណងនៃកិច្ចប្រជុំនេះ គឺប្រមូលផ្តុំយោបល់ពាក់ព័ន្ធទៅនឹងឧស្សាហកម្មបម្រើការនាំចេញមិនមែនវិស័យកាត់ដេរ និងស្នើសុំការដោះស្រាយជាមួយសហប្រធាន នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ក្នុងកិច្ចប្រជុំនេះតំណាងក្រុមហ៊ុននានាបានលើកឡើងពីបញ្ហាដែលក្រុមហ៊ុនរបស់ខ្លួនកំពុងជួបប្រទះការលំបាកផ្សេងៗនិងសំណូមពរទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាតាមរយៈយន្តការក្រុមការងារបច្ចេកទេសទី២ ដើម្បីសម្រួលនិងដោះស្រាយបញ្ហា។

## 3.9 កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា

### ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការជប៉ុន (JiCA)

ចាប់តាំងពីចុងឆ្នាំ ២០១៨ មក ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការ ជប៉ុន បានរៀបចំ វេទិកាគ្រាប់ស្រូវពូជគម្រោងជំរុញផលិតកម្មប្រើប្រាស់គ្រាប់ពូជស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម សហការជាមួយសហព័ន្ធស្រូវអង្ករ កម្ពុជា បាន៣លើកកន្លងមក នៅខេត្តនៃគម្រោងចំនួន៤ខេត្ត មានខេត្តព្រៃវែង ខេត្តបាត់ដំបង និងខេត្តតាកែវ ហើយគ្រោងបន្តនៅខេត្តកំពង់ឆ្នាំង ផងដែរ ។

សមាសភាព ចូលរួមនៅក្នុងវេទិកាគ្រាប់ពូជស្រូវ មានតំណាងគម្រោងតំណាងមន្ទីរ ស្ថាប័ន ពាក់ព័ន្ធ តំណាងមន្ទីរកសិកម្មខេត្ត តំណាងសហព័ន្ធស្រូវអង្ករ តំណាងធនាគារ អភិវឌ្ឍន៍ ជនបទ តំណាងក្រុមហ៊ុនផលិតគ្រាប់ស្រូវពូជ តំណាងសហគមន៍ និងក្រុមផលិតគ្រាប់ស្រូវ តំណាងរោងម៉ាស៊ីនកិនស្រូវ ។ល។

**គោលបំណងនៃ វេទិកាគ្រាប់ស្រូវពូជរបស់ JICA៖**

- ផ្តល់ឱកាសអោយអ្នកផលិតគ្រាប់ស្រូវពូជ ក្នុងស្រុក ដើម្បីបង្ហាញអំពីសមត្ថភាពរបស់ពួកគាត់ នៅក្នុងផលិតកម្មគ្រាប់ពូជ ទៅកាន់អ្នកទិញ ដែលមានសក្តានុពល ។
- ផ្តល់ឱកាសជូនអ្នកទិញ ដែលមានសក្តានុពល ដើម្បីស្គាល់អ្នកផលិតគ្រាប់ស្រូវពូជដែលមានស្រាប់នៅក្នុងខេត្ត ។
- ផ្តល់ឱកាស ជូនអ្នកទិញ ដែលមានសក្តានុពល និង រោងម៉ាស៊ីនកិនស្រូវ ដើម្បីបង្ហាញអំពីតម្រូវការ របស់ពួកគាត់ ប្រភេទពូជ បរិមាណ ពេលវេលាបញ្ជូនទិញ និងកន្លែងស្តុកទំនិញ ស្តង់ដារគុណភាពជាដើម ទៅការអ្នកផលិតគ្រាប់ពូជស្រូវ ។
- ផ្តល់ឱកាស ជូន CARDI និងអ្នកផ្គត់ផ្គង់គ្រាប់ពូជ ចុះបញ្ជីផ្សេងៗដើម្បីស្វែងរកតម្រូវការគ្រាប់ពូជចុះបញ្ជីនៃពូជផ្សេងៗទៀត ។
- ផ្តល់ជូនអ្នកចូលរួមនូវព័ត៌មានថ្មី ស្តីពីស្ថានភាពអាជីវកម្មគ្រាប់ពូជស្រូវ នៅក្នុងប្រទេសកម្ពុជា ។ល។



**វេទិកាគ្រាប់ស្រូវពូជ កាលពីដើមឆ្នាំ២០១៩ នៅខេត្តតាកែវ និង ខេត្តបាត់ដំបង**

### ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់(GIZ)

សហពន្ធ័ស្រូវអង្ករកម្ពុជានាឆ្នាំកន្លងមកបានទំនាក់ទំនង សហការជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ នៅក្នុងតំបន់របស់ខ្លួនក្នុងខេត្តមួយចំនួននៃគម្រោងរបស់GIZ មានខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តព្រះវិហារ ហើយក៏បានសហការគ្នាជាមួយនឹងមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងមន្ទីរពាក់ព័ន្ធ បានរៀបចំ កម្មវិធីប្រជុំ និងសិក្ខាសាលាវគ្គបណ្តុះបណ្តាលដោយលើកយកប្រធានបទសំខាន់ៗមួយចំនួន ដូចជា កិច្ចសន្យាកសិកម្ម ស្តង់ដារគុណភាពស្រូវ តាមលក្ខខណ្ឌបច្ចេកទេស ការដាំដុះស្រូវ ផ្សាភ្ជាប់ ជាមួយទីផ្សារការសម្របសម្រួល រវាងអ្នកដាំដុះ(សហគមន៍កសិកម្ម) និងអ្នកទិញ (រោងម៉ាស៊ីនកិនស្រូវ) រៀបចំបង្កើតបណ្តាញ និងក្រុមផលិតគ្រាប់ស្រូវពូជ ។ល។



**ក្រុមការងារសម្របសម្រួលដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋាន ខេត្តឧត្តរមានជ័យ កាលពីខែមីនា ឆ្នាំ២០១៨**

ក្រៅពីនេះក៏បានសហការរៀបចំការប្រជុំ ក្រុមការងារដោះស្រាយ បញ្ហាស្រូវអង្ករ នៅមូលដ្ឋាន ខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ និងខេត្តផ្សេងៗក៏បានរៀបចំប្រជុំ

ជាបន្តបន្ទាប់ផងដែរ។ គោលបំណងនៃការសហការគ្នានៃដំណើរការប្រជុំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលគឺ ៖

- ពង្រឹងសមត្ថភាព នៃដំណើរការសហគមន៍ កសិកម្ម និងរោងម៉ាស៊ីនកិនស្រូវ និងភាគីពាក់ព័ន្ធ
- ជំរុញការអនុវត្ត កិច្ចសន្យាកសិកម្ម (Contract Farming) រវាងសហគមន៍ និងរោងម៉ាស៊ីនកិនស្រូវ
- ជំរុញការដាំដុះស្រូវតាមស្តង់ដារបច្ចេកទេសអោយស្របតាមតម្រូវការទីផ្សារ
- ផ្សព្វផ្សាយជី និងថ្នាំគីមី ហាមឃាត់ និងផលប៉ះពាល់
- សម្របសម្រួល និងជំរុញដំណើរការប្រជុំក្រុមការងារដោះស្រាយបញ្ហា ស្រូវអង្ករ នៅមូលដ្ឋានខេត្ត
- ចែករំលែកចំណេះដឹង និងបទពិសោធន៍ ជូនដល់ភាគីពាក់ព័ន្ធ នៃវិស័យ ស្រូវអង្ករ ដើម្បីឈានទៅការអភិវឌ្ឍរីកចម្រើនរួមគ្នា ។ល។

## **វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ** ( IRRI )

សហព័ន្ធ ស្រូវអង្ករ កម្ពុជា នាឆ្នាំកន្លងមកបានសហការលើការងារមួយចំនួន ជាមួយដៃគូ អភិវឌ្ឍ IRRI លើសកម្មភាពមួយចំនួនដូចជា៖

- សហការផ្សព្វផ្សាយស្រូវពូជថ្មីៗមួយចំនួន មិនប្រកាន់រដូវ ធន់នឹងអាកាសធាតុ ព្រមទាំងទិន្នផលខ្ពស់ ក្នុងនោះ មានប្រភេទស្រូវ CAR.15, CAR.16ជូនដល់ភាគីពាក់ព័ន្ធ មានកសិករ សហគមន៍ កសិកម្ម រោងម៉ាស៊ីនកិនស្រូវ តាមរយៈចុះទៅពិនិត្យមើលផ្ទាល់ស្រែ បង្ហាញ ដើម្បីធ្វើការពង្រីក ការដាំដុះអោយបានច្រើន
- សម្របសម្រួល និងជម្រុញ ការអនុវត្តកិច្ចសន្យាកសិកម្ម (Contract Farming)រវាងអ្នកផលិត និងអ្នកដាំដុះគឺ សហគមន៍កសិកម្មនិងរោងម៉ាស៊ីនកិនស្រូវ បានរៀបចំអោយមានការចុះកិច្ចសន្យាកសិកម្មរវាងសហគមន៍កសិកម្ម ចំនួន១២ ជាមួយនឹងរោងម៉ាស៊ីននៅខេត្តកំពង់ធំ ហើយកំពុងបន្តសម្របសម្រួលនៅខេត្តសៀមរាបផងដែរ
- IRRIបានសហការជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា និងមន្ទីរកសិកម្មខេត្តសៀមរាបបានចុះជ្រើសរើសសហគមន៍ កសិកម្ម និងក្រុមផលិតគ្រាប់ស្រូវពូជនៅក្នុងស្រុកជីក្រែង ខេត្តសៀមរាប ហើយនឹងគ្រោងបន្តធ្វើនៅខេត្តមួយចំនួនទៀតនៃគម្រោង ។

## **គម្រោងខ្សែសង្វាក់ផលិតកម្មស្រូវអង្ករកម្ពុជា**( CAVAC )៖

- បានចូលរួមសហការជាមួយសហព័ន្ធស្រូវអង្ករកម្ពុជានិងកាឌី(CARDI)ធ្វើបន្សុទ្ធពូជស្រូវសែនក្រអូប
- ចូលរួមការផ្សព្វផ្សាយម៉ាកវិញ្ញាតកម្មម្លិះអង្គរ(Malys Angkor)
- ចូលរួមសហការជួលមេធាវីនិងរៀបចំឯកសារការពារករណីសហភាពអឺរ៉ុបគ្រោងដាក់ពន្ធលើអង្ករកម្ពុជា។





**សិក្ខាសាលាស្តីពីគំរោងបន្សុទ្ធពូជស្រូវសែនក្រអូប នៅវិទ្យាស្ថាន** CARDI

**គម្រោងសាជីវកម្មអន្តរជាតិ** (IFC)៖ បានសហការជាមួយសហព័ន្ធស្រូវអង្ករកម្ពុជាក្នុងការរៀបចំពិធីបុណ្យអង្ករកម្ពុជានៅឆ្នាំ២០១៤ សហការចូលរួមបង្កើតម៉ាកវិញ្ញាតកម្មម្លិះអង្ករ ចូលរួមសហការដឹកនាំសមាជិកក្រុមហ៊ុននាំចេញមួយចំនួនទៅចូលរួមតាំងពិពរណ៍ពាណិជ្ជកម្ម និងចាប់ដៃគូពាណិជ្ជកម្មក្រៅប្រទេស និងការពង្រឹងស្តង់ដារដល់រោងម៉ាស៊ីនមួយចំនួនឱ្យមានស្តង់ដារនិងបទដ្ឋានបច្ចេកទេសនាំចេញ។






**គម្រោងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង**(AFD)៖ ចូលរួមសហការក្នុងការរៀបចំការបង្កើតម៉ាកវិញ្ញាតកម្មម្លិះអង្ករ និងចូលរួមសម្របសម្រួលដល់ការបោះឆ្នោតជ្រើសរើសតំណាងសហគមន៍កសិករ៣រូបចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករអាណត្តិទី២ នៅឆ្នាំ២០១៦។





**អង្គការអាដា**(ADA) **និងអង្គការរីដា**(RIDA):

អង្គការអាដានិងរីដា បានគាំទ្រដល់ដំណើរការសហគមន៍កសិកម្មចំនួន១២នៅក្នុងខេត្តសៀមរាប បានសហការជាមួយបុគ្គលិកប្រចាំតំបន់នៃលេខាធិការសហព័ន្ធស្រូវអង្ករកម្ពុជា និងភាគីពាក់ព័ន្ធនៅក្នុងខេត្តរៀបចំកម្មវិធីប្រជុំសិក្ខាសាលាវគ្គបណ្តុះបណ្តាលមហាសន្និបាទនិងកម្មវិធីផ្សេងៗ។ អង្គការទាំងពីរក៏បានចងក្រងសហគមន៍កសិកម្មទាំង១២ជាសហភាពសហគមន៍កសិកម្មមានជ័យ។

គោលបំណង គឺពង្រឹងសមត្ថភាពនិងតម្លាភាពនៃដំណើរការសហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្ម ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់កសិករនៅមូលដ្ឋានអោយកាន់តែប្រសើរឡើង។



# 4. ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពដែលនៅសេសសល់ត្រូវបន្តអនុវត្ត

## សហព័ន្ធស្រូវអង្ករកម្ពុជា

### តារាងសង្ខេបលទ្ធផល និងសកម្មភាពនៃផែនការរយៈពេល៥ឆ្នាំ ត្រូវបន្តអនុវត្ត

| លរ | ផែនការ | សម្រេចបាន (២០១៤-២០១៩) | បន្ត |
|---|---|---|---|
| I | **គោលដៅ ១ នៃសកម្មភាព** | | |
| ១ | **គោលបំណងយុទ្ធសាស្ត្រ ១ (ការពង្រឹងស្ថាប័ន)** | | |
| | រៀបចំប្រជុំជាប្រចាំជាមួយក្រុមប្រឹក្សាភិបាល និងសមាជិកសហព័ន្ធ | ២១លើក | ✓ |
| | រៀបចំកម្មវិធីទស្សនៈកិច្ចជាមួយសមាជិកដើម្បីស្វែងយល់ពីបញ្ហា | ៥លើក | ✓ |
| | រៀបចំវគ្គបណ្តុះបណ្តាលផ្តោតលើការសិក្សាស្រាវជ្រាវពីមូលហេតុនៃបញ្ហា | ៥លើក | ✓ |
| | រៀបចំកម្មវិធីពិគ្រោះយោបល់ | ១០លើក | ✓ |
| | វាយតម្លៃការគោរពតាម លក្ខន្តិកៈ និងបទបញ្ញត្តិផ្ទៃក្នុង | ២លើក | ✓ |
| | ពិនិត្យ និងណែនាំបទបញ្ញត្តិថ្មី និងគោលការណ៍ដែលមានប្រសិទ្ធភាពខ្ពស់ | ២លើក | ✓ |
| | រៀបចំរបាយការណ៍ស្តីពីសកម្មភាពរបស់ក្រុមប្រឹក្សាភិបាលជាប្រចាំ | ២១លើក | ✓ |
| ២ | **គោលបំណងយុទ្ធសាស្ត្រ ២ (កសាងសមត្ថភាពនៃលេខាធិការដ្ឋាន និងការស្វែងរកថវិកាសម្រាប់ដំណើរការ)** | | |
| | រៀបចំវគ្គបណ្តុះបណ្តាលជាប្រចាំដោយទៀងទាត់ | ៥លើក | |
| | គាំទ្រជំនួយការផ្នែកបច្ចេកទេស | ប្រចាំខែ | ✓ |
| | ជ្រើសរើសបុគ្គលិកជំនាញ(បើសិនជាចាំបាច់)ដើម្បីរៀបចំផែនការហិរញ្ញវត្ថុ និងគៀងគងធនធានហិរញ្ញវត្ថុពីបណ្តាស្ថាប័នសម្រាប់ទ្រទ្រង់សកម្មភាព | មានកំរិតដោយថវិកាមានកំរិតដែរ | ✓ |
| | រៀបចំក្រុមប្រតិកម្មរហ័ស សម្រាប់ឆ្លើយតបទៅនឹងតម្រូវការនិងសំណូមពរនានា | រួចរាល់ | ✓ |
| ៣ | **គោលបំណងយុទ្ធសាស្ត្រ ៣ (ពង្រឹងសមត្ថភាព និងប្តូរផ្តាច់នឹងការងារ របស់គណៈកម្មាធិការប្រតិបត្តិ)** | | |
| | រៀបចំរបាយការណ៍ប្រចាំខែជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់គណៈកម្មាធិការប្រតិបត្តិ | មានរបាយការណ៍រាល់លើក | ✓ |
| | ផ្តល់ការគាំទ្រជាពិសេសដូចជា ហិរញ្ញវត្ថុ ទស្សនៈទាន | មិនបានទៀងទាត់ | |
| | ប្រជុំគណៈកម្មាធិការនិមួយៗជាប្រចាំជារៀងរាល់ខែ | មិនបានទៀងទាត់ | ✓ |
| | គណៈកម្មាធិការប្រតិបត្តិរៀបចំរបាយការណ៍ស្តីពីការប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាជូនប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា | បានធ្វើជាប្រចាំ | ✓ |
| ៤ | **គោលបំណងយុទ្ធសាស្ត្រ ៤ (បង្កើតតំណាងលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជាតាមតំបន់និមួយៗ)** | | |
| | រៀបចំក្រុមការងារ និងមន្ត្រីនៅតាមតំបន់និមួយៗ | បាន៤តំបន់ | ខ្វះ១តំបន់ |
| | ផ្សារភ្ជាប់សហព័ន្ធស្រូវអង្ករកម្ពុជាជាមួយអាជ្ញាធរដែនដីស្ថាប័នមានសមត្ថកិច្ច និងដៃគូអភិវឌ្ឍន៍តាមតំបន់និមួយៗ | បាន១៦ខេត្ត | ✓ |

| | | | |
|---|---|---|---|
| | បណ្តុះបណ្តាលសមត្ថភាពតំណាងតំបន់និមួយៗ | មិនទាន់ | ✓ |
| ៥ | **គោលបំណងយុទ្ធសាស្រ្ត ៥** (**ផ្សារភ្ជាប់ សហព័ន្ធស្រូវអង្ករកម្ពុជាជាមួយសារព័ត៌មាន**) | | |
| | រៀបចំការប្រជុំជាប្រចាំ(ក្រៅផ្លូវការ)ជាមួយភ្នាក់ងារសារព័ត៌មាន | ២លើក | ✓ |
| | បង្កើតបណ្តាញជាមួយភ្នាក់ងារសារព័ត៌មាន | ៣បណ្តាញ | ✓ |
| | រៀបចំកម្មវិធីទូរទស្សន៍ប្រចាំខែ | តាមការចាំបាច់ | ✓ |
| | ពង្រីកបណ្តាញផ្សព្វផ្សាយជាមួយភ្នាក់ងារសារព័ត៌មានផ្សេងៗទៀតអោយបានទូលំទូលាយ | បានធ្វើ | ✓ |
| | រៀបចំសន្និសីទកាសែត តាមការចាំបាច់ | ៥លើក | ✓ |
| ៦ | **គោលបំណងយុទ្ធសាស្រ្ត៦**(**ផ្តោតលើការលើកកំពស់ការយល់ដឹងដល់សាធារណជន**) | | |
| | រៀបចំខ្លឹមសារខ្លីខ្លឹមនៃព័ត៌មាន ឆ្លុះបញ្ចាំងការងារស្នូល របស់សហព័ន្ធ | ២៦០លើក | ✓ |
| | រៀបចំអត្ថបទនានាដើម្បីដាក់បង្ហាញក្នុងគេហទំព័រ និងទំព័រហ្វេសប៊ុក (Facebook) | ជាប្រចាំថ្ងៃ | ✓ |
| | ធ្វើបច្ចុប្បន្នភាព(Update)នៃព័ត៌មាន និងព្រឹត្តិការណ៍នានាជាប្រចាំ | ២៦០លើក | ✓ |
| | រៀបចំអត្ថបទប្រចាំសប្តាហ៍តាមរយៈ E-Briefings | ២៦០លើក | ✓ |
| | បោះពុម្ពនិងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មាន | បោះពុម្ព១០លើក | ✓ |
| | រៀបចំរបាយការណ៍ និងផលិតវីដេអូ | ៦ខ្លីប | ✓ |
| | រៀបចំបេសកកម្មដើម្បីផលិតអត្ថបទផ្សេងៗ | ១០លើក | ✓ |
| | ផ្សព្វផ្សាយព័ត៌មានជាប្រចាំ | ១៣០០លើក | ✓ |
| ៧ | **គោលបំណងយុទ្ធសាស្រ្ត ៧** (**ធ្វើការប្រមូលព័ត៌មាន និងទិន្នន័យអំពីវិស័យស្រូវអង្ករអោយបានទៀងទាត់និងត្រូវលក្ខណៈបច្ចេកទេស**) | | |
| | រៀបចំក្រុមការងារ និងបង្កើតបណ្តាញដើម្បីប្រមូលទិន្នន័យពីសមាជិក និងក្រៅពីសមាជិក | ៥លើក | ✓ |
| | រៀបចំក្រុមការងារបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ Database | បញ្ចូលនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ | ✓ |
| ៨ | **គោលបំណងយុទ្ធសាស្រ្ត ៨** (**ធ្វើការវិភាគទៅលើទិន្នន័យដែលប្រមូលបាន និងសរសេររបាយការណ៍ជូនថ្នាក់ដឹកនាំ សអក**) | | |
| | ជួលក្រុមការងារជំនាញដើម្បីពិនិត្យនិងវាយតម្លៃទិន្នន័យ ព្រមទាំងធ្វើការវិភាគ | ៣លើក | ✓ |
| | រៀបចំក្រុមការងារជំនាញដើម្បីសរសេររបាយការណ៍ផ្អែកលើលទ្ធផលវិភាគទិន្នន័យសម្រាប់ សអក ធ្វើការតស៊ូមតិ | ១៥០លើក | ✓ |
| ៩ | **គោលបំណងយុទ្ធសាស្រ្ត ៩** (**ប្រើឥស្សរតាងជាក់ស្តែងជាលក្ខខណ្ឌក្នុងការជ្រើសរើសសំណើជូនអ្នកនយោបាយ**) | | |
| | បង្កើតនីតិវិធី និងលក្ខខណ្ឌសម្រាប់សអក ក្នុងការលើកជាសំណើរផ្សេងៗដល់ស្ថាប័នរដ្ឋាភិបាល | បានអនុវត្ត | ✓ |
| | ប្រើប្រាស់នីតិវិធី និងលក្ខខណ្ឌ ដើម្បីប្រមូលបញ្ហា ឬសំណើរនានា | បានអនុវត្ត | ✓ |
| | រៀបចំអោយមានការប្រជុំផ្ទៃក្នុងមុនពេលការប្រជុំតស៊ូមតិលើបញ្ហាជាមួយស្ថាប័នរដ្ឋាភិបាល តាមនីតិវិធី | បានអនុវត្ត | ✓ |

| | | | |
|---|---|---|---|
| ១០ | **គោលបំណងយុទ្ធសាស្ត្រ ១០ (បន្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋដែលជាដៃគូយុទ្ធសាស្ត្រ)** | | |
| | អនុវត្តរាល់សេចក្តីសម្រេចដោយអង្គប្រជុំ | បានអនុវត្ត | ✓ |
| | តាមដាន និងវាយតម្លៃការអនុវត្តសេចក្តីសម្រេចនៃការប្រជុំរបស់ក្រុមការងារទី ៩ | បានតាមដាន | ✓ |
| | លើកយកបញ្ហាដែលកើតមានឡើងក្នុងដំណើការអនុវត្តសម្រាប់កិច្ចប្រជុំបន្ទាប់ | ជាប្រចាំ | ✓ |
| | ចូលរួមការប្រជុំជាមួយក្រសួងពាណិជ្ជកម្ម និងពិគ្រោះយោបល់លើបញ្ហាពាណិជ្ជកម្មនានា | ៥0លើក | ✓ |
| | សហការជាមួយក្រសួងសេដ្ឋកិច្ច និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ លើគម្រោងនានា | ៤គម្រោង | ✓ |
| | ស្នើសុំការបញ្ចុះតម្លៃអគ្គិសនីជាបន្តបន្ទាប់ដើម្បីជួយគាំទ្រដល់រោងម៉ាស៊ីនកិនស្រូវ | បានទទួលការបញ្ចុះជាបន្តបន្ទាប់ | ✓ |
| | ប្រសិនបើអាច បន្តស្នើសុំបញ្ចុះតម្លៃ Logistics (ស្នើសុំបញ្ចុះតម្លៃយ៉ាងយោចណាស់ស្មើនឹងប្រទេសជិតខាង) | បានជោគជ័យ ចុះ 5$២0ហ្វីត និង 10$៤0ហ្វីត | |
| II | **គោលដៅ ២ នៃសកម្មភាព** | | |
| ១១ | **គោលបំណងយុទ្ធសាស្ត្រ ១១ (ទាក់ទាញកសិករ និងក្រុមហ៊ុនទាំងឡាយណាដែលមិនទានជាសមាជិកអោយចូល)** | | |
| | ធ្វើការសិក្សាដើម្បីកំណត់យុទ្ធសាស្ត្រទាក់ទាញសហគមន៍កសិករ | ធ្វើទ្រង់ទ្រាយធំ១លើក និងជាប្រចាំតាមតំបន់ | ✓ |
| | តំណាងអ្នកសម្របសម្រួលសហព័ន្ធតាមតំបន់និមួយៗ ជួយប្រជុំពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលនូវគំនិត និងយោបល់ | ធ្វើរួចរាល់ | ✓ |
| | រៀបចំផែនការសកម្មភាពដោយផ្អែកលើលទ្ធផលគម្រោងសិក្សាខាងលើ | ធ្វើរួចរាល់ | |
| | ធ្វើការផ្សព្វផ្សាយស្តីពីអត្ថប្រយោជន៍នានានៃការចូលជាសមាជិកសហព័ន្ធ | ធ្វើរួចរាល់ | ✓ |
| | អនុវត្តអោយបាននូវវិធានផ្សេងៗសម្រាប់ក្រុមហ៊ុនជាសមាជិក និងមិនទាន់ជាសមាជិក | សមាជិកបានទទួលចុះ LoLo Fee, EIA ជាដើម | ✓ |
| ១២ | **គោលបំណងយុទ្ធសាស្ត្រ ១២ (ពង្រឹងការអនុវត្តក្រមសីលធម៌ និងវិន័យជាមួយសមាជិក ព្រមទាំងឯកភាពជាធ្លងមួយ)** | | |
| | តាមដាន និងចុះត្រួតពិនិត្យលើការសកម្មភាពរបស់សមាជិកជាប្រចាំ | បានធ្វើ | ✓ |
| | ជម្រុញអនុវត្តវិធានដែលអនុម័តដោយគណៈកម្មាធិការ និងពង្រឹងការអនុវត្តដោយអនុលោមតាមក្រមសីលធម៌ និងវិន័យ | អនុវត្តក្រមសីលធម៌ | |
| | ពិនិត្យមើលឡើងវិញនូវដំណើរការប្រមូលកំរៃផ្សេងៗ | ប្រសិទ្ធភាពមានកម្រិតចំពោះកម្រៃនាំចេញ និងសមាជិកភាព | ✓ |
| | រៀបចំវិធានការ និងអនុវត្តដាក់ពិន័យចំពោះសមាជិកដែលមិនបានបង់កំរៃទៀងទាត់ | មិនទាន់មាន | ✓ |
| | ពង្រឹងការទំនាក់ទំនងជាមួយសមាជិកតាមរយៈការប្រជុំ និងទស្សនៈកិច្ចជាប្រចាំនិងបង្កើតប្រព័ន្ធទំនាក់ទំនង | ជោគជ័យ | ✓ |
| | ពង្រីកការយល់ដឹងតាមរយៈយុទ្ធនាការផ្សព្វផ្សាយ សិក្ខាសាលា និងដំណើរកំសាន្ត(ដូចជារៀបចំមហាសន្និបាតនៅតាមខេត្ត ដែលមានសមាជិកច្រើន) | មិនទាន់ធ្វើ | ✓ |
| ១៣ | **គោលបំណងយុទ្ធសាស្ត្រ១៣(បង្កើតម៉ាកអន្តរជាតិសម្រាប់ទីផ្សារអន្តរជាតិ)** | | |

| | | | |
|---|---|---|---|
| | សម្រេចការចុះបញ្ជីម៉ាកវិញ្ញាតិកម្មម្លិះអង្ករជាផ្លូវការ | បានចុះនៅក្រសួងពាណិជ្ជកម្ម | ✓ |
| | សម្រេចផែនការត្រួតពិនិត្យ និងបែបបទសម្រាប់អ្នកប្រើប្រាស់ម៉ាកសញ្ញា | រួចរាល់ | |
| | រៀបចំផ្សព្វផ្សាយពីអង្ករដែលប្រើប្រាស់ម៉ាកសញ្ញា | រួចរាល់ | |
| | រៀបចំឯកសារតម្រូវទាំងអស់ដើម្បីដាក់ជូននិងចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម | រួចរាល់ | |
| | ដាក់ឯកសារជូន និងចុះបញ្ជីនៅ WIPO | រួចរាល់ | |
| | កម្មវិធីបើកសម្ពោធឲ្យប្រើប្រាស់ជាផ្លូវការនូវម៉ាកអង្ករជាតិ | រួចរាល់ | |
| | ការចុះបញ្ជីម៉ាកសញ្ញានិងដាក់ឲ្យប្រើប្រាស់លើទីផ្សារអន្តរជាតិគោលដៅសំខាន់ៗ | កំពុងបន្តធ្វើ | ✓ |
| ១៤ | **គោលបំណងយុទ្ធសាស្ត្រ ១៤ ( បញ្ច្រាបម៉ាកអង្ករជាតិ ចូលនៅក្នុងទីផ្សារ)** | | |
| | រៀបចំក្រុមការងារទទួលបន្ទុកការងារផ្សព្វផ្សាយម៉ាកអង្ករទៅក្នុងទីផ្សារ | មិនទាន់មាន | ✓ |
| | ជួបជាមួយស្ថាប័នពាក់ព័ន្ធនានាក្នុងការចូលរួមសកម្មភាពផ្សព្វផ្សាយម៉ាកសញ្ញា ដូចជា ក្រសួង ស្ថានទូត ទូតពាណិជ្ជកម្ម អង្គការក្រៅរដ្ឋាភិបាល សមាគមខ្មែរនៅបរទេស) | មិនទាន់ធ្វើ | ✓ |
| | រៀបចំកាលវិភាគ និងកញ្ចប់ថវិកាសម្រាប់សហព័ន្ធចូលរួមក្នុងពិពរណ៍ពាណិជ្ជកម្មអន្តរជាតិ ដូចជា ការតាំងពិព័រណ៍ម្ហូបអាហារនៅហុងកុង វេទិកាពាណិជ្ជកម្មចិន-អាស៊ាន វេទិការស្រូវអង្ករពិភពលោកនៅ SIAL PARIS, ANUGA-Germany, Fancy Food Fair, USA(San Francisco and New York) | ១១លើក | ✓ |
| | រៀបចំបេសកកម្មទីផ្សារទៅសហភាពអឺរ៉ុប ចិន-ហុងកុង ម៉ាឡេស៊ី សិង្ហបុរី សហរដ្ឋអាមេរិច មជ្ឈឹមបូព៌ា អូស្រ្តាលី អ៊ឺរ៉ុបខាងកើត កូរ៉េខាងត្បូង | ១១លើក | ✓ |
| | បង្កើតតំណាងចែកចាយនៅក្នុងទីផ្សាររបស់សហភាពអឺរ៉ុប ចិន-ហុងកុង ម៉ាឡេស៊ី សិង្ហបុរី សហរដ្ឋអាមេរិច និងបណ្តារគោលដៅសំខាន់ៗផ្សេងទៀត | មិនទាន់មាន | ✓ |
| | ផ្តល់ការលើកទឹកចិត្តអ្នកប្រើប្រាស់ និងក្រុមហ៊ុននាំចេញអង្ករជំបូងដែលប្រើប្រាស់ម៉ាកសញ្ញា និងអ្នកប្រើប្រាស់ទាំង១០ | មានក្នុងផែនការ | ✓ |
| | បណ្តុះបណ្តាលសមត្ថភាពដល់អ្នកប្រើប្រាស់ម៉ាកសញ្ញា | ២លើក | ✓ |
| | បង្កើតប្រព័ន្ធ Database ដើម្បីស្ទេរភាពនៃការគ្រប់គ្រង់អ្នកប្រើប្រាស់ម៉ាកសញ្ញា | មិនទាន់មាន | ✓ |
| ១៥ | **គោលបំណងយុទ្ធសាស្ត្រ ១៥ (ការបំពេញលក្ខខណ្ឌ និងការទាមទារពីទីផ្សារចំពោះផ្គត់ផ្គង់អង្ករ និងអ្នកទិញ)** | | |
| | សហការជាមួយក្រុមហ៊ុនត្រួតពិនិត្យគុណភាពដើម្បីធ្វើចំណាត់ថ្នាក់ រោងម៉ាស៊ីនកិនស្រូវ | ២៦រោងម៉ាស៊ីន | ✓ |
| | កំណត់ដៃគូរអភិវឌ្ឍន៍ ដូចជា AFD, EU, USAID, AUAID, JICA និងស្ថាប័នពាក់ព័ន្ធដើម្បីគាំទ្រ និងអភិវឌ្ឍសមត្ថភាពនិងជំនាញរបស់រោងម៉ាស៊ីនកិនស្រូវ | IFC, AFD, CAVAC, GIZ, JiCA, SRP, USAID, ADB, | |
| | រៀបចំកម្មវិធីជាមួយដៃគូរអភិវឌ្ឍន៍ និងស្ថាប័នរដ្ឋាភិបាលដើម្បីអភិវឌ្ឍរោងម៉ាស៊ីនកិនស្រូវឲ្យមានស្តង់ដារ និងអនុលោមតាមស្តង់ដារសុវត្ថិភាពចំណីអាហារ | ១លើក | ✓ |
| | បណ្តុះបណ្តាលពីរបៀបប្រតិបត្តិការប្រចាំថ្ងៃឲ្យមានប្រសិទ្ធភាព និងចរន្តពាណិជ្ជកម្ម | ៣លើកជាមួយពន្ធដារ | ✓ |

| | | | |
|---|---|---|---|
| | បង្កើតគំរូនៃការដាក់ទិញលក់អង្ករតាមOnline សាកល្បងប្រើប្រាស់កម្មវិធីនេះ និងដាក់ប្រើប្រាស់ Platform នេះ | មិនទាន់មាន | ✓ |
| ១៦ | **គោលបំណងយុទ្ធសាស្ត្រ ១៦ (ណែនាំអោយសហគមន៍កសិករបំពេញលក្ខខណ្ឌតាមតម្រូវការទីផ្សារ)** | | |
| | ***ផលិតកម្មពូជ*** | | |
| | ការរៀបចំផែនការសម្រាប់ផលិតកម្មពូជដែលផ្តោតលើម៉ាកសញ្ញាជាតិ | បានធ្វើមិនទាន់ចប់ | ✓ |
| | ពង្រឹងការសហការជាមួយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) និងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | បានធ្វើ | ✓ |
| | កំណត់ផ្នែកនៃសហការរវាងសហព័ន្ធនិងដៃគូរអភិវឌ្ឍដែលគម្រោងមានស្រាប់ ដូចជា CAVAC ADB, GIZ ជាដើម | បានធ្វើជាមួយកាឌី និងការ៉ាក់ | ✓ |
| | ស្វែងរកនិងភ្ជាប់ទំនាក់ទំនងជាមួយដៃគូរអភិវឌ្ឍផ្សេងៗទៀតដើម្បីគាំទ្រសកម្មភាពផលិតកម្មពូជ | បានធ្វើ | ✓ |
| | ជម្រុញកសិករ និងសហគមន៍កសិកម្មផលិតកម្មស្រូវពូជ | បានធ្វើ | ✓ |
| | ***ផលិតកម្មស្រូវ*** | | |
| | ជ្រើសរើសកសិករ និងសហគមន៍កសិកម្មដែលអាចផលិតស្រូវស្របតាមលក្ខខណ្ឌការទីផ្សារ ដូចជា ការចុះធ្វើកម្មវិធីបោះជំរុំ | មានគម្រោង | ✓ |
| | សម្របសម្រួលជំនួយការផ្នែកបច្ចេកទេស និងបណ្តុះបណ្តាលដល់កសិករ និងសហគមន៍កសិកម្មពីរបៀបអនុវត្តឲ្យអនុលោមតាមតម្រូវការរបស់ទីផ្សារ ដោយមើលតាមម៉ូដែលកសិដ្ឋានគំរូ | បានធ្វើ | ✓ |
| | ផ្សារភ្ជាប់កសិករ និងសហគមន៍កសិកម្មដែលមានសមត្ថភាពជាមួយផលិតកម្មស្រូវពូជ | បានធ្វើ | ✓ |
| | ភ្ជាប់ទំនាក់ទំនង និងត្រួតពិនិត្យកសិដ្ឋានដែលមានសមត្ថភាពគ្រប់គ្រាន់ផលិតពូជនៅគ្រប់តំបន់ | ១លើក | ✓ |
| | ***គម្រោងផ្សេងៗដើម្បីគាំទ្រផលិតកម្មស្រូវ និងស្រូវពូជ*** | | |
| | គម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យា (Contract Farming) | បានធ្វើនៅមានកំរិត | ✓ |
| | គម្រោងបង្រួមក្បាលដីស្រែដើម្បីកាត់បន្ថយចំណាយនិងបង្កើនទិន្នផលស្រូវ | បានធ្វើជាគំរូ | ✓ |
| | គម្រោងកសិដ្ឋានគំរូ | មិនទាន់ | ✓ |
| | គម្រោងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្រ្តអង្ករ (GI Project) ជុំវិញតំបន់បឹងទន្លេសាប | មិនទាន់ធ្វើ | ✓ |
| | គម្រោងអភិវឌ្ឍប្រសិទ្ធភាពប្រព័ន្ធធារាសាស្រ្តសម្រាប់លើកកំពស់ដំណាំស្រូវសម្រាប់ពាណិជ្ជកម្ម | មិនទាន់ធ្វើ | ✓ |
| | **គោលបំណងយុទ្ធសាស្ត្រ ១៧ (ការសម្របសម្រួលការនាំអង្ករចេញជាទ្រង់ទ្រាយធំ)** | | |
| | ប្រមូលនូវបែបបទនីតិវិធីបច្ចុប្បន្នសម្រាប់ការនាំចេញអង្កររបស់កម្ពុជា របស់បណ្តាប្រទេសជិតខាងនិងក្នុងតំបន់ ដើម្បីធ្វើបច្ចុប្បន្នភាពលើនីតិវិធីនាំចេញអង្ករឲ្យប្រសើរឡើង | FOB, CIF | ✓ |
| | សម្របសម្រួលដល់ការណែនាំពីប្រព័ន្ធស្វ័យប្រវត្តិកម្មលើការនាំចេញអង្ករ | មិនទាន់មាន | ✓ |
| | ពង្រីកជម្រើសនៃការកម្មង់ទិញ | ជោគជ័យ | |

| | | | |
|---|---|---|---|
| | ស្នើសុំក្រសួងពាណិជ្ជកម្មគាំទ្រនិងអនុញ្ញាតឲ្យសហព័ន្ធស្រូវអង្ករកម្ពុជា និងក្រុមហ៊ុនហ្គ្រីន ត្រេដ ក្លាយជាតំណាងក្រុមអ្នកនាំចេញអង្ករកម្ពុជា លើកូតាប្រទេសចិន និងប្រទេសផ្សេងៗទៀត | បានសម្រេច | ✓ |
| | ស្នើសុំក្រសួងពាណិជ្ជកម្មពន្លឿនការអនុវត្ត និងពង្រីកទំហំនៃអនុស្សារណៈយោគយល់ជាមួយប្រទេសឥណ្ឌូនេស៊ី | បានជម្រុញ | ✓ |
| | បង្កើតសម្ព័ន្ធអ្នកនាំចេញដើម្បីអនុវត្តកិច្ចព្រមព្រៀងរដ្ឋាភិបាល និងរដ្ឋាភិបាល(G2G) និងលិខិតឥណទាន (LC) | បានរៀបចំឯកសារ | ✓ |
| | ផ្តល់នូវព័ត៌មានទីផ្សារនិងទិន្នន័យស្តីពីការនាំចេញអង្ករ ដោយទៀងទាត់ក្នុង១ឆ្នាំ២ដងតាមរយៈការប្រជុំជាមួយក្រុមហ៊ុននាំចេញដែលជាសមាជិក | ១០ដង | ✓ |
| | **គម្រោងគាំទ្រ** | | |
| | Warehouse Receipt System សម្រាប់វិស័យស្រូវអង្ករ | មិនទាន់ធ្វើ | ✓ |
| | Adopted Financial Schem សម្រាប់សមាជិកសហព័ន្ធ | មិនទាន់បាន | ✓ |
| | ប្រមូលទិន្នន័យសមត្ថភាពប្រមូលទិញ និងស្រូវស្តុករបស់រោងម៉ាស៊ីន | រួចរាល់ | ✓ |
| | ស្វែងរកកត្តាដែលជះឥទ្ធិពលដល់ការអនុវត្តកិច្ចសន្យាប្រមូលទិញស្រូវ | មិនទាន់ធ្វើ | ✓ |
| ១៨ | **គោលបំណងយុទ្ធសាស្ត្រ ១៨** ( ***កែតម្រូវទីផ្សារក្នុងស្រុក តាមរយៈការលុបបំបាត់ការក្លែងបន្លំអង្ករ***) | | |
| | ធ្វើការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរខេត្តដើម្បីទប់ស្កាត់ការនាំចូលអង្ករខុសច្បាប់ | ជោគជ័យ | |
| | ជំរុញឲ្យក្រុមហ៊ុននាំចូលអង្ករទាំងអស់ធ្វើការចុះបញ្ជីទទួលអាជ្ញាប័ណ្ណ | ជោគជ័យ | |
| | ណែនាំដល់សមាជិកសហព័ន្ធទាំងអស់ឲ្យអនុវត្តតាមបទប្បញ្ញត្តិរបស់កាំកុងត្រូល | ជោគជ័យ | |
| | សហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពង្រឹងបទប្បញ្ញត្តិ ស្តីពីអនាម័យនិងភូតគាមអនាម័យសម្រាប់ការនាំចូលអង្ករ និងនាំចេញអង្ករ | ជោគជ័យ | |
| | ជម្រុញអោយអ្នកចែកចាយនិងម្ចាស់ដេប៉ូលក់អង្ករដែលមានតែម(Seal)របស់សហព័ន្ធ | ១លើក | ✓ |
| | ណែនាំសមាជិក និងផ្សព្វផ្សាយដល់ក្រុមហ៊ុនដែលមិនមែនជាសមាជិកឲ្យធ្វើអាជីវកម្មប្រកបដោយតម្លាភាព ដោយផ្តោតលើសុខភាពរបស់អ្នកប្រើប្រាស់ជាចម្បង | ៣លើក | ✓ |
| | ធ្វើការជាមួយបណ្តាក្រុមហ៊ុនគោលដៅសំខាន់ៗដើម្បីផាកពិន័យលើរាល់សកម្មភាពមិនស្របច្បាប់ទាំងអស់ | មិនទាន់បានអនុវត្ត | ✓ |
| | ចុះត្រួតពិនិត្យ និងវាយតម្លៃទីផ្សារអង្ករនៅទូទាំងប្រទេស | បានធ្វើនៅភ្នំពេញ | ✓ |
| | ផ្តល់ទិន្នន័យជាប្រចាំ និងថ្មីបំផុតពីព័ត៌មានអំពីទីផ្សារអង្ករក្នុងស្រុក | បានផ្តល់ប្រចាំសប្តាហ៍ | ✓ |
| | ធ្វើការស្រាវជ្រាវពីទីផ្សារអង្ករក្នុងស្រុក | បានធ្វើទីតាំងមួយចំនួន | ✓ |
| III | **គោលដៅ ៣ នៃសកម្មភាព** | | |
| ១៩ | **គោលបំណងយុទ្ធសាស្ត្រ១៩** ( ***រៀបចំបង្កើតប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការប្រមូលទិន្នន័យយ៉ាងទៀងទាត់***) | | |
| | បង្កើតប្រព័ន្ធជាអចិន្ត្រៃយ៍ និងក្រុមការងារដើម្បីប្រមូលទិន្នន័យ និងព័ត៌មានពីសមាជិក | រួចរាល់ | |

| | | | |
|---|---|---|---|
| | រៀបចំក្រុមការងារនិងបណ្តាញដើម្បីប្រមូលទិន្នន័យ និងព័ត៌មានពីក្រុមហ៊ុនដែលមិនមែនជាសមាជិក | រួចរាល់ | |
| | កសាងបណ្តាញ និងដៃគូរយុទ្ធសាស្ត្រដើម្បីធានាដល់ការចែករំលែកនូវទិន្នន័យ និងព័ត៌មាន | នៅខ្វះយន្តការ | ✓ |
| ២០ | **គោលបំណងយុទ្ធសាស្ត្រ ២០ (វិភាគតួលេខ និងសរសេររបាយការណ៍តាមលក្ខណៈវិទ្យាសាស្ត្រ)** | | |
| | ទិញឬជួលកម្មវិធីដើម្បីផ្ទុក និងដំណើរការទិន្នន័យរៀបចំក្រុមការងារដើម្បីផ្ទៀងផ្ទាត់ និងបញ្ចូលទិន្នន័យទៅក្នុង Database | ខ្វះថវិកា | ✓ |
| | រៀបចំក្រុមការងារបច្ចេកទេស ឬជួលអ្នកជំនាញសម្រាប់រៀបចំម៉ូដែល និងវិភាគទិន្នន័យ | ខ្វះថវិកា | ✓ |
| | រៀបចំរបាយការណ៍ដាក់ជូនថ្នាក់ដឹកនាំសហព័ន្ធជាប្រចាំ | បានធ្វើជាប្រចាំ | ✓ |
| | ផ្សព្វផ្សាយទិន្នន័យ ព័ត៌មាន និងរបាយការណ៍ដែលបានសិក្សា | មិនទាន់សិក្សា | ✓ |
| ២១ | **គោលបំណងយុទ្ធសាស្ត្រ ២១ (បោះពុម្ព និងផ្សព្វផ្សាយពីវិស័យស្រូវអង្ករតាមរយៈការធ្វើគម្រោងនិងកម្មវិធីផ្សេងៗ)** | | |
| | ***គម្រោងការគូសផែនទីវាលស្រែ និងទីតាំងរោងម៉ាស៊ីន និងសហគមន៍*** | គូសផែនទីរោងម៉ាស៊ីន និងសហគមន៍រួចរាល់ | ផែនទីវាលស្រែ |
| | ប្រមូលព័ត៌មានអំពីទីតាំងរោងម៉ាស៊ីនកិនស្រូវ ឈ្មួញកណ្តាល សហគមន៍កសិករដើម្បីគូសផែនទី | ជោគជ័យ | |
| | ផលិតផែនទីវាលស្រែទៅតាមប្រភេទស្រូវទូទាំងប្រទេសកម្ពុជា | មិនពេញលេញ | ✓ |
| | អនុវត្តគម្រោងសាកល្បងគូសផែនទីដំណាំស្រូវ និងសហគមន៍កសិករនៅក្នុងខេត្តតាកែវ និងបណ្តាខេត្តផ្សេងៗទៀត | មិនពេញលេញ | ✓ |
| | ***ការប្រមូលផលស្រូវធៀបនឹងសមត្ថភាពនៃឡសម្ងួត និងរោងម៉ាស៊ីនកិនស្រូវដែលមានស្រាប់*** | | |
| | រៀបចំក្រុមការងារដើម្បីប្រមូលទិន្នន័យអំពី ការប្រមូលទិន្នផលស្រូវតាមកន្លែងនិងពេលវេលាតាមប្រភេទស្រូវ | រួចរាល់ តែត្រូវធ្វើបច្ចុប្បន្នភាព | ✓ |
| | រៀបចំក្រុមការងារដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យសមត្ថភាពឡសម្ងួត និងម៉ាស៊ីនកិនស្រូវរបស់សមាជិក | រួចរាល់ | |
| | ធ្វើការផ្សព្វផ្សាយពីទិន្នន័យអំពីបរិមាណស្រូវ និងសមត្ថភាពសម្ងួត និងការកិនស្រូវទៅកាន់សមាជិក | មិនទាន់ពេញលេញ | ✓ |

****សំគាល់៖ សង្ខេបសកម្មភាពនិងគម្រោងនានាអាទិភាពត្រូវបន្ត៖**

| លរ | សកម្មភាពនិងគម្រោងអាទិភាពនានា | សម្រេចបាន (២០១៤-២០១៩) | បន្ត |
|---|---|---|---|
| ១ | បន្តការប្តឹងតវ៉ាទៅកាន់តុលាការសហភាពអឺរ៉ុបករណីដាក់ពន្ធលើអង្ករកម្ពុជា | ដាក់ប្តឹងរួច | ✓ |
| ២ | បន្តសហការជាមួយក្រសួងពាណិជ្ជកម្មលើការអនុវត្តMoUជាមួយCOFCO | MoU2018& 2019 | ✓ |
| ៣ | បន្តសហការនិងចុះបញ្ជីម៉ាកអង្ករនៅទីផ្សារអន្តរជាតិជាង៥០ប្រទេស | ចុះតាមWIPO | ✓ |

| | | | |
|---|---|---|---|
| ៤ | បន្តពង្រាងចុះអនុស្សារណៈជាមួយCOFCOលើកិច្ចសហការផ្សព្វផ្សាយនិងការពារម៉្លិះអង្ករ | មិនទាន់បានចុះ | ✓ |
| ៥ | រៀបចំកម្មវិធីមហាសន្និបាតប្រចាំឆ្នាំ | ៤លើក | ✓ |
| ៦ | រៀបចំវេទិកាស្រូវអង្ករកម្ពុជាថ្នាក់ជាតិ និងអន្តរជាតិ រៀងរាល់២ឆ្នាំម្តង | ៣លើក | ✓ |
| ៧ | ក្រកូតស្រូវ-អង្ករថ្នាក់ជាតិប្រចាំឆ្នាំ | ៦លើក | ✓ |
| ៨ | ដឹកនាំសមាជិក  និងនាំយកអង្ករទៅប្រកួតពានរង្វាន់អង្ករល្អបំផុតលើពិភពលោក និងចូលរួមពិព័រណ៍និងចាប់ដៃគូពាណិជ្ជកម្ម | ៤លើក | ✓ |
| ៩ | បន្តគម្រោងការបន្សុទ្ធនិងចុះបញ្ជីពូជស្រូវសែនក្រអូប និងស្រូវផ្ការំដួលមិនប្រកាន់រដូវ សហការជាមួយCARDI &CAVAC | សម្រេចពូជសែន | ✓ |
| ១០ | រៀបចំចុះMoUជាមួយក្រសួងបរិស្ថានឡើងវិញ ដើម្បីបន្តសុពលភាព | MoUចាស់៣ឆ្នាំ | ✓ |
| ១១ | បន្តសហការជាមួយអគ្គនាយកដ្ឋានកសិកម្មដើម្បីសម្របសម្រួលជាមួយសមត្ថកិច្ចចិន ដើម្បីវាយតម្លៃរោងម៉ាស៊ីនលើកទី២ | លើកទី១ បាន២៦រោងម៉ាស៊ីន | ✓ |
| ១២ | បន្តចូលរួមផ្តល់ធាតុចូលសម្រាប់គោលនយោបាយស្រូវអង្ករថ្មីរបស់រាជរដ្ឋាភិបាល | បានប្រជុំ២លើក | ✓ |
| ១៣ | ជម្រុញការអនុវត្តលើគម្រោងឃ្លាំងនិងឡសម្ងួត | MoCចុះMoU | ✓ |
| ១៤ | ជម្រុញការផ្តល់កម្ចីឥណទានរដ្ឋាភិបាលតាមរយៈRDB | ៨០លានដុល្លា | ✓ |
| ១៥ | បន្តពង្រឹងក្រុមការងារថ្នាក់ខេត្ត និងតំបន់ទាំង៥ | សម្រេច៤តំបន់ | ✓ |
| ១៦ | សកម្មភាពនានាដែលនៅសល់ដូចមានចែងក្នុងផែនការ៥ឆ្នាំ | សម្រេច៨០% | ✓ |



# 5 ទិន្នន័យសំខាន់ៗ

## 5.1 ទិន្នន័យ-ស្ថិតិ ( តម្លៃអង្ករFOB និងការនាំចេញអង្ករ២០១០-២០១៩ និងតម្លៃស្រូវ )

Statistics of Cambodia Rice Export Over 10 Years and Half




Shares of Cambodia Rice Export by Types



Trends of Cambodia Rice Export by Types




| | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|---|
| Paboiled Rice | | 19,050 | 41,863 | 46,633 | 84,998 | 26,638 |
| White Rice | 194,004 | 135,226 | 221,862 | 188,605 | 156,654 | 105,990 |
| Fragrant Rice | 6,664 | 61,966 | 87,913 | 130,237 | 169,475 | 204,146 |
| Premium Fragrant Rice | 178,190 | 170,819 | 186,758 | 176,669 | 224,552 | 289,451 |

Designation of Rice Export over last 4 years



Cambodia Rice (FOB) Price in 2017




Cambodia Rice (FOB) Price in 2018









## 5.2 ផែនទីតំបន់ រោងម៉ាស៊ីន និងសហគមន៍






## ខេត្តបន្ទាយមានជ័យ

| | ស.កិន/ម៉ | សំងួត / ម៉ |
|---|---|---|
| រោងម៉ាស៊ីនកិនស្រូវ ហួត ជឹង | ៨ តោន | N/A |

## ខេត្តបាត់ដំបង

| | | |
|---|---|---|
| ក្រុមហ៊ុនបៃតង (កម្ពុ ជា) ភីអិលស៊ី | ៤៥ តោន | ៦០០ តោន |
| ភូ ប៉ុយ ឌីវេឡុបមេន អ៊ីមផត អិចផត | ២០ តោន | ១៥០ តោន |
| រោងម៉ាស៊ីនកិនស្រូវ ឈង ឌីន | ២០ តោន | N/A |
| រោងម៉ាស៊ីន កិនស្រូវ អៀង ហ៊ាង | ២០ តោន | N/A |
| រោងម៉ាស៊ីនកិនស្រូវ អេង ហុក | ១៥ តោន | ១៥ តោន |
| រោងម៉ាស៊ីនកិនស្រូវ ឡាយ សែ | ១២ តោន | N/A |
| រោងម៉ាស៊ីនកិនស្រូវហ្សេត រ៉ាយស៍ បាត់ដំបង | ១០ តោន | ១៦០ តោន |
| ក្រុមហ៊ុន បាត់ដំបងរ៉ាយស៍ អ៊ិនវេសមេន | ១០ តោន | N/A |
| រោងម៉ាស៊ីនកិនស្រូវ សៀ ហេង | ៨ តោន | N/A |
| ក្រុមហ៊ុនលីម ឃាងហួត អិមផត អិចផត | ៧ តោន | ២០០ តោន |

## ខេត្តព្រៃវែង

| | | |
|---|---|---|
| រោងម៉ាស៊ីនកិនស្រូវ ឈុន ធំ | ៨ តោន | ៣០០ តោន |
| រោងម៉ាស៊ីនកិនស្រូវ ឈិត ប៊ុនថន | ៨ តោន | ១៥០ តោន |
| រោងម៉ាស៊ីនកិនស្រូវ ហេង ហៀង | ៧ តោន | ១៥០ តោន |

## ខេត្តតាកែវ

| | | |
|---|---|---|
| រោងម៉ាស៊ីនកិនស្រូវ ហ្គោល ឌិនដូនកែវ | ៦៥ តោន | N/A |
| ក្រុមហ៊ុន សុខ កែវ អ៊ីមផត អ៊ិចផត | ១០ តោន | ១០០ តោន |

## ខេត្តកំពត

| | | |
|---|---|---|
| ក្រុមហ៊ុន ត្រីស្តាល់រ៉ាយស៍ (កម្ពុ ជា) ខូអិលធីឌី | ៨០ តោន | ៣០០០ តោន |

## ខេត្តកំពង់ចាម

| | | |
|---|---|---|
| ក្រុមហ៊ុនឡ អៀកហេង សេកមាស រ៉ាយស៍ | ១៥ តោន | ១៥០ តោន |
| រោងម៉ាស៊ីនកិនស្រូវ ហាក់ សែ | ៨ តោន | N/A |
| ក្រុមហ៊ុន អេមរុ រ៉ាយ ស៍ (ខេ មូឌា) | ១៦ តោន | N/A |

## ខេត្តសៀមរាប

| | | |
|---|---|---|
| រោងម៉ាស៊ីនកិនស្រូវ កៅ មី | ១៣ តោន | ១០០ តោន |
| រោងម៉ាស៊ីនកិនស្រូវ រស់ ហួរ | ១០ តោន | ៧០ តោន |

## ខេត្តត្បូងឃ្មុំ

| | | |
|---|---|---|
| ក្រុមហ៊ុន នីកូលីន អ៊ីនវេសមែន ខូអ៊ិលធីឌី | ១២ តោន | ១៥០ តោន |

## ខេត្តកណ្តាល

| | | |
|---|---|---|
| រោងម៉ាស៊ីនកិនស្រូវ អង្គរកសិកម្ម រុងរឿង | ៣០ តោន | N/A |
| ក្រុមហ៊ុន 7NG UNION RICE | ១០ តោន | N/A |
| ក្រុមហ៊ុន តិច ស៊ួន អាហ្គ្រោ អ៊ិនដាស្ទ្រី | ៨ តោន | N/A |

## រាជធានី ភ្នំពេញ

| | | |
|---|---|---|
| ក្រុមហ៊ុន ម៉ែន សារុន អាហារ៍ណ នីហារ៍ណ និងសំណង់ | ២៤ តោន | N/A |
| ក្រុមហ៊ុន ខាម៉ារ៉ាយស៍ លីមីតធីត | ១២ តោន | N/A |

## ខេត្ត កំពង់ឆ្នាំង

| | | |
|---|---|---|
| ក្រុមហ៊ុន ឥណ្ឌ ចាយណា រ៉ាយស៍មីល លីមីធីត | ១២ តោន | N/A |

## ខេត្ត កំពង់ស្ពឺ

| | | |
|---|---|---|
| ក្រុមហ៊ុន ស៊ី អេច រ៉ាយ អិន រ៉ាយស៍ អ៊ីមផត អិចផត | ២២ តោន | N/A |
| រោងម៉ាស៊ីនកិនស្រូវ អប្សររ៉ាយស៍ (ខេមបូឌាន) | ២០ តោន | N/A |

## ខេត្ត កំពង់ធំ

| | | |
|---|---|---|
| រោងម៉ាស៊ីនកិនស្រូវ កំពង់ធំ រ៉ាយស៍ | ៨ តោន | ៩០ តោន |

## 5.3 កម្រងរូបភាពផ្សេងៗ






















រួមគ្នាអនាគតតែមួយ





365 Moving Co.,Ltd
7NG Union Rice Co.,Ltd
AGRIBUDDY Co.,Ltd
Amru Rice (Cambodia) Co., Ltd
Amtak Thebtey Angricultural Cooporation
Angkor Kasekam Roong Roeung Co.,Ltd
ANZ Royal Bank (Cambodia)., Ltd
Apsara Rice (Cambodia) Co.,Ltd
AQIP SEED Co.,Ltd
ASIA COMMERCE VERTS (CAMBODIA) CO.,LTD
Asia Diamond Rice Import Export Co., Ltd
Baitang (Kampuchea) Plc.
Battambang Rice Investment Co.,Ltd
Bayon Cereal Co.,Ltd
Boost Riche(Cambodia)Co.,Ltd
Boromey Vuthy Rice Miller
Bou Sokha Rice Mill
Bou Sokkhai Rice Mill
Bred Bank (Cambodia) PLC
Brightway Group Co.,Ltd
Buhler (CAMBODIA) Co.,Ltd
Bun Hor Rice Mill
Bureau Veritas (Cambodia) Limited
CAM MJ AGRICULTURAL PARK Co.,Ltd
CAMBODIA LI SHINE INTERNATIONAL TRADE
Cambodian Federation Association of Rice Producer
Cambodian Organic Farm Enterprise (C.O.F.E) Co.,Ltd
Capital Food Investment Import Export Co.,Ltd
CaviFoods Company Co.,Ltd
CCIC (Cambodia)
Champa Preyphdoa Agricultural Cooperative( CPAC)
Chamroeun Chey Agriculture Community
Chamroeun Meanchey Agricultural Cooperative
Chamroeun Phal Rang Kesey Angricultural Cooporation
Chan Kok Lun rice Mill
Chang Korn Meng Rice Mill
Chao Lor Suong Rice Mill
Chao Seav Rice Mill
Chea Hap Rice Mill
Cheav Khouy Rice Mill
Cherng Koun Chorkchey Angricultural Cooporation
Chheang Heng Rice Mill
Chheung Bun Ham Rice Mill
Chhith Bounthan Rice Mill
Chhnal Morn Samki Rongroeun Angricultural Cooporation
Chhorng Din Rice Mill
Chhueng Born Rice Mill
Chhun Thom Rice Mill
Chhuon Vorn Rice Mill
CHIEF (Cambodia) Specialized Bank Plc
Chin Van Rice Mill
Chouk Tep Rice Mill
Chrou Thol Rice Mill
Chum Lay Rice Mill
Chuoy Sam Rice Mill
ChyKraeng Sammky Agriculture Development Community
City Rice Import Export Co.,Ltd
CK Rice Trading Co., Ltd
CMA CGM Cambodia Co.,Ltd
Control Union (Cambodia) Co.,Ltd
Cool Transportation & Logistic Co.,Ltd
Crystal Rice (Kampuchea) Co., Ltd
CWT Commodities (Cambodia) Co.,Ltd
Domnak Teuk Group Co., Ltd
Dy Chhay Rice Mill
Eang Heang Import Export Co., Ltd
Ear Chhaiy Yin Rice Mill
Eath LeangKheng Rice Mill
Eath Leangseng Rice Mill
E-Freight Solution Inc
Eng Dypo Aphivath Co.,Ltd
Eng Hok Rice Mill
Eng Sorng Rice Mill
Eng Sour Rice Mill
Eng Van Mao Rice Mill
Export Trading Commodities (Cambodia) Limited
Fang Ly Rice Mill
Fang Vun Rice Mill
Fang Vy Rice Mill
Farmer and Natural Networking Association
Farmer and Natural Networking Federation
Fed Rcie Battambang Ltd
Federation of Associations For Small and Medium Enterpaises of Cambodia
First Packaging Partner Co., Ltd
Global Ecological Rice (Cambodia) Co.,Ltd
Golden Daun Keo Rice Mill Co.,Ltd
Golden Rice (Cambodia) Co.,Ltd
Golden Star Rice Mill and Import Export Co.,Ltd (Pkay Meas Rice Mill)
Great & Grain Garment Asia Pacific( Cambodia) Co.,Ltd
Green Rice Agriculture Development
Green Trade Company
Guohong (Cambodia) Industry Co.,Ltd
Hang Pi Phally Sokha Rice Mill
Hay Chuong Rice Mill
Heng Heang Rice Mill
Heng Horm Rice Mill
Heng Huch Rice Mill
Heng Lay Rice Mill
Heng Seang Hak Rice Mill
Herba (Cambodia) Co.,Ltd
High Level Logistics (Cambodia) C.,Ltd
Hoeng Siva Rice Mill
Hong Ly Rice Mill
Hout Chheng Ngoun Rrice Mill
HS Rice Co.,Ltd
Hung Hiep (Cambodia) Co.,Ltd
Huong Leng Rice Mill
Huong Long Rice Mill
Huot Ching Rice Mill
Huy Eang Rice Mill
Idemitsu Saison Microfinance (Cambodia) Plc
Im Eangkry Co.,LTD
Indochina Rice Mill Limited
International Rice Trading (Cambodia)Co.,LTD
Jasmine Rice Mill Factory Co., Ltd
Jing Mi Rice Mill Co.,Ltd
Ka Vannara Rice Mill
Kakoh Agriculture Cooperative (KKAC)
Kampeng Soksen Sambo Agricultural Cooperative
Kampongthom Rice Mill Limited
Kao My Rice Mill
Kao Nget Rice Mill
Kasikor Samki Rongroeung Agricultural Cooperative
“Keat Sothea Rice Mill
Keopor Samki Chamroeu Phal Agricultural Cooperative
Khean Kav Rice Mill
Kheng Hout Rice Mill
Khieu Techsreang Rice Mill
Khiev Khea Rice Mill
Khiev Khean Rice Mill
Khmer Foods Group Co., Ltd
Khum Wat Tamem Angricultural Cooporation
Khun Nguon Rice Export Co.,Ltd
Khuth Thanh Rice Mill
Khy Thay Corperation Co., Ltd
Kim Se Rice Mill
Kim Sun Rice Mill
Kim Ty Rice Mill
Klakrahoem Meanchey Agricultural Cooperative
Kol Veasna Investment Co.,Ltd
Kong Hour Rice Mill import export Co., Ltd
Kor 1 (Hort Ngun Hong) Rice Mill
Kors krlor Pheakdey reaksmey Rongroeun Angricultural Cooporation
Krabao Promtep Agriculture Development Community
Laov Fak Rice Mill
LBN Angkar (Kampuchea) Co.,Ltd
Lerk Kompos Kasikor Agricultural Cooperative
Ley Chhinh Rice Mill
Lim Chhunly Rice Mill
Lim Heng Leap Trading Co.,Ltd
Lim Kheang Hout Import Eport Co.,Ltd
Loeung Chhoy Rice Mill
Long Chhengmeng Rice Mill
Lor Eak Heng Sek Meas Rice Co.,Ltd
Loran Group (Plc)
Loun Cheng Leang Rice Mill
Luon Kun Rice Mill
Ly Chhean Rice Mill
Mao Kuch Rice Mill
Mao Siphorn Rice Mill
Meas Chheng Rice Mill
Meas Sor (Kampuchea) Co.,Ltd
Mei Jing Rice (Cambodia) Co.,Ltd
Mekong Agro (KH) Industries Limited
Mekong Oryza Trading Co.,Ltd
Men Sarun Import Export & Construction Co.,Ltd
Milin Rice (Cambodia) Import Export Co.,Ltd
Mom Sophal Rice Mill
Mongkol Phum SalaTrav Angricultural Cooporation
Muoy Leang Rice Mill
Neng Po Rice Mill
Ngauv Huong Rice Mill
Ngeap Chiv Rice Mill
Ngin Beang Rice Mill
Ngov Meng Rice Mill
Nguon Hong Rice Mill
Nhek Sarith Rice Mill
Nikoline Investment Co.,Ltd
Norm Srim Rice Mill
Noyakong Group Co., Ltd
Om Seth Than Rice Mill
OMIC (Cambodia) Ltd
Palm Rice Co.,Ltd
Pen Narom Rice Mill
Pheak Chhuoy Rice Mill
Phnom Bayang Agricultural Cooperative (PBAC)
Phou Poy Develpment Import Export Co.,Ltd
Phour Kok Ky Rice Mill
Phouv Thouv Rice Mill
Phrahpos Ponleu Thmey Agricultural Cooperative
Phum Yerng Agriculture Development Community
Pidor Ta Ung Agriculture Development Community
Pisda Aphivath Co.,Ltd
Pomleu Samki Angricultural Cooporation
Pon Loeu Kasekor Agricutural Cooperative
Ponleu Beng Krapom Chhouk Agricultural Cooperative
Ponleu Thmey Phaong Agricultural Cooperative
Ponlok Thmey Angricultural Cooporation
Por Samroung Angrilcultural Cooporation
Pov Kea Import Eport Co.,Ltd
Pracheachun Prey Romdeng Agricultural Cooperative(P-PRAC)
Prasat Soksenchey Agricultural Cooperative (PAKC)
Preah Sihanouk Agriculture Development community
Prey Yuthka Agricultural Cooperative (PYTAC)
Primalis Corporation Co.,Ltd
R.L Co.,Ltd
Ram Sar Steung Traeng Rice Development
Reak Chamroeun Agriculture Development Community
Reaksmey Dombok Khpos Meanchey
Reaksmey Prey Pnhors Angricultural Cooporation
Roluos Meanchey Raksmey Satrey Angkor Agricultural Cooperative
Roluos Meas Agricultural Cooperative(RLMAC)
Romdoul Seryreang tareach Angricultural Cooporation
Ros Hour Rice Mill
Royal Rallway Co.,Ltd
Ruos Neng Rice Mill
SAMBATHVATHANAK C.,Ltd
Samki Amtak Angricultural Cooporation
Samor Leu Agricultural Cooperative (SALAC)
Samply Angkor Reangsei Agricultural Cooperative (RLMAG)
Sann & Khan Rice Mill
Sann Ty Rice Mill
Sao Hak Se Rice Mill
Sary KuntheaInternational trading Co.,Ltd
Satrey Haong Samnam Agriculture Development Community
Scafco Corporation (DBA Scafco Grain Systems Company)
Se Chamroeun Rice Mill
Se Khun Rice Mill
Sen Rith Rice Mill
Seng Bunsor Rice Mill
Senh Chhinh Rice Mill
SGS (Cambodia) Limited
Siev Heng Rice Mill
Siev Lay Rice Mill
Signatures of Asia Co.,Ltd
Smach Kompong Ror Agriculture Development Community
Sok Keo Import Export Co.,Ltd
Soma Trading Co., Ltd
Sombo Meanchey Agriculture Community
Sombo Rice Co.,Ltd
Song Heng Rice Mill
Sor Kimsuong Rice Mill
Speed Logistics & Transportation Co.,Ltd
Sramor Sreboeng Agricultural Cooperative (SSAC)
SSCORP (Cambodia) Ltd
Suon Sophal Rice Mill
Suy Vanni Rice Mill
Svay Meanhey Satrey Sammaky Community
T.M.K Investment Co.,Ltd
T.O.T (Trust Our Trade) Co.,LTD
Ta Kol Yiv Pov Rice Mill
Taing Cheng Rice Mill
Takbey Lay Kongveng Rice Mill
Tangkrsao Kasikor Chok Chey Agricultural Cooperative
Teav Heu Rice Mill
Teav Eang Rice Mill
Tech Soon Agro- Industry Co.,Ltd
Teng Lay Import Export and Transportation Co.,Ltd
Thean Kong IMPEX
Thmor Korl Rice Import Export Co.,Ltd
Thol Sam At Rice Mill
Thorn Chea Rice Mill
Tong Pheap Rice Mill
Tong Pheap Rice Mill
Touch Sarom Rice Mill
Trapaing Russey Agriculture Development Community
Tuol Prasvihear Agricultural Cooperative (TPVAC)
TUV Rheinland (Cambodia) Co.,Ltd
Ty Chay Rice Mill
Udom Sorya Agricultural Community
Ung Simon Rice Mill
UNI – Natural Co.,Ltd
Vann Linh Vou Rice Mill
Vibol Dara Rice Mill
Vinh Cheang Medium Enterprise of Rice Mill
Vong Bun Heng Import Export Co., Ltd
Vong Sambath Rice Co.,Ltd
W.K.R. Trading Co., Ltd
Wat Kor Chamroeun Phal Angricultural Cooporation
White Gold Import Export Co., Ltd
Xiang Shan Rice (Cambodia) Co.,Ltd
Ya Rina Rice Mill
Yam Bunsong Rice Mill
Yam Chanray Rice Mill
Yam Kinh Rice Mill
Yam Sann Rice Mill
Yamloeung Rice Mill
Yeung Shi Group Co., Ltd
Yin Khuong Rice Mill
Yin Mann Rice Mill
Yin Pou Rice Mill
You Khim Rice Mill
See more at: www.crf.org.kh

**គាំទ្រដោយ SUPPORTED BY**

**ឧបត្ថម្ភដោយ SPONSORED BY**